# ជំពូក ៣

## ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ

## RELEVANT LAW AND REGULATIONS

Draft

Draft

# ជំពូកទី ៣

# ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ

## ៣.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័តដោយសភាធម្មនុញ្ញ និងប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលមាត្រាពាក់ព័ន្ធ និងគម្រោងនេះមានដូចតទៅៈ

- **មាត្រា២:** បូរណភាពទឹកដី របស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាត ក្នុងព្រំដែនរបស់ខ្លួនដែលបានកំណត់ក្នុងផែនទីខ្នាត/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩។
- **មាត្រា៤:** បាវចនា នៃព្រះរាជាណាចក្រកម្ពុជា គឺជាតិ សាសនា ព្រះមហាក្សត្រ។
- **មាត្រា៥:** ភាសា និងអក្សរដែលប្រើជាផ្លូវការ គឺភាសា និងអក្សរខ្មែរ។
- **មាត្រា៥៨:** ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀត ដែលបានកំណត់ថាជារបស់រដ្ឋ។

ការគ្រប់គ្រងលើការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់។

- **មាត្រា៥៩:** រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាព នៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភោគោត្តសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផល ព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល។

## ៣.២ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ ២០០៨

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋ សភាលើកទី៧ និតិកាលទី៣ ហើយបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រម លេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ដែលមានមាត្រាពាក់ព័ន្ធនិងគម្រោងដូចតទៅៈ

- **មាត្រា១:** ច្បាប់នេះកំណត់ក្របខណ្ឌ័នៃការគ្រប់គ្រងការអភិរក្សនិងការអភិវឌ្ឍតំបន់ការពារធម្មជាតិ។

គោលបំណងនៃច្បាប់ នេះគឺធានានូវការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះនិងការធានាប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

- **មាត្រា២:** ច្បាប់នេះមានវិសាលភាពអនុវត្ត នៅតំបន់ការពារធម្មជាតិ ដែលកំណត់ដោយបទប្បញ្ញត្តិទាំងឡាយ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស.រកម.១២៩៦-៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ ការពារធម្មជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ឋបនីយ ជីវមណ្ឌលបឹងទន្លេសាប លេខនស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០១ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត។
- **មាត្រា៤:** ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដូចមានចែងនៅក្នុងមាត្រា២ នៃច្បាប់នេះត្រង់ស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។ ក្រសួងបរិស្ថានមានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាសេនាធិការសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

Draft

នៃព្រះរាជាណាចក្រកម្ពុជា។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។ ការគ្រប់គ្រងតំបន់ការពារធម្មជាតិត្រូវធានានូវសិទ្ធិរបស់សហគមន៍មូលដ្ឋានជនជាតិដើមភាគតិចនិងសាធារជនដើម្បីចូលរួម ក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង និងការអភិរក្សជីវៈចម្រុះប្រកបដោយនិរន្តរន៍ភាព។

-**មាត្រា៦:** មន្ត្រីរដ្ឋបាលការពារនិងអភិរក្សធម្មជាតិមានសិទ្ធ និងភារកិច្ចសំខាន់ៗ ដូចខាងក្រោម:

១- យាមល្បាត ត្រួតពិនិត្យជាប្រចាំ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិគ្រប់ប្រភេទនៅក្នុងតំបន់ការពារធម្មជាតិ។

២- ត្រួតពិនិត្យលិខិតអនុញ្ញាត និងឯកសារផ្សេងៗដែលកំណត់ដោយច្បាប់នេះ

៣- មានវិធានការទប់ស្កាត់ភ្លើងឆេះព្រៃ ក្នុងតំបន់ការពារធម្មជាតិ

៤- ត្រួតពិនិត្យរាល់ការនាំចេញការនាំចូលនូវប្រភេទសត្វ រុក្ខជាតិគ្រាប់រុក្ខជាតិនិងសំណាកក្នុងតំបន់ការពារធម្មជាតិ

៥- ធ្វើការអប់រំផ្សព្វផ្សាយ និងសម្របសម្រួល ជាមួយសហគមន៍មូលដ្ឋានជនជាតិដើមភាគតិចក្នុងដំណើរការរៀបចំ និងការអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ។ សិទ្ធនិងភារកិច្ចលម្អិតរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

-**មាត្រា៨:** ការសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិ ណាមួយត្រូវផ្អែកតាមលទ្ធផល នៃការសិក្សាស្រាវជ្រាវលក្ខណៈវិនិច្ឆ័យ គោលបំណងនៃការគ្រប់គ្រង សិទ្ធប្រើប្រាស់ធនធានធម្មជាតិ សិទ្ធិកាន់កាប់ដីធ្លី និងកត្តាពាក់ព័ន្ធផ្សេងទៀត។ការស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយត្រូវភ្ជាប់មកជាមួយនូវ:

១- ការអធិប្បាយអំពីសារៈសំខាន់ខាងផ្នែកជីវៈចម្រុះ សណ្ឋានដី ភូគព្ភសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងការអភិរក្ស តំបន់ដែលស្នើសុំរៀបចំប្រែតំបន់ការពារធម្មជាតិនោះ

២- ការអធិប្បាយអំពីលក្ខណៈច្បាប់ នៃតំបន់ដែលស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិ ភ្ជាប់ជាមួយនូវផែនទីមាន មាត្រាដ្ឋានកំណត់ច្បាស់លាស់ ដែលបង្ហាញយ៉ាងច្បាស់អំពី ទីតាំង ព្រំប្រទល់ និងទំហំនៃតំបន់ការពារធម្មជាតិនោះ

៣- ការបញ្ជាក់ពីគោលបំណង នៃការគ្រប់គ្រងតំបន់ស្នើរៀបចំ និងការគម្រោមកំហែងចំពោះមុខ

៤- ការសិក្សាលើការប្រើប្រាស់ធនធានធម្មជាតិ និងដីធ្លី នៅក្នុងតំបន់ការពារធម្មជាតិ

៥- របាយការណ៍អំពីលទ្ធផលនៃការពិគ្រោះយោបល់ ជាមួយស្ថាប័ន ភាគីពាក់ព័ន្ធ និងតំណាងអាជ្ញាធរមូលដ្ឋាន ដែលមានទីតាំងនៅក្នុង ឬក្បែរតំបន់ស្នើសុំ រៀបចំកែប្រែតំបន់ការពារធម្មជាតិ។ ការរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយត្រូវកំណត់ដោយអនុក្រឹត្យ។

-**មាត្រា១១:** តំបន់ការពារធម្មជាតិនីមួយៗបែងចែកចេញជាបួន (៤) តំបន់គ្រប់គ្រង:

**១-តំបន់ស្នូល:** ជាតំបន់គ្រប់គ្រងដែលមានតម្លៃខ្ពស់ សម្រាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិដែលកម្រជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គម្រាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ី ផុយស្រួយ។ ការចេញ ចូលតំបន់នេះ ត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិដែលមានភារកិច្ច និងអ្នកសិក្សាស្រាវជ្រាវ ផ្នែកវិទ្យាសាស្ត្រធម្មជាតិ ក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថាន ដែលត្រូវមានការអនុញ្ញាតជាមុនសិនពីក្រសួងបរិស្ថានលើកលែងតែក្នុងវិស័យ សន្តិសុខ និងការពារជាតិ។

**២-តំបន់អភិរក្ស:** ជាតំបន់គ្រប់គ្រងស្ថិតនៅជាប់នឹងតំបន់ស្នូល ដែលមានតម្លៃខាងការ អភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីតំបន់ទីជម្រាលនិងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។ ការចេញចូលតំបន់នេះ ត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអ្នកអភិរក្ស

ធម្មជាតិនៅនឹងកន្លែងលើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ។ ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះ សម្រាប់ជីវភាពសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលមិនប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យហ្មត់ចត់បំផុតរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។

**៣-តំបន់ប្រើប្រាស់ដោយចីរភាព:** ជាតំបន់គ្រប់គ្រង ដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាអាចអនុញ្ញាតឱ្យមានការអភិវឌ្ឍនិងការវិនិយោគនៅក្នុងតំបន់នេះ តាមការស្នើសុំរបស់ក្រសួងបរិស្ថានក្រោយពីមានការពិគ្រោះយោបល់ពីបណ្តាលក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋានដោយអនុលោមតាមច្បាប់ និងនិតីវិធីជាធរមាន។

**៤-តំបន់សហគមន៍:** ជាតំបន់គ្រប់គ្រងបម្រើឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍ និងជនជាតិដើមភាគតិច ដែលមានសកម្មភាពស្រាប់ រួមមានលំនៅឋានស្រែ និងចំការ។

ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពី ក្រសួងបរិស្ថានដោយអនុលោមតាមច្បាប់ភូមិបាល។

តំបន់ការពារធម្មជាតិនេះ មិនគ្របដណ្តប់ទៅលើការកំណត់ និងការចាត់ចែងគ្រប់គ្រងរបស់អាជ្ញាធរអប្សរា និង អាជ្ញាធរដទៃទៀត ដែលរាជរដ្ឋាបាលប្រគល់ភារកិច្ចឱ្យ។

Draft

-<u>មាត្រា២២:</u> រដ្ឋទទួលស្គាល់ និងធានាសិទ្ធប្រើប្រាស់ជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់ជំនឿសាសនារបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ។ សិទ្ធិប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈ ប្រពៃណី ទំនៀមទម្លាប់ តាមតម្រូវការរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ជាលក្ខណៈគ្រួសារអាចប្រព្រឹត្តទៅបាននៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់អភិរក្ស ដោយអនុវត្តន៍ ទៅតាមគោលការណ៍ណែនាំ ដែលកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

-<u>មាត្រា៣៦:</u> ការកាប់គាស់ ការឈូសឆាយដីព្រៃក្នុងតំបន់ការពារធម្មជាតិដើម្បីស្ថាបនាអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ គ្រប់ប្រភេទ ដែលកាត់តាមតំបន់ស្នូល និងតំបន់អភិរក្សត្រូវហាមឃាត់។ ករណីនេះ អាចធ្វើទៅបានតែក្នុងតំបន់ប្រើប្រាស់ ដោយចីរភាព និងតំបន់សហគមន៍ដោយមានការសម្រេចពីរដ្ឋាភិបាលតាមការស្នើរបស់ក្រសួងបរិស្ថាន។

-<u>មាត្រា៣៩:</u> រាល់ការនាំចេញ ការនាំចូល ឬការដោះដូរ ដែលពុំមានលក្ខណៈពាណិជ្ជកម្ម នូវប្រភេទសត្វ រុក្ខជាតិ គ្រាប់ រុក្ខជាតិ ការបង្កាត់ពូជ និងសំណាករបស់ប្រភេទទាំងនោះ ដែលមានដើមកំណើតនៅក្នុងតំបន់ការពារធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសដទៃ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគវិនិច្ឆ័យ និងវាយតម្លៃឱ្យបានច្បាស់លាស់ពីរដ្ឋបាល ការពារ និងអភិរក្សធម្មជាតិ និងត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន។

-<u>មាត្រា៤០:</u> ហាមបង្កឱ្យភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិ។ ការប្រើប្រាស់ភ្លើង អាចអនុគ្រោះបានចំពោះរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដើម្បីផលប្រយោជន៍រុក្ខវប្បកម្ម ផ្លូវភ្លើង ឬអនាម័យព្រៃ។ ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់មានកាតព្វកិច្ចចូលរួមសហការក្នុងការថែរក្សា ការពារព្រៃឈើ ក្នុងការប្រយុទ្ធ ទប់ស្កាត់ភ្លើងឆេះព្រៃ។

**-មាត្រា៤១:** តំបន់ការពារធម្មជាតិនីមួយៗ ត្រូវការពារ និងទប់ស្កាត់នូវរាល់សកម្មភាព ដែលធ្វើឱ្យខូតខាត ឬ ប៉ះពាល់ អវិជ្ជមានក្នុងតំបន់ការពារធម្មជាតិ បណ្តាលមកពីការកាប់គាស់រុករាន ទន្ទ្រានដីព្រៃ ដោយរំលោភ ការធ្វើអាជីវកម្ម ការបំពុលមជ្ឈដ្ឋានធនធានជីវៈចម្រុះ ភ្លើងឆេះព្រៃ ការធ្វើកសិកម្ម ពនេចរ ការនាំចូលជម្ងឺសត្វល្អិតចង្រៃ និងប្រភេទរុក្ខជាតិ ឬសត្វរាតត្បាត។

សកម្មភាពដែលនាំឱ្យខូតខាត ឬ ប៉ះពាល់អវិជ្ជមាន ដែលត្រូវហាមឃាត់ក្នុងតំបន់ការពារធម្មជាតិមាន :

១- រំកិល ដកចេញ ឬ បំផ្លាញគោលសីមា ឬសញ្ញាសម្គាល់ព្រំប្រទល់តំបន់ការពារធម្មជាតិ

២- ប្រើសិទ្ធិប្រើប្រាស់ធនធានធម្មជាតិខុសពី សិទ្ធិដែលបានទទួលស្គាល់ ឬ បានអនុញ្ញាតដោយច្បាប់

៣- កាប់ ផ្តួល រំលំ គ្រៀវ កាប់បំផ្លាញដើមឈើ ឬ បំពុល ឬ គាស់រម្លើងគល់ឈើ

៤- ការចាប់ ប្រមាញ់ ប្រមូលពង កូនសត្វព្រៃ និងសត្វស្លាប តាមគ្រប់រូបភាព

៥- ការបំផ្លាញគុណភាពទឹកតាមគ្រប់រូបភាព ការដាក់ថ្នាំបំពុល ការប្រើសារធាតុគីមី ការចោលសំណល់រឹងរាវចូល ក្នុងទឹក ឬលើដី ការប្រើប្រាស់ឧបករណ៍ឆក់

៦- ការស្តុក ការទិញ និងការតាំងលក់សត្វព្រៃ សំណាកសត្វព្រៃគ្រប់ប្រភេទ

៧- ការបំផ្លាញវាលស្មៅធម្មជាតិ រុក្ខជាតិនានា និងទីជម្រកសត្វព្រៃ

៨- ការលែងសត្វពាហនៈ និងបណ្តើរឆ្កែប្រមាញ់

៩- ការនេសាទដែលផ្ទុយនឹង បទប្បញ្ញត្តិនៃច្បាប់ការធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ ទាំងក្នុងដែនសមុទ្រ និងដែន ទឹកសាបព្រៃលិចទឹកព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ

១០- ការបង្កើតមូលដ្ឋាននិងកែច្នៃខ្លឹមច័ន្ទន៍ ដើមម្រះព្រៅ វល្លិរមៀត ឬអនុផលព្រៃឈើផ្សេងទៀត និងការធ្វើវារីវប្បកម្មទឹកសាប ទឹកប្រៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់និងបច្ចេកទេសដែលនាំដល់ការបំពុល ឬបំផ្លាញមជ្ឈដ្ឋាន ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។

**-មាត្រា៤២:** ហាមឃាត់ការកែច្នៃផលអនុផលធនធានធម្មជាតិ ការបង្កើត និងដំណើការមូលដ្ឋានរោងអារជ្រៀកឈើ រោងចក្រកែច្នៃឈើសិប្បកម្មកែច្នៃផល អនុផលធនធានធម្មជាតិ និងឡគ្រប់ប្រភេទ ក្នុងតំបន់ការពារធម្មជាតិ។

**-មាត្រា៤៤:** ដើម្បីកាត់បន្ថយជាអតិបរមា នូវហេតុប៉ះពាល់បរិស្ថាន និងសង្គម និងសម្រេចឱ្យបាននូវគោលបំណងយុទ្ធសាស្ត្រ នៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ រាល់គម្រោងអភិវឌ្ឍ ឬវិនិយោគក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ក្រសួងបរិស្ថានត្រូវធ្វើការ សិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាមុនដោយសហការ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់គម្រោង ឬសកម្មភាពណាមួយ ត្រូវអនុលោមតាមបទប្បញ្ញត្តិ ទាំងឡាយ ដែលពាក់ព័ន្ធនិងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

**-មាត្រា៤៥:** បទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចរិតពិសេសដូចបានចែងក្នុងច្បាប់នេះ។ មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ បំពេញភារកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ និងជាភ្នាក់ងារនគរបាល យុត្តិធម៌ មានសមត្ថកិច្ចសើបអង្កេត ស្រាវជ្រាវ បង្ក្រាបទប់ស្កាត់បទល្មើសធនធានធម្មជាតិ នៅក្នុងវង្វង់ដែនសមត្ថកិច្ច របស់ខ្លួន និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិ ដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងជាភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវអនុវត្តន៍ស្របតាម ក្រមនីតិ វិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ បន្ទាប់ពីសាលក្រម ឬសាលដីកាចូលជាស្ថាពរ វត្ថុតាង ដែលបានរឹបអូសទុក ជាសម្បត្តិរដ្ឋត្រូវចាត់ចែង តាមនីតិវិធីដោយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន។

Draft

**-មាត្រា៥១:** មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានសមត្ថកិច្ចមានសិទ្ធិផ្អាកសកម្មភាពទាំងមូលឬមួយផ្នែកជា បណ្ដោះអាសន្នរបស់បុគ្គលណា ដែលប្រព្រឹត្តល្មើស និងបទប្បញ្ញត្តិ នៃច្បាប់នេះ ឬបំពានលើកិច្ចសន្យារហូតដល់ដំណោះ ស្រាយ នៃវិវាទ ត្រូវបានបញ្ចប់។

**-មាត្រា៥៣:** ទណ្ឌកម្ម នៃបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិមាន ទោសដាក់ពន្ធនាគារ ទោសពិន័យ ដោយតុលាការ ពិន័យអន្តរការណ៍ រឹបអូសវត្ថុតាង ជួសជុលស្តារការខូតខាត ព្រមាន ព្យួរដកហូតលិខិតអនុញ្ញាត ឬលុបកិច្ចសន្យា។ ការព្យួរ ការដកហូតលិខិតអនុញ្ញាត ឬការលុបកិច្ចសន្យាជាសិទ្ធិរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។ ការពិន័យអន្តរការណ៍លើបទល្មើសធនធានធម្មជាតិ ការជួសជុលស្តារការខូចខាត និងការព្រមានជាសមត្ថកិច្ចរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ឬធ្វើការជួសជុលស្តារការខូចខាត មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវកសាងសំណុំរឿងបទល្មើសបញ្ជូនទៅតុលាការ។ ការរឹបអូស វត្ថុតាងជាសមត្ថកិច្ចរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ឬ តុលាការអាស្រ័យទៅតាមករណីនីមួយៗ ដែល បានកំណត់ក្នុងច្បាប់នេះ។

**-មាត្រា៦០:** ត្រូវផ្តន្ទាទោសជាបទល្មើសធនធានធម្មជាតិថ្នាក់ទី២ និងត្រូវរឹបអូសវត្ថុតាងជាសម្បត្តិរដ្ឋ ចំពោះជន ដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១- ប្រើប្រាស់សារធាតុពុលគ្រប់ប្រភេទ ដែលធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ

២- ធ្វេសប្រហែសបង្កឱ្យមានភ្លើងឆេះព្រៃ

៣- យាយី បំផ្លាញជម្រកពង កូនកន្លែងបន្តពូជសត្វព្រៃ និងមច្ឆជាតិ

៤- កាប់បំផ្លាញរុក្ខជាតិក្នុងតំបន់ស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ

៥- ប្រើប្រាស់ឧបករណ៍នានា ដែលបង្ករការរំខានដោយសម្លេង រំញ័រ រលក និងផ្សែង

៦- លាក់បាំង ធ្វើឱ្យបាត់បង់ ឬធ្វើឱ្យខូចខាតវត្ថុតាងនៃបទល្មើស

៧- ប្រមូលផ្លែឈើព្រៃ តាមវិធីកាប់រំលំដើម

៨- កម្ទេច ផ្លាស់ប្តូរ លុបបំបាត់ ឬធ្វើឱ្យខូចខាតផ្លាកសញ្ញាគ្រប់ប្រភេទ

៩- បោះបង្គោលហ៊ុមព័ទ្ធ ដាក់សញ្ញាសម្គាល់ ក្នុងគោលបំណងកាន់កាប់ជាកម្មសិទ្ធ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទា ទោសទ្វេដង។

**-មាត្រា៦១:** ត្រូវផ្តន្ទាទោស ជាបទល្មើសធនធានធម្មជាតិថ្នាក់ទី៣ និងរឹបអូសវត្ថុតាងជាសម្បត្តិរដ្ឋ ចំពោះជន ដែល បានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម ÷

១- ធ្វើឱ្យខូចខាត ឬប្រែប្រួលសភាពដើម រំកិល ឬបង្ខិតបង្គោលព្រំប្រទល់ និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់គ្រប់គ្រង តំបន់ការពារធម្មជាតិ

២- ការបង្កើតមូលដ្ឋានកែច្នៃផល អនុផលធនធានធម្មជាតិគ្រប់ប្រភេទ

៣- កែច្នៃខ្លឹមច័ន្ទន៍ ម្រះព្រៅ វល្លិ៍រមៀត និងចម្រាញ់រុក្ខជាតិផ្សេងទៀត

៤- កាប់ គ្រៀវ ចង រឹត គាស់រម្លើង កាប់រំលំ ប្រមូល បំផ្លាញ រុករាន និងធ្វើសន្និធិរុក្ខជាតិដែលរងគ្រោះថ្នាក់ ឬមានដោយកម្រ និងជិតផុតពូជ ដែលបានកំណត់ដោយប្រកាសក្រសួងបរិស្ថាន

៥- ចាប់ដោយដាប់អន្ទាក់ ខ្នារ អង្គប់ បន្ទឹង លប់ ដោយបង្កៃ ឬដោយប្រមាញ់ ដែលធ្វើឱ្យរបួសបំពុល សម្លាប់ នាំចេញ ប្រមូលពង និងកូនសត្វព្រៃ គ្រប់ប្រភេទ ដែលកំពុងរងគ្រោះថ្នាក់មានដោយកម្រ និងជិតផុតពូជ ដែលបានកំណត់ ដោយប្រកាសក្រសួងបរិស្ថាន

៦- ប្រើប្រាស់អាវុធជាតិផ្ទុះ ជាតិគីមី ថ្នាំពុល គ្រឿងឆក់ ធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិ

Draft

៧- រារាំង បង្កគ្រោះថ្នាក់ របួសស្នាម ដល់មន្ត្រីរដ្ឋបាលការពារ និងអភិរក្ស ធម្មជាតិ ក្នុងការចុះអនុវត្តមុខនាទី និង ភារកិច្ចរបស់ខ្លួន

៨- ក្លែងបន្លំដោយប្រើប្រាស់ ឯកសណ្ឋាន ផ្លាកសញ្ញាសម្គាល់ ឬឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលការពារ និង អភិរក្ស ធម្មជាតិ ដើម្បីធ្វើសកម្មភាពល្មើស

៩- ក្លែងបន្លំលិខិតបទដ្ឋានរបស់ស្ថាប័នមានសមត្ថកិច្ច ដើម្បីធ្វើសកម្មភាពល្មើស

១០- បំផ្លិតបំផ្លាញបង្គោលព្រំប្រទល់ ស្ពាន លូ ផ្លូវ អាគារ ទីស្នាក់ការ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ ក្នុងករណីមិន រាងចាលត្រូវទទួលផ្តន្ទាទោសទ្វេដង។

## ៣.៣. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ ១៩៩៦

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦។ ច្បាប់នេះមានគោលដៅ:

- ការពារលើកកំពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋ ដោយធ្វើការទប់ស្កាត់ការកាត់បន្ថយ និងការត្រួតពិនិត្យ ការបំពុល។
- វាយតម្លៃហេតុប៉ះពាល់បរិស្ថានមុន នឹងចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គម្រោង ដែលបានស្នើឡើង។
- ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា។
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។
- បង្ក្រាបអំពើទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន។

ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិច្បាប់នេះ បានតម្រូវឱ្យបណ្តាក្រុមហ៊ុនទាំងអស់ ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA)។ ផ្អែកលើច្បាប់នេះបានចែងនៅក្នុងមាត្រាទី៦ និង៧ នៃជំពូកទី៣ ដូចតទៅៈ

**-មាត្រា៦:** ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តន៍លើគម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថាន មុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច។

ការវាយតម្លៃនេះត្រូវអនុវត្តន៍ផងដែរ ចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការហើយ ដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។ បែបបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើ របស់ក្រសួងបរិស្ថាន។ ប្រភេទ និងទំហំគម្រោង និងសកម្មភាពដែលបានស្នើឡើងព្រមទាំងសកម្មភាព ដែលមានស្រាប់ និងកំពុងដំណើរការ ទាំងឯកជន និងសាធារណៈ ដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើ របស់ក្រសួងបរិស្ថាន ។

**-មាត្រា៧:** ចំពោះរាល់ពាក្យសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើ (IEIA) ឬ (EIA) ទៅអង្គការមានសមត្ថកិច្ចក្នុងរយៈពេល ដូចបានកំណត់ក្នុងច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

Draft

## ៣.៤. ច្បាប់ស្តីពី ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ២០១១

ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គ លើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី១ ហើយដែលមានមាត្រាពាក់ព័ន្ធនិងគម្រោងដូចតទៅ:

-មាត្រា២: ធនធានរ៉ែទាំងអស់ដែលស្ថិតនៅក្នុងដី លើដី ឬក្រោមដីនៃដែនគោក ភ្នំ ខ្ពង់រាប ដែនទឹក ដែនសមុទ្រក្នុងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ជាសម្បត្តិរដ្ឋ។

-មាត្រា៣: ធនធានរ៉ែគឺជាសារធាតុទាំងឡាយណា ទោះជាក្នុងទម្រង់រឹង រាវ ឧស្ម័ន ដែលកកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផល នៃការជីកយកពី ក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ត្បូងថ្ម ត្បូងថ្ម រ៉ែអលោហៈ ទឹកខនិជ ថ្ម ក្រួស ខ្សាច់ ដីឥដ្ឋ ប្រេងកាត និងឧស្ម័ន។

ប្រតិបត្តិការធនធានរ៉ែ គឺជាការធ្វើសកម្មភាពបុរេសនាស្វែងរក និងអាជីវកម្មធនធានរ៉ែ។

បុរេសនា គឺជាការស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ហើយមានការប៉ះពាល់បន្តិចបន្តួច ដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែ ដែលមានតម្លៃពាណិជ្ជកម្ម និងអាចជាទិសដៅសម្រាប់ការស្នើសុំអាជ្ញាប័ណ្ណស្វែងរុករក និងអាជីវកម្មធនធានរ៉ែ។

ការស្វែងរុករក គឺជាការសិក្សាស្រាវជ្រាវក្នុងបំណងរកឱ្យឃើញ ធ្វើតេស្តសន្និស្សន៍រ៉ែ ដើម្បីកំណត់សក្តានុពល ទំហំ គុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ចអាជីវកម្ម តាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត។

អាជីវកម្មធនធានរ៉ែ គឺជាប្រតិបត្តិការជីកយកធនធានរ៉ែ ដែលនៅក្នុងនោះធនធានរ៉ែ ត្រូវបានយកចេញពីជម្រករ៉ែ ធ្វើប្រព្រឹត្តិកម្មដឹកជញ្ជូន លក់ដូរ ឬការនាំចេញ ការនាំចូលក្នុងគោលបំណងពាណិជ្ជកម្ម។ ដោយឡែកការលក់ដូរ ការនាំចេញ ការនាំចូលលោហៈធាតុមានតម្លៃ ត្បូងថ្មមានតម្លៃ ដែលមិនទាន់ច្នៃ និងកែច្នៃរួចហើយ ត្រូវស្ថិតនៅក្រោមបញ្ញត្តិច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

-មាត្រា៥: គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាអាចធ្វើការស្វែងរក រុករក ឬធ្វើអាជីវកម្មធនធានរ៉ែ ដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ដែលចេញដោយស្ថាប័នមានសមត្ថកិច្ចបានឡើយ លើកលែងតែម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ស្របច្បាប់លើដីធ្លី ដែលជាឯកជនអាចប្រើប្រាស់ក្រួស ខ្សាច់ ថ្ម ដីឥដ្ឋ ដោយមិនចាំបាច់មានអាជ្ញាប័ណ្ណ តែមិនអនុញ្ញាតឱ្យដឹកជញ្ជូនចេញផុតពីព្រំដែនដីធ្លី ជាកម្មសិទ្ធិ ដើម្បីធ្វើអាជីវកម្មនោះទេ។

ប្រជាពលរដ្ឋខ្មែរអាចធ្វើបុរេសនានៅលើដីរបស់រដ្ឋ បានឱ្យតែដីនោះរដ្ឋមិនទាន់ចេញអាជ្ញាប័ណ្ណធនធានរ៉ែទៅបុគ្គលដទៃ។

-មាត្រា១១: អាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានរៀបចំជាប្រាំមួយប្រភេទ ដើម្បីសម្រួលដល់អ្នកដាក់ពាក្យសុំក្នុងគោលដៅសម្រួលការគ្រប់គ្រងលើការងារស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែ នៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានប្រសិទ្ធិភាព។

Draft

**២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម** អាចផ្តល់ឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលដែលមានលក្ខណៈសម្បត្តិ និងសម្ថភាពគ្រប់គ្រាន់ ក្នុងបំណងអនុវត្តន៍ការងារស្វែងរុករក ធ្វើអាជីវកម្មធនធានរ៉ែសំណង់ និងធនធានរ៉ែឧស្សហាកម្ម ណាមួយបម្រើឱ្យការសាងសង់ឧស្សាហកម្មគីមី ឧស្សាហកម្មកែច្នៃ ហើយជីកយក អណ្តូងរ៉ែបើក ឬការដ្ឋានវាយថ្ម។ ធនធានរ៉ែសំណង់ និងធនធានរ៉ែឧស្សាហកម្មមានជាអាទិ៍ខ្សាច់ ក្រួស ថ្មសំណង់ ឡាតេរីត ដីឥដ្ឋ ដីឥដ្ឋធ្វើស៊ីម៉ងត៍ ផូសីលផ្កាថ្ម ហ្វូស្វរីត ថ្មកំបោរ ដូឡូមីត ថ្មម៉ាប កៅឡាំង ប៉ាហ្គោឌីត អំបិល ប៉ូតាស ម្នាងសិលា ត្បូងភក់ ត្បូងថ្ម ខ្សាច់ទីតាន ខ្សាច់ស៊ីលីស ឬសមាសធាតុធនធានរ៉ែផ្សេងទៀត ដែលប្រើប្រាសក្នុងគោលដៅដូចគ្នា។

**៥- អាជ្ញាប័ណ្ណស្វែងរុករក** អាចផ្តល់ឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានលក្ខណសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើការស្វែងរុករក និងសិក្សាអំពីសក្តានុពលធនធានរ៉ែ។

**មាត្រា១៨:** អាជ្ញាប័ណ្ណធនធានរ៉ែ ក្រោមអំណាចនៃច្បាប់នេះ អាចព្យួរ ឬលុបចោលចំពោះសម្បទានិកណាដែលបំពានច្បាប់នេះ។

នីតិវិធីនៃការព្យួរទុក ការដកហូតអាជ្ញាប័ណ្ណត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២១:** សម្បទានិកឬអ្នកចុះកិច្ចសន្យាបន្តនីមួយៗត្រូវទទួលខុសត្រូវលើការដឹកនាំប្រតិបត្តិការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែ នឹងត្រូវអនុវត្តន៍ទៅតាមការកំណត់ដូចខាងក្រោមនេះ ៖

១- ដំណើរប្រតិបត្តិការឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពតាមលក្ខណៈបច្ចេកទេស និងហិរញ្ញវត្ថុដែលនឹងលម្អិតក្នុងកម្មវិធីការងារស្វែងរុករក ឬការសិក្សាអំពីសមិទ្ធិភាពអណ្តូងរ៉ែ។

២- ការពារបរិស្ថាន ដូចមានលម្អិតក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធានធានធម្មជាតិ ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការលុបអណ្តូងរ៉ែ និងការធានាផ្នែកហិរញ្ញវត្ថុ។

៣- ធានាការការពារសុខភាព និងសុវត្ថិភាពពលករ ដែលនឹងលម្អិតក្នុងកម្មវិធីផែនការអណ្តូងរ៉ែ កម្មវិធីសុខភាព និងសុវត្ថិភាពក្នុងអណ្តូងរ៉ែរាប់បញ្ចូលទាំងការការពារគ្រោះថ្នាក់ បែបបទរាយការណ៍ស្តីពី គ្រោះថ្នាក់នេះ។

៤- ការពារសុវត្ថិភាពដល់សាធារណជននៅក្នុង និងជុំវិញតំបន់អណ្តូងរ៉ែ ដែលនឹងលម្អិតក្នុងផែនការអណ្តូងរ៉ែ។

៥- ធ្វើការអប់រំ បណ្តុះបណ្តាល និងផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរ ដែលនឹងលម្អិតក្នុងកម្មវិធីផ្តល់ការងារអប់រំ បណ្តុះបណ្តាល។

៦- ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវទំនិញ និងសេវាកម្មក្នុងព្រះរាជាណាចក្រកម្ពុជា នៅតាមកន្លែង និងពេលវេលាសមស្រប។

## ៣.៥. ច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ ២០១០

ច្បាប់ស្តីពីអស្សាមិករណ៍ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាល ទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យ ធម្មនុញ្ញភាព និងបានប្រកាសថា ស្របតាមសេចក្តីសម្រេចលេខ ១០៨/០១១/២០១០កបធម ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០១០ដែលមានមាត្រាពាក់ព័ន្ធ និងគម្រោងដូចតទៅ៖

Draft

-មាត្រា១: ច្បាប់នេះមានគោលដៅកំណត់ ពីអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយកំណត់ពី គោលការណ៍ យន្តការ នីតិវិធីអស្សាមិករណ៍ និងសំណងឱ្យបានសមរម្យ និងយុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ និង គម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការអភិវឌ្ឍ របស់ព្រះរាជាណាចក្រកម្ពុជា។

-មាត្រា២: ច្បាប់នេះមានគោលបំណងជាអាទិ៍ៈ

- ធានាការដកសិទ្ធស្របច្បាប់ លើកម្មសិទ្ធិឯកជនដោយសមរម្យ និងយុត្តិធម៌
- ធានាការទូទាត់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌
- បម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ
- ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

-មាត្រា៧: មានតែរដ្ឋទេ ដែលជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។

អស្សមិករណ៍អាចអនុវត្តន៍ទៅបាន លុះត្រាតែយកទៅអនុវត្តន៍គម្រោងដូចមានចែងក្នុងមាត្រា៥ នៃច្បាប់នេះ។

-មាត្រា៩: អចលវត្ថុដែលត្រូវដកហូតនេះ ត្រូវប្រើប្រាស់សម្រាប់តែក្នុងគោលដៅ ដែលបានគ្រោងទុកនៅក្នុង ប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដើម្បីប្រយោជន៍សាធារណៈ ឬតម្រូវនៃប្រយោជន៍ជាតិប៉ុណ្ណោះ និងមិនអាចឱ្យទុកនៅចោលទំនេរដោយគ្មានហេតុផលសមស្រប ឬផ្ទេរឱ្យតតិយជនណាម្នាក់ ក្នុង គោលដៅបំរើផលប្រយោជន៍ឯកជន។

អចលវត្ថុដែលនៅសល់ពីតម្រូវការប្រើប្រាស់ ត្រូវផ្តល់អាទិភាពលក់ជូនម្ចាស់អចលវត្ថុ និង/ឬម្ចាស់ សិទ្ធិតាមអត្រាតម្លៃនៃការទូទាត់សំណង។ ក្នុងករណីដែលម្ចាស់អចលវត្ថុ និង/ឬម្ចាស់សិទ្ធិមិន ព្រមទទួលយកអចលវត្ថុ ដែលនៅសល់ពីតម្រូវការប្រើប្រាស់វិញទេ ត្រូវរក្សាទុកអចលវត្ថុនោះជា ទ្រព្យសម្បត្តិរដ្ឋ។

-មាត្រា១១: មុននឹងដំណើរការការងារអស្សាមិនករណ៍ រដ្ឋាភិបាលត្រូវគ្រោងថវិកាប្រចាំឆ្នាំ ឱ្យបានគ្រប់គ្រាន់ ហើយត្រូវផ្តល់ឥណទានឱ្យគ្រប់ចំនួន និងទាន់ពេលវេលាជូនគណៈកម្មាធិការអស្សាមិនករណ៍ តាមសំណើររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់យកទៅទូរទាត់សំណងជូនម្ចាស់អចលវត្ថុ និង/ឬម្ចាស់សិទ្ធិដែលទទួលរងផលប៉ះពាល់ដោយសារអស្សាមិករណ៍។

## ៣.៦. ច្បាប់ស្តីពីទេសចរណ៍ ឆ្នាំ ២០០៩

ច្បាប់ ស្តីពី ទេសចរណ៍ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០៩ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ:

- មាត្រា ១: ច្បាប់នេះមានគោលដៅកំណត់វិធាន និង យន្តការសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា។

Draft

- **មាត្រា ២:** ច្បាប់នេះមានគោលបំណងដូចតទៅ:
  - គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទេសចរណ៍ ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ
  - រួមចំណែកការពារ និងថែរក្សាធនធានធម្មជាតិ វប្បធម៌ និង ទំនៀមទម្លាប់ ដែលជាមូលដ្ឋានបម្រើឱ្យវិស័យទេសចរណ៍
  - ធានា និងលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតប្រព័ន្ធធានាគុណភាព ដោយផ្តល់សន្តិសុខ សុវត្ថិភាព ផាសុខភាពនិងបង្កើនការពេញចិត្តដល់ទេសចរណ៍
  - ទាញយកផលប្រយោជន៍ក្នុងវិស័យទេសចរណ៍ ឱ្យបានជាអតិបរមា ធានាការបែងចែកប្រកបដោយសមធម៌ និង ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាន នៃវិស័យទេសចរណ៍
  - លើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយ រកទីផ្សារ និងជំរុញការផ្សព្វផ្សាយទេសចរណ៍កម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ដោយមានការចូលរួមពីផ្នែកសាធារណៈ និង ផ្នែកឯកជន
  - អភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍
  - រួមចំណែកកសាងមិត្តភាព និង ការយោគយល់ជាអន្តរជាតិតាមរយៈឧស្សាហកម្មទេសចរណ៍។
- **មាត្រា ៣:** ច្បាប់នេះ មានវិសាលភាពគ្រប់គ្រង និងគ្របដណ្តប់លើរាល់សកម្មភាពទេសចរណ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- **មាត្រា ១១:** ក្រសួងទេសចរណ៍ត្រូវមានការទទួលខុសត្រូវ រួមគ្នាជាមួយក្រសួង ស្ថាប័ន និង អាជ្ញាធរពាក់ព័ន្ធដទៃទៀត ក្នុងការចេញបទប្បញ្ញត្តិសំខាន់ៗ ដែលប៉ះពាល់ទៅលើ ឬទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍។ ផ្នែកសំខាន់ៗទាំងនោះរួមមាន:
  - សមាគមន៍ឧស្សាហកម្មទេសចរណ៍
  - ការការពារបរិស្ថាន
  - ការការពារ និងការបង្ការពីមរតកធម្មជាតិ
  - ការការពារ និង ការបង្ការពីមរតកវប្បធម៌
  - ការវិនិយោគវិស័យទេសចរណ៍ និងការលើកទឹកចិត្ត
  - ការគ្រប់គ្រង និងឯកជនភាវូបនីយកម្ម នៃសហគ្រាសទេសចរណ៍របស់រដ្ឋ
  - ការគ្រប់គ្រងដីធ្លីរបស់រដ្ឋ ដែលបានជូលសម្រាប់គោលបំណងទេសចរណ៍
  - ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ
  - ការអភិវឌ្ឍផលិតផលទេសចរណ៍
  - អេកូទេសចរណ៍
  - សហគមន៍ទេសចរណ៍មូលដ្ឋាន
  - ការកាត់បន្ថយភាពក្រីក្រ
  - អនាម័យ និងសុវត្ថិភាពចំណីអាហារ
  - សន្តិសុខ និងសុវត្ថិភាពទេសចរណ៍
  - នគរបាលទេសចរណ៍។

ក្រសួងទេសចរណ៍ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ត្រូវសហការគ្នា ដើម្បីធានាថាផ្នែកនានានៅក្នុងឧស្សាហកម្មទេសចរណ៍ត្រូវបានចាត់ចែង និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងឆ្លើយតបទៅតាមផែនការអភិវឌ្ឍទេសចរណ៍។

Draft

**មាត្រា ១២:** ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដែលការងាររបស់ខ្លួនប៉ះពាល់ទៅដល់ឧស្សាហកម្មទេសចរណ៍និង ផែនការអភិវឌ្ឍទេសចរណ៍ ត្រូវពិគ្រោះយោបល់ផ្នែកជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍។ ផ្នែកដែលប៉ះពាល់ទៅលើ ឬ ទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍អាចរួមមាន:

- ផែនការប្រើប្រាស់ដីធ្លី
- ផែនការរូបវន្ត និងផែនការអភិវឌ្ឍ
- ហេដ្ឋារចនាសម្ព័ននិងសេវាសាធារណៈ
- ការផ្តល់ឱ្យភាពជាម្ចាស់កម្មសិទ្ធិ ភតិសន្យា ឬ សម្បទានសម្រាប់គោលបំណងទេសចរណ៍
- ការកសាងគោលនយោបាយពន្ធដារលើអាជីវកម្មទេចរណ៍
- ទិដ្ឋាការ
- គោលនយោបាយអាកាសចរណ៍។

ដើម្បីធានាការអនុវត្តឱ្យមានប្រសិទ្ធិភាព រាល់គម្រោងសាងសង់សំណង់បម្រើឱ្យ សកម្មភាពទេសចរណ៍ ត្រូវធ្វើឡើងឱ្យស្របតាមផែនការអភិវឌ្ឍទេសចរណ៍ និងត្រូវមានការជួយយោបល់ផ្នែកជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍។

ក្រសួងទេសចរណ៍ ជួយផ្តល់ដំបូន្មានបច្ចេកទេសទៅដល់គណៈកម្មការគ្រប់គ្រង់ និងអភិវឌ្ឍន៍ទេសចរណ៍រាជធានីខេត្ត និងថ្នាក់មូលដ្ឋាន ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារផ្សព្វផ្សាយទេសចរណ៍កម្ពុជា សមាគមឧស្សាហកម្មទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍។

- **មាត្រា ២១:** ហិរញ្ញប្បទានទ្រទ្រង់ការអភិវឌ្ឍ និងគ្រប់គ្រងវិស័យទេសចរណ៍បានមកពី:
  - ថវិកាជាតិប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍
  - ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍នានា
  - ការបរិច្ចាគរបស់សប្បុរសជន អតិថិជន និងសមាគមឧស្សាហកម្មទេសចរណ៍
  - ការបរិច្ចាគរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា
  - ការបរិច្ចាគរបស់ប្រតិបត្តិករទេសចរណ៍
  - ប្រភពហិរញ្ញប្បទាន ឬចំណូលស្របច្បាប់ផ្សេងៗទៀត។

ការគ្រប់គ្រង និងការប្រើប្រាស់ថវិការសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៣.៧ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ច្បាប់នេះត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភា លើកទី៦ និតិកាលទី ៣ និងព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិ នៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ ហើយបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០០៧ មាត្រា ដែលមានពាក់ព័ន្ធនឹងគម្រោងមានដូចតទៅ:

-មាត្រា១: ច្បាប់នេះ មានគោលដៅជំរុញឱ្យមានការគ្រប់គ្រងធនធានទឹក ប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចបាននូវការងារអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

ច្បាប់នេះកំណត់:

- សិទ្ធិ និងភាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក

Draft

- គោលការណ៍គ្រឹះសំខាន់ៗ សម្រាប់ការគ្រប់គ្រងធនធានទឹក
- ការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹកក្នុងការអភិវឌ្ឍធនធានទឹកប្រកបដោយនិរន្តរភាព។

-មាត្រា២: ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានន័យថា៖

- ទឹក គឺទឹកលើដី ទឹកក្រោមដី និងទឹកក្នុងអាកាស។
- ធនធានទឹក គឺសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងជងអូរ បឹងបួ ត្រពាំង ថ្លុក អាងទឹក។
- ទឹកក្រោមដី គឺទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូច ធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។
- ល្អាងទឹកក្រោមដី គឺទឹកក្រោមដីដែលស្ថិតនៅជាអចិន្ត្រៃយ៍ក្នុងល្អាងធម្មជាតិក្រោមដី។
- អាងទន្លេ គឺតំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាល នៃប្រព័ន្ធទឹកហូរ ដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។
- អាងទន្លេរង គឺផ្នែកមួយនៃអាងទន្លេ។
- ទន្លេអន្តរជាតិ គឺទន្លេ ដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹកដីប្រទេសចាប់ពីពីរឡើងទៅ។
- ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួរ និងអាងទឹក គឺចំណែកដីដែលធម្មតាលិច ដោយទឹកនៅក្នុង ទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬអង្គធាតុដទៃទៀត ដែលជាប់នៅនឹងច្រាំងនោះ ដោយមិនរាប់បញ្ចូលនូវដី ថ្ម ឬអង្គធាតុដទៃទៀតដែលនៅឆ្ងាយពីច្រាំង និងលិចទឹកម្ដងម្កាលនោះទេ។
- ឆ្នេរ សមុទ្រ ទន្លេ ស្ទឹង គឺចំណែកដី ឬខ្សាច់ ដែលមានសណ្ឋានជម្រាល និងលិចទឹកម្ដងម្កាល។
- បាតទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួរ និងអាងទឹក គឺផ្នែកមួយនៃដីដែលកំណត់ដោយច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួរ និងអាងទឹកដែលគ្របដណ្ដប់ដោយទឹក។
- តម្រូវការសាធារណៈ គឺការផ្គត់ផ្គង់ទឹកនៅតាមទីក្រុង និងជនបទ ការផលិតស្បៀង ការផលិតថាមពលវារីអគ្គិសនី ការបំរើវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យនាវាចរ និងការរក្សាឱ្យមានធារទឹកអប្បបរមា ដើម្បីថែរក្សាបរិស្ថាន ជីវិតមនុស្ស ជីវិតមច្ឆជាតិ និងរុក្ខជាតិនានា។
- ការងារទឹក គឺសំណង់ទំនប់ធំ តូច ទំនប់បង្ហៀរ ទំនប់បញ្ចាល់ទឹក ទំនប់ការពារទឹកជំនន់ ប្រឡាយដោះ ទឹកធំ តូច ប្រព័ន្ធស្រោចស្រព អាងទឹកធំតូច ប្រឡាយនាំទឹក អណ្ដូងទឹកគ្រប់ប្រភេទ និងសំណង់ដទៃទៀត ដែលបានសាងសង់ក្នុងគោលបំណងបង្វែរទឹក រក្សាទឹកទុក នាំទឹកយកទឹកប្រើប្រាស់ អភិរក្ស ការពារធនធានទឹក ដោះទឹកចេញពីតំបន់ដីលិចទឹក ការពារកាត់បន្ថយនូវឥទ្ធិពលទឹកជំនន់ និងសង្គ្រោះបន្ទាន់ផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងទឹក។
- អាជ្ញាប័ណ្ណទឹក គឺប័ណ្ណដែលផ្ដល់សិទ្ធិប្រើប្រាស់ទឹក និងធនធានទឹកឱ្យដល់បុគ្គលគ្រប់រូប ដើម្បីធ្វើអាជីវកម្ម និងអភិវឌ្ឍន៍។
- បុគ្គល គឺរូបវន្តបុគ្គល ឬនិតិបុគ្គល ទោះក្នុងន័យជាឯកជន ឬសាធារណៈក៏ដោយ។

-មាត្រា៣: ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ។

-មាត្រា៤: ទឹក និងធនធានទឹកត្រូវបានគ្រប់គ្រង និងអភិវឌ្ឍន៍ដោយផ្អែកទៅលើវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះ។

Draft

វិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះនេះ និងពិចារណាទៅលើ:

- គ្រប់ទិដ្ឋភាពទាំងអស់នៃធានធនទឹក
- ទំនាក់ទំនងរវាងធនធានទឹក និងទិដ្ឋភាពដទៃទៀតនៃបរិស្ថានធម្មជាតិ
- តម្រូវការប្រើប្រាស់ទឹកសម្រាប់មនុស្ស បរិស្ថាន និងវិស័យផ្សេងទៀត ដើម្បីឱ្យមាននិរន្តរភាព និង ប្រសិទ្ធភាព។

ការអនុវត្តវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះត្រូវធ្វើក្នុងពេលតែមួយ និងក្នុងក្របខណ្ឌសហប្រតិបត្តិការរវាងរាល់ស្ថាប័នពាក់ព័ន្ធ។

**-មាត្រា៥:** ក្រសួងធនធានទឹក និងឧតុនិយមមានភារកិច្ចគ្រប់គ្រង ដឹកនាំ និងត្រួតពិនិត្យក្នុងការអនុវត្តច្បាប់នេះ។ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយនឹងក្រសួងពាក់ព័ន្ធនានាក្នុងករណីចាំបាច់រាជរដ្ឋាភិបាលអាច នឹងបង្កើតគណៈកម្មការចំរុះចំពោះមុខ ដើម្បីដោះស្រាយ និងសំរបសំរួលការងាររវាងបណ្ដាក្រសួងពាក់ព័ន្ធ។

**-មាត្រា១១:** បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយ មិនលើសពីសេចក្ដីត្រូវការចាំបាច់ជាមូលដ្ឋាន សម្រាប់ការហូបចុក បោកគក់ ងូត និងតម្រូវការផ្សេងទៀត រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រព សួនច្បារ និងដំណាំ ដោយជៀសវាងមិនឱ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។ តម្រូវការខាងលើ នេះមិនតម្រូវឱ្យសុំអាជ្ញាប័ណ្ណទឹកឡើយ។

**-មាត្រា១២:** ការបង្វែរទឹក ការយកទឹកការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្ម លើសពីកម្រិត ដែលមានចែងក្នុងមាត្រា១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត។ បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ។

ការយកខ្សាច់ ដី ឬគ្រួស ប្រេងកាត និងឧស្ម័នពីបាតច្រាំង ឆ្នេរសមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួរ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក។ បែបបទបច្ចេកទេសជលសាស្ត្រ ដែលពាក់ព័ន្ធនឹងការងារនេះ នឹងមានចែងលម្អិតនៅក្នុងអនុក្រឹត្យ។

ការលុបទន្លេ ស្ទឹង ព្រែក អូរ បឹងបួរ ប្រឡាយ អាងទឹក និងអាងធម្មជាតិ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ។

ការសាងសង់ស្ពានតូច ធំកាត់ទន្លេ ស្ទឹង កំពង់ផែ ឬសំណង់អាគារតូច ធំលើច្រាំង និងឆ្នេរ តម្រូវឱ្យមានការឯកភាព ផ្នែកបច្ចេកទេសជលសាស្ត្រជាមុន ពីក្រសួងធនធានទឹក និងឧតុនិយម។

ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការអនុញ្ញាត និងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជាដោយមានការអនុម័តយល់ព្រមពីស្ថាប័ននីតិបញ្ញត្តិ។

**-មាត្រា១៤:** មុនពេលផ្ដល់អាជ្ញាប័ណ្ណទឹកដល់បុគ្គលណាមួយ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើការប្រើប្រាស់ទឹក និងការសាងសង់សំណង់ការងារទឹក ដែលបុគ្គលនោះស្នើឡើង។

**-មាត្រា២២:** រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពុល ដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិ ត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការអនុញ្ញាត។

Draft

ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដាបច្ចេកទេស នៃការបញ្ចេញទឹកសំណល់ នឹងមានកំណត់ដោយអនុក្រឹត្យ។ រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

**-មាត្រា២៣:** ក្រសួងធនធានទឹក និងឧតុនិយម អាចប្រកាសទុកជាតំបន់អាសន្ន ឬជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹកក្នុងករណីដែល ៖

- ទឹកលើដី ឬទឹកក្រោមដីត្រូវបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬគុល្យភាពអេកូឡូស៊ី
- ទឹកលើទីជម្រាល ដែលកំពុងរងការគំរាមកំហែងដោយសកម្មភាពមនុស្ស ឬធម្មជាតិ
- ទឹកដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ។

ដែនភូមិសាស្ត្រនៃតំបន់អាសន្ន ឬតំបន់ហាមឃាត់នោះ ត្រូវកំណត់តាមករណីនីមួយៗ ដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម។

**-មាត្រា៣២:** រាល់វិវាទ ដែលពាក់ព័ន្ធការបង្កើត និងដំណើរការសេវភាពក្នុងការប្រើប្រាស់ទឹកត្រូវសម្រួលដោះស្រាយ ដោយក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

**-មាត្រា៣៥:** រាជរដ្ឋាភិបាលអាចផ្តល់រង្វាន់លើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗដល់បុគ្គលទាំងឡាយដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ ការបង្កើតបច្ចេកវិទ្យាថ្មីៗ ឬការដំឡើងឧបករណ៍ទំនើបដែលជួយកាត់បន្ថយកាកសំណល់ និងជួយបង្កើនគុណភាពទឹក ដើម្បីឱ្យការប្រើប្រាស់ទឹកមានប្រសិទ្ធិភាពខ្ពស់។

លក្ខណៈវិនិច្ឆ័យ និងបែបបទសម្រាប់ការផ្តល់រង្វាន់លើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

## ៣.៨. ច្បាប់ស្តីជលផល ឆ្នាំ ២០០៦

ច្បាប់ស្តីពីជលផល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០០៦ នាសម័យប្រជុំសភាលើកទី ៤ នីតិកាលទី៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់ នេះស្របតាមមាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានមាត្រាពាក់ព័ន្ធនិងគម្រោងដូចតទៅៈ

**-មាត្រា១:** ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្ម ផលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ មូលដ្ឋាន ដើម្បីផលប្រយោជន៍ សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះផង ទាំងមរតកវប្បធម៌ធម្មជាតិផង ប្រកបដោយនិរន្តរភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**-មាត្រា២:** ច្បាប់នេះ មានវិសាលភាពអនុវត្តន៍លើជលផលទាំងអស់ ទាំងប្រភេទជលផលដែលកើតឡើងដោយធម្មជាតិ ទាំងជលផលកែច្នៃ និងទាំងវារីវប្បកម្ម។
រដ្ឋធានាសិទ្ធប្រើប្រាស់ធនធានជលផលជាប្រពៃណី របស់សហគមន៍មូលដ្ឋានក្រោមបទបញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត។

**-មាត្រា៣:** ការគ្រប់គ្រងធនធានជលផលត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។



Draft

ការគ្រប់គ្រងព្រៃលិចទឹក និងព្រៃកោងកាង ដែលពាក់ព័ន្ធនឹងវដ្តជីវិតនៃធនធានជលផលត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់នេះ។ រដ្ឋផ្តល់សិទ្ធគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថានក្រោមបទបញ្ញត្តិទាំងឡាយ នៃច្បាប់ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធសហការធ្វើសកម្មភាពពង្រឹងការអនុវត្តច្បាប់ចំពោះរាល់ បទល្មើសជលផល ដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការសម្រប សម្រួលជាមួយ ក្រសួងបរិស្ថាន ស្របតាមបទបញ្ញត្តិដូចមានចែងក្នុងជំពូកទី១៤នៃច្បាប់នេះ។ សកម្មភាពនេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់ដែន សមត្ថភាពគ្រប់គ្រង របស់ក្រសួងបរិស្ថានដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

-មាត្រា៤: ធនធានជលផល មានសេរីរាង្គទឹកសាប និងសមុទ្រ ជាសត្វ និងរុក្ខជាតិ មានជីវិត ឬគ្មានជីវិត ជាអាទិ៍ មច្ឆជាតិ សិប្បីសត្វ ថលជលិកសត្វ បាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀត ដែលបង្កកំណើតនៅក្នុងទឹក ប្លង់តុង សារាយ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃលិចទឹកព្រមទាំងព្រៃកោងកាងជាដើម។

-មាត្រា៨: ដែននេសាទរួមមាន ដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីទទួលរបបទឹកទន្លេមេគង្គ និងដែនដីទទួលរបបទឹកជោរ នាចនៃសមុទ្រដែលមានទួនាទីសំខាន់បម្រើឱ្យការនាសាទគ្រប់ប្រភេទ និងការការពារប្រព័ន្ធអេកូឡូស៊ីជលផល។

ដែនដីលិចទឹកអចិន្ត្រៃយ៍មានជាអាទិ៍ សមុទ្រ ទន្លេ ដៃសមុទ្រ បឹង ព្រែក ស្ទឹង អូរ អាងទឹក និងប្រឡាយ។

ដែនដីដែលទទួលរបបទឹកទន្លេមេគង្គមានជាអាទិ៍ ត្រពាំង រណ្ដៅ វាលភក់ ល្បាប់ វាលទំនាបដែលលិចទឹកក្នុងរដូវជំនោឡើង និងនាទីព្រៃលិចទឹក។

ដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រមានជាអាទិ៍ នាទីព្រៃកោងកាង។

-មាត្រា១៨: តំបន់គ្រប់គ្រងជលផលជាអាទិ៍ តំបន់ទឹកជ្រូរ អន្លង់ជ្រៅៗនៅតាមដងទន្លេ បឹងទន្លេសាប ព្រៃលិចទឹក តំបន់កោះ តំបន់ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាង ដែលជាកន្លែងមានសារៈសំខាន់ដល់និរន្តរភាពនៃធនធានជលផលត្រូវរៀបចំចាត់ថ្នាក់ជាកន្លែងការពារនិងអភិរក្សធនធានជលផល។

-មាត្រា២២: ហាមឃាត់ ការចាក់ចោល ការបោះចោល ការបង្ហូរ ការបាចពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬរាវ ឬសារធាតុពុល ដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តសកម្មភាព ដែលធ្វើឱ្យពុល ឬការបង្កគ្រោះថ្នាក់ ដល់វារីសត្វ និងវារីរុក្ខជាតិ។

-មាត្រា២៨: ហាមឃាត់:

១-ការពង្រីកផ្ទៃដីកសិកម្ម ឬការប្រើប្រាស់ដីក្នុងបំណងផ្សេងៗ ក្រៅពីកិច្ចអភិវឌ្ឍន៍វិស័យជលផលនៅក្នុងតំបន់លិចទឹក ដែលត្រូវការពារស្របតាមបទបញ្ញត្តិនៃច្បាប់នេះ។

២-ការផ្តល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីធ្លីនៅក្នុងតំបន់លិចទឹកដែលត្រូវការពារ។

៣-ការកាប់ ការឆ្ការ ការគាស់ ការរាន ការឈូសឆាយ ការដុត ឬការហ៊ុមព័ទ្ធកាន់កាប់ព្រៃលិចទឹក និងព្រៃកោងកាង។

៤- ការកាប់បំផ្លាញផ្តួលរំលំដើមឈើព្រៃលិចទឹក និងព្រៃកោងកាង ឬគាស់រំលើងប្រមូលគល់ឈើព្រៃលិចទឹក និងព្រៃកោងកាង។

៥-ការប្រមូល ដឹកជញ្ជូន និងការធ្វើសន្និធិឈើ អុស ធ្យូង ប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាងជាលក្ខណៈអាជីវកម្ម ឬពាណិជ្ជកម្ម។

៦-ការសាងសង់ឡ រោងសិប្បកម្ម មូលដ្ឋានកែច្នៃ និងរោងចក្រគ្រប់ប្រភេទ ដែលប្រើប្រាស់វត្ថុធាតុដើមជាប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាង។

## ៣.៩. ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ឆ្នាំ ២០០៥

ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គរបស់រដ្ឋសភាលើកទី២ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ ហើយបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ដែលមានពាក់ព័ន្ធនឹងគម្រោងមានដូចតទៅៈ

- **មាត្រា១:** ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- **មាត្រា២:** វិសាលភាពនៃច្បាប់នេះគ្របដណ្តប់លើការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃដំឡើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រាប់ប្រភេទ។
- **មាត្រា៥:** ត្រូវបានអនុញ្ញាតអោយជនស៊ីវិលប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដែលមិនស្ថិតនៅក្នុងកថាខណ្ឌ ក, ខ, គ នៃមាត្រា ៣ ក្នុងច្បាប់នេះ :
  - កាំភ្លើង និង គ្រាប់បាញ់កំណត់សញ្ញា
  - កាំភ្លើង និង គ្រាប់បាញ់សម្រាប់សកម្មភាពកីឡា
  - កាំភ្លើងដែលបាញ់ មិនមានបញ្ចូលក្បាលគ្រាប់ ឬ គ្រាប់ប្រាយ។ កាំភ្លើងបាញ់ បញ្ជូនកាំជ្រួចលំអ ឬកាំភ្លើងផ្ទុះស្នូរគ្មានក្បាលគ្រាប់សម្រាប់សំដែងសិល្បៈ។
  - គ្រឿងផ្ទុះសម្រាប់បម្រើសេវាកម្មសាធារណៈ និង វិស្វកម្មស៊ីវិល ឬ សម្រាប់ ផ្ទុះលំអ។ ល័ក្ខខ័ណ្ឌ និងនីតិវិធី សម្រាប់អនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹតតាមសំណើរបស់ក្រសួងមហាផ្ទៃ ។
- **មាត្រា៩:** ការចុះបញ្ជីគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាសមត្ថកិច្ចរបស់ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។
- **មាត្រា១២:** ក្រសួងការពារជាតិ ទទួលខុសត្រូវលើសុវត្ថិភាព និង សន្តិសុខស្តុកទុកអាវុធ គ្រឿង ផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ របស់កងយោធពលខេមរភូមិន្ទ។

  ក្រសួងមហាផ្ទៃ ទទួលខុសត្រូវលើសុវត្ថិភាព និងសន្តិសុខស្តុកទុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ របស់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និងជនស៊ីវិល។

  អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវទាំងអស់ត្រូវចុះក្នុងបញ្ជី ហើយអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទត្រូវតែស្តុកទុក និងបញ្ចូលក្នុងឃ្លាំងដែលមានសុវត្ថិភាព ។

Draft

- **មាត្រា២៣:** ជនណាដែលផលិត ធ្វើពាណិជ្ជកម្ម នាំឆ្លងកាត់ នាំចេញ នាំចូល ឬស្តុកនូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ។

## ៣.១០ ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣

ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី១ ហើយបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ដែលមានសេចក្តីទាំងស្រុងដូចតទៅ:

- **មាត្រា១ ថ្មី:** ច្បាប់នេះ មានវិសាលភាពចំពោះរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធី នៃការបង្កើតគម្រោងវិនិយោគមានលក្ខណៈគ្រប់គ្រាន់ ដែលធ្វើឡើងដោយបុគ្គលណាមួយ ។
  មានតែគម្រោងវិនិយោគលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេដែលមានសិទ្ធទទួលបាននូវផលប្រយោជន៍ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ។
- **មាត្រា១៤ ថ្មី:** ការលើកទឹកចិត្ត ដែលមានចែងក្នុងមាត្រា ១៣ រួមមានដូចខាងក្រោម :
  ១- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធទទួលការលើកលែងពន្ធ លើប្រាក់ចំនេញដែលមានកំណត់ក្នុងច្បាប់សារពើពន្ធ ដោយទទួលបាននូវរយៈពេលលើកលែងពន្ធលើប្រាក់ចំនេញ។ រយៈពេលលើកលែងពន្ធរួមមាន: រយៈពេលគន្លឹះបូករយៈពេល ៣(បី)ឆ្នាំ បូករយៈ ពេលអាទិភាព។ រយៈពេលអាទិភាព នឹងត្រូវកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ។ រយៈពេល គន្លឹះជាអតិបរិមាគឺជា ឆ្នាំទី១ ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណេញរយៈពេល៣(បី)ឆ្នាំ បន្ទាប់ពីគម្រោងវិនិយោគបានទទួលប្រាក់ចំណូលដំបូងរបស់ខ្លួន ដោយជ្រើសយកជម្រើសណាមួយដែលឆាប់ជាង ។
  ២- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធទទួលបាននូវការលើកទឹកចិត្ត ផ្អែកតាមកថាខណ្ឌ១ ខាងលើលុះត្រាតែគម្រោងនោះទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវវិញ្ញាបនប័ត្រប្រចាំឆ្នាំបញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ ដែលត្រូវកំណត់ដោយអនុក្រឹត្យ។
  ៣- បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវជាប់ពន្ធលើប្រាក់ចំណេញ ។
  ៤- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលប្រើប្រាស់សិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្អែកតាមកថាខណ្ឌ ១ខាងលើ ពុំមានសិទ្ធិធ្វើការទាមទារការរំលោះពិសេសណាមួយឡើយ
  ៥- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបម្រើទីផ្សារក្នុងស្រុក មានសិទ្ធ នាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារបរិក្ខាផលិតកម្ម សម្ភារសាងសង់បម្រើផលិតកម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។
  ៦- ក្រៅពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញដែលជ្រើសរើស ឬបានជ្រើសរើសយកយន្តការ កណ្តាគារផលិតកម្មក្រោមការគ្រប់គ្រងរបស់គយ គម្រោង

Draft

វិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បម្រើឱ្យការនាំចេញដ៏ទៃទៀត មានសិទ្ធិនាំចូលដោយរួចពន្ធ-គយនូវគ្រឿងសម្ភារបរិក្ខាផលិតកម្ម សម្ភារសាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវកំណត់ដោយអនុក្រឹត។

៧- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រមាន សិទ្ធិនាំចូលដោយរួចពន្ធគយ នូវគ្រឿងសម្ភារបរិក្ខា ផលិតកម្មសម្ភារសាងសង់វត្ថុធាតុដើមផលិតផលពាក់កណ្តាលសម្រេច និងសម្ភារបន្ទាប់បន្សំបម្រើផលិតកម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៨- បុគ្គលណាដែលបានទិញ ឬវិនិយោគដែលបានរំលាយបញ្ចូលគ្នាជាមួយអ្នកវិនិយោគណាមួយអាចទទួលស្នងពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយធ្វើសំណើទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវរាល់ការធានា សិទ្ធិ បុព្វសិទ្ធិ និងកាតព្វកិច្ចទាំងអស់ដោយយោងទៅតាមនីតិវិធីនៃការទិញ ឬការរំលាយបញ្ចូលគ្នាដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៩- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេសឬតំបន់ផលិតកែច្នៃនាំចេញដែលមាននៅក្នុងបញ្ជីអាទិភាពសម្រាប់អភិវឌ្ឍន៍ប្រកាសដោយក្រុមអភិវឌ្ឍកម្ពុជា មានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងបុព្វសិទ្ធិដូចគ្នានឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងៗទៀតដូចមានចែងនៅក្នុងច្បាប់នេះ ។

១០-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធទទួលបាននូវការលើកលែងពន្ធនាំចេញ១០០% (មួយរយភាគរយ) លើកលែងតែចំពោះសកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងច្បាប់ជាធរមាន។

១១-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធទទួលបាននូវទិដ្ឋាការ និងប័ណ្ណការងារដើម្បីធ្វើការនៅក្នុង ព្រះរាជាណាចក្រកម្ពុជា សម្រាប់ជនបរទេស ដែលធ្វើជាអ្នកគ្រប់គ្រង អ្នកបច្ចេកទេស និងកម្មករជំនាញ រួមទាំងទិដ្ឋាការស្នាក់នៅសម្រាប់សហព័ន្ធនិងអ្នកនៅក្នុងបន្ទុករបស់ជនបរទេសទាំងនោះ ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍និងច្បាប់ស្តីពីការងារ ។

- **មាត្រា១៥ ថ្មី:** សិទ្ធិ បុព្វសិទ្ធិ និងសិទ្ធិដ៏ទៃទៀត ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានទទួលមិនអាចផ្ទេរ ឬប្រគល់ជូនទៅតតិយជនណាមួយឡើយ លើកលែងតែក្នុងករណីទិញ ឬរំលាយបញ្ចូលគ្នា ដូចមានចែងនៅក្នុងកថាខណ្ឌ ៨ នៃមាត្រា១៤ ថ្មី ។

## ៣.១១. ច្បាប់ស្តីពីវិនិយោគ ឆ្នាំ១៩៩៤

ច្បាប់ស្តី ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ០៤ ខែសីហា ឆ្នាំ១៩៩៤ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី១ ។

- **មាត្រា១២:** រាជរដ្ឋាភិបាលលើកទឹកចិត្ត ដើម្បីជំរុញការវិនិយោគលើវិស័យសំខាន់ៗ ដូចតទៅ ៖

១- ឧស្សាហកម្មនាំមុខ ឬ ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់

២- ការបង្កើតការងារ

៣- ការបង្កើនការនាំចេញ

៤- ឧស្សាហកម្មទេសចរណ៍

៥- ការផលិតទំនិញកសិឧស្សាហកម្ម និង ឧស្សាហកម្មកែច្នៃ

៦- ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការផលិតថាមពល

៧- អភិវឌ្ឍន៍ខេត្ត និងជនបទ



Draft

៨- ការការពារបរិស្ថាន

៩- ការវិនិយោគក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលនិងត្រូវបង្កើតឡើងដោយច្បាប់ ។

## ៣.១២. ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២

ច្បាប់ស្តីពីព្រៃឈើ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៨០២/ ០១៦/៣១ សីហា ២០០២, អនុម័តនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២ ។ ច្បាប់នេះមានមាត្រាចំនួនខាងក្រោម ដែលពាក់ព័ន្ធនឹងគម្រោងៈ

**- មាត្រា១:** ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការធ្វើអាជីវកម្ម ការអភិវឌ្ឍ និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និង បរិស្ថានរួមទាំងការអភិរក្សជីវៈចំរុះ និងមរតកវប្បធម៌។

**- មាត្រា២ :** ច្បាប់នេះ មានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី។ រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផលអនុផលព្រៃឈើរបស់សមាគមន៍មូលដ្ឋាន ក្រោមបទបញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ពាក់ព័ន្ធផ្សេងទៀត។

**- មាត្រា៣:** ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រងព្រៃលិចទឹក ស្ថិតនៅក្រោមច្បាប់មួយដោយឡែក។

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិ ដល់ក្រសួងបរិស្ថាន ក្រោមបទបញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តច្បាប់ចំពោះរាល់បទល្មើសព្រៃឈើ ដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថាន ស្របតាមបទបញ្ញត្តិ ដូចមានចែងក្នុងជំពូកទី១៤ នៃច្បាប់នេះ។ សកម្មភាពនេះ នឹងមិនធ្វើឱ្យប៉ះពាល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ច ការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

**- មាត្រា៤:** ក្នុងការអនុវត្តច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាល ដែលមានសក្តានុភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជារដ្ឋទូទៅ លើជីវភាពសមាគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ។

សកម្មភាពចំបងៗពាក់ពន្ធ័ទៅនឹងប្រពន្ធ័មជ្ឈដ្ឋានព្រៃឈើដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រមបច្ចេកទេស គ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ ឯកសារនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់ មតិជាសាធារណៈបាន។ រាល់ការសម្រេចចុងក្រោយលើរាល់សកម្មភាពចំបងៗ ពាក់ពន្ធ័ទៅនឹងប្រព័ន្ធមជ្ឈដ្ឋាន ព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ ចុងក្រោយ នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម។ ការសម្រេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើ

Draft

ការជូនដំណឹងជាសាធារណៈ។

**- មាត្រា១០:** សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមាន:

១. ព្រៃបំរុងទុកអចិន្ត្រៃយ៍ ។

២. ព្រៃឯកជន ។

ព្រៃបំរុងទុកអចិន្ត្រៃយ៍រួមមានបីប្រភេទ:

១. ព្រៃផ្តល់ផលត្រូវបានរក្សាទុកសម្រាប់ផលិតកម្មផល អនុផលព្រៃឈើប្រកបដោយនិរន្តរភាព ដែលក្នុងនោះមុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់។ ព្រៃផ្តល់ផលមានជាអាទិ៍ៈ

- ព្រៃសម្បទាន
- ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន
- ព្រៃឈើត្រូវស្តារឡើងវិញ
- ផ្ទៃដីព្រៃបំរុងទុកសម្រាប់ដាំដើមឈើឡើងវិញ ឬ ចំការព្រៃឈើ
- ផ្ទៃដីព្រៃបំរុងទុកសម្រាប់បន្តពូជព្រៃឈើ
- ផ្ទៃដីព្រៃរិចរឹល
- ព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀង ។

២. ព្រៃការពារត្រូវបានរក្សាទុកជាចំបង ដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ។ ព្រៃការពារមានជាអាទិ៍:

- ព្រៃបំរុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស
- ព្រៃសម្រាប់សិក្សាស្រាវជ្រាវ
- ព្រៃនិយតកម្មប្រភពទឹក
- ព្រៃការពារទីជម្រាល
- ព្រៃលំហែកម្សាន្ត
- សួនរុក្ខជាតិ
- ព្រៃជំនឿសាសនា ។

ព្រៃការពារនេះអាចអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណី ដែលមានផលប៉ះពាល់ទាបដោយសហគមន៍មូលដ្ឋាន ។

៣. ផ្ទៃដីព្រៃសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិ ព្រៃបន្ទាប់បន្សំ ដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវតែដាក់ឱ្យស្ថិតនៅក្នុងចំណាត់ថ្នាក់ នៃព្រៃបំរុងទុកអចិន្ត្រៃយ៍រហូតដល់មានការសម្រេចឱ្យប្រើប្រាស់ និងអភិវឌ្ឍន៍សម្រាប់គោលបំណងផ្សេង ទៀតដោយរាជរដ្ឋាភិបាល។

ព្រៃឯកជនត្រូវថែរក្សាដោយម្ចាស់កម្មសិទ្ធិ និងមានសិទ្ធិទទួលផលប្រយោជន៍ក្នុងការអភិវឌ្ឍ និងប្រមូលផលប្រើប្រាស់ លក់ចែកចាយ ផលិតផលរបស់ខ្លួនដោយផ្ទាល់ ។

**- មាត្រា១២:** រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិអំណាចរំសាយចំណាត់ថ្នាក់ព្រៃឈើណាមួយពីព្រៃបំរុងទុកអចិន្ត្រៃយ៍។

ការសម្រេចបែបនេះ ត្រូវស្ថិតនៅក្នុងផលប្រយោជន៍សាធារណៈ និងមានសង្គតិភាពជាមួយគោលនយោបាយ វិស័យព្រៃឈើជាតិ ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ និងទិន្នន័យបច្ចេកទេស

Draft

សង្គមសេដ្ឋកិច្ច ដែលផ្តល់ដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ស្របតាមបទបញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ការរំសាយចំណាត់ថ្នាក់ណាមួយ នៃព្រៃបំរុងទុកអចិន្ត្រៃយ៍ សម្រាប់គោលបំណងមិនមែនព្រៃឈើ ត្រូវពិចារណាលើអាទិភាពដូចខាងក្រោមៈ

១. ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ។

២. ដីព្រៃបំរុងទុកអចិន្ត្រៃយ៍ផ្សេងទៀត ដែលតម្រូវការបច្ចុប្បន្នខ្ពស់ជាងតម្រូវការដែលកំណត់កន្លងមក ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចស្នើសុំរាជរដ្ឋាភិបាលកំណត់រកផ្ទៃដីព្រៃទំនេរផ្សេងទៀត ដើម្បីជំនួយផ្ទៃដីព្រៃបំរុងទុកអចិន្ត្រៃយ៍ ដែលបានរំសាយក្នុងគោលបំណងការពារ និងដាំព្រៃឡើងវិញ ដើម្បីរក្សាគំរបជាអចិន្ត្រៃយ៍។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចស្នើសុំរាជរដ្ឋាភិបាលសម្រេចធ្វើការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃណាមួយនៅក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ដោយផ្អែកលើទិន្នន័យសិក្សាថ្មី និងមុខងាររបស់ដីព្រៃនោះ។

រាល់សម្រេចរំសាយចំណាត់ថ្នាក់ព្រៃឈើ ដូចមានចែងក្នុងកថាខ័ណ្ឌទី១ និងការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃឈើដូចមានចែងក្នុងកថាខ័ណ្ឌទី៣ នៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ។

- **មាត្រា៣៧:** សហគមន៍មូលដ្ឋាន ដែលប្រកបរបរចំការពនេចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិ សហគមន៍ជនជាតិភាគតិច ដែលបានចុះបញ្ជីការួចហើយជាមួយរដ្ឋ។ ផ្នែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាននេះ ត្រូវផ្តល់ការអនុញ្ញាតការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះ ដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសហគមន៍នោះ។ ការអនុវត្ត ចំការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃធម្មជាតិមិនទាន់ប៉ះពាល់ក្នុងដែនព្រៃបំរុង ទុកអចិន្ត្រៃយ៍។ ដីព្រៃឈើដែលរៀបចំបំរុងសម្រាប់ចំការពនេចរត្រូវកំណត់ដោយអនុក្រឹត្យ ។

- **មាត្រា៣៩:** គ្មានរូបវន្តបុគ្គលណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ឱ្យកាប់ដើមឈើ ឬ ធ្វើសកម្មភាពគ្រប់យ៉ាង ដើម្បីប្រមូលផល អនុផលព្រៃឈើ ឬ កាន់កាប់ដីក្នុងដែនព្រៃបំរុងទុក អចិន្ត្រៃយ៍ ផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះឡើយ ។

- **មាត្រា៤០:** ចំពោះសហគមន៍មូលដ្ឋានរស់នៅក្នុង ឬ ក្បែរដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ រដ្ឋត្រូវទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាប្រពៃណី របស់សហគមន៍មូលដ្ឋាន នោះសម្រាប់គោលបំណងទំនៀមទំលាប់ ជំនឿ សាសនា និងការរស់នៅដូចមានចែងក្នុងមាត្រានេះ។

សិទ្ធិប្រើប្រាស់ជាប្រពៃណីលើផល អនុផលព្រៃឈើដោយសហគមន៍មូលដ្ឋាន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតប្រមូលផលឡើយ ។ សិទ្ធិប្រើប្រាស់ជាប្រពៃណីក្រោមមាត្រានេះរួមមានៈ

១. ការរើសប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការរុករកឃ្មុំ ការចោះយកជ័រ និងរុករកអនុផល ព្រៃឈើដទៃទៀតទាំងអស់ ។

២. ការប្រើប្រាស់ឈើមកសង់លំនៅឋាន ក្រោលសត្វ របង និងសម្រាប់ធ្វើឧបករណ៍កសិកម្ម។

៣. ការច្រូតយកស្មៅ ឬ លែងសត្វពាហនៈឱ្យស៊ីស្មៅក្នុងព្រៃ។

៤. ការប្រើប្រាស់ផលអនុផលព្រៃឈើផ្សេងទៀត ស្របតាមការប្រើប្រាស់ជាប្រពៃណី ជាលក្ខណៈគ្រួសារ។

៥. សិទ្ធិដោះដូរ ឬ លក់អនុផលព្រៃឈើដោយពុំចាំបាច់មានលិខិតអនុញ្ញាត ប្រសិនបើការលក់ដូរនេះ មិនគំរាម កំហែង ដល់និរន្តរភាពព្រៃឈើ។ អតិថិជន ឬភាគីទីបីណាមួយដែលបានប្រមូលទិញ អនុផលព្រៃឈើទាំង នោះពីសហគមន៍មូលដ្ឋាន ក្នុងគោលដៅពាណិជ្ជកម្មស្របតាមបទបញ្ញត្តិនៃ ច្បាប់នេះអាចធ្វើការដឹកជញ្ជូន ទៅកាន់បានដោយតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនក្រោយ ពេលបានបង់ថ្លៃសួយសារ និងបុព្វលាភលើ អនុផលព្រៃឈើទាំងនោះរួច ។

សហគមន៍មូលដ្ឋានមិនអាចផ្ទេរសិទ្ធិប្រើប្រាស់ជាប្រពៃណីឱ្យទៅភាគីទីបីបានឡើយ ទោះបីជាមានកិច្ចព្រមព្រៀង ទៅវិញមកក្តី ឬស្ថិតក្រោមកិច្ចសន្យាក្តី។ សិទ្ធិប្រើប្រាស់ជាប្រពៃណីត្រូវៈ

១. ស្របតាមលំនឹងធម្មជាតិ មាននិរន្តរភាពចំពោះធនធានព្រៃឈើ និងគោរពសិទ្ធិអ្នកដទៃ ។

២. ស្របតាមការអនុញ្ញាត និងការហាមឃាត់ ដែលកំណត់ដោយបទបញ្ញត្តិនៃច្បាប់នេះ ។

- **មាត្រា៤១:** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិប្រគល់ផ្នែកណាមួយនៃព្រៃបំរុងទុក អចិន្ត្រៃយ៍ឱ្យទៅសហគមន៍ ដែលរស់នៅក្នុង ឬ ជិតតំបន់ព្រៃឈើក្រោមរូបភាពជាព្រៃសហគមន៍ ។

- **មាត្រា៤២:** ខ័ណ្ឌរដ្ឋបាលព្រៃឈើ តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត មានភារកិច្ចសិក្សារៀបចំព្រៃបំរុងទុកអចិន្ត្រៃយ៍ ដើម្បីបង្កើតជាព្រៃសហគមន៍ ដោយកំណត់ ព្រំប្រទល់ច្បាស់លាស់ និង មានទំហំសមស្រប ផ្អែកតាមលទ្ធភាពធនធានព្រៃឈើ និងតម្រូវការ ប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍។ នាយខ័ណ្ឌរដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចចុះកិច្ចព្រម ព្រៀងព្រៃសហគមន៍ ជាមួយសហគមន៍មូលដ្ឋានណាមួយ ដែលរស់នៅក្នុង ឬក្បែរដែនព្រៃបំរុង ទុកអចិន្ត្រៃយ៍។ កិច្ចព្រមព្រៀងនេះត្រូវ មានសុពលភាពមិនលើសពីរយៈពេលដប់ប្រាំ *(១៥)* ឆ្នាំ តែអាចពន្យាលបាន ដោយផ្អែកលើរបាយការណ៍ពិនិត្យ និងវាយតម្លៃឡើងវិញរបស់ថ្នាក់ផ្នែករដ្ឋ បាលព្រៃឈើ។

- **មាត្រា៤៥:** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលស្គាល់ព្រៃពាក់ព័ន្ធជំនឿសាសនា របស់ សហគមន៍មូលដ្ឋាន ដែលរស់នៅក្នុង ឬក្បែរព្រៃនោះទុកជាព្រៃការពារ សម្រាប់គោលបំណង សាសនា វប្បធម៌ ឬការអភិរក្ស។ ដើមឈើជំនឿសាសនាអាចត្រូវបានសម្គាល់ ជាពិសេស មិន អនុញ្ញាតឱ្យកាប់រំលំ និងត្រូវកំណត់ក្នុងផែនការការគ្រប់ គ្រងព្រៃសហគមន៍ ។

- **មាត្រា៤៦:** បុគ្គលដែលបានដាំដើមឈើលើដីកម្មសិទ្ធិឯកជនផ្ទាល់ ឬ លើដីព្រៃរបស់រដ្ឋ ដែលបានប្រគល់សិទ្ធិ ប្រើប្រាស់មានសិទ្ធិថែរក្សា អភិវឌ្ឍន៍ប្រើប្រាស់ លក់ និងចែកចាយផលិតផលរបស់ខ្លួនបាន។ វិធាន ស្តីពីព្រៃឯកជនត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បី ជំរុញលើក ទឹកចិត្តដល់បុគ្គលក្នុងការដាំដុះ និងថែទាំចំការព្រៃឈើ ។

- **មាត្រា៥៣:** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចបន្ថយ ឬមិនយកថ្លៃសួយសារ និង បុព្វលាភ លើផលអនុផលព្រៃឈើដែលប្រមូលពីព្រៃឈើរដ្ឋ សម្រាប់គោលបំណងវិទ្យាសាស្ត្រ ឬដើម្បី បង្កើនការលើកទឹកចិត្តសេដ្ឋកិច្ច ចំពោះការប្រើប្រាស់អស់លទ្ធភាពលើផលិតផល។

រដ្ឋមិនយកថ្លៃសួយសារ និងបុព្វលាភពីសហគមន៍មូលដ្ឋានលើផលអនុផលព្រៃឈើដែលប្រមូលដោយសហគមន៍ មូលដ្ឋានសម្រាប់សិទ្ធិប្រើប្រាស់ជាប្រពៃណី ឬប្រមូលពីព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ឡើយ។

- **មាត្រា៦៨:** ទោះជាមានលិខិតអនុញ្ញាតិស្របតាមបទបញ្ញត្តិ នៃច្បាប់នេះក៏ដោយ ក៏ការកាប់ដើមឈើការ ប្រមូល ឬការដឹកជញ្ជូនផល អនុផលព្រៃឈើក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ត្រូវហាមឃាត់ចាប់ពី



Draft

ម៉ោងប្រាំបី (៨)យប់ ដល់ម៉ោង ប្រាំ (៥)ភ្លឺ ។

**-មាត្រា៩៤:** បុគ្គលណាដែលបានប្រព្រឹត្តិបទល្មើសព្រៃឈើ ធ្វើឱ្យប៉ះពាល់ខូតខាតដល់មជ្ឈដ្ឋានព្រៃឈើ ត្រូវចេញថ្លៃស្តារ ឬជួសជុលការខូចខាត មានលក្ខខណ្ឌដូចដើមឡើងវិញ ។

**-មាត្រា១០០:** សកម្មភាពទាំងឡាយណា ដែលធ្វើឡើងដោយមន្ត្រីអាជ្ញាធរដែនដី មន្ត្រីនគរបាល មន្ត្រីនៃកងយោធពលខេមរៈភូមិន្ទ ឬមន្ត្រីអាជ្ញាធរផ្សេងទៀត ដើម្បីធ្វើអន្តគមន៍ ផ្តល់ការអនុញ្ញាតិដោយផ្ទាល់ ឬដោយប្រយោល ជួយដល់អាជីវកម្មព្រៃឈើ និងធ្វើសកម្មភាពគ្រប់យ៉ាង ផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះ ឬធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬរាំងស្ទះដល់ការបំពេញភារកិច្ច និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវចាត់ទុកជាបទល្មើស ដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ចំនួនពី ដប់លាន (១០. ០០០.០០០) រៀល ។

**-មាត្រា១០១:** ចំពោះសកម្មភាពដូចខាងក្រោម ដែលប្រព្រឹត្តិឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវចាត់ទុកជាបទល្មើស និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី (១)ឆ្នាំ ទៅប្រាំ(៥) ឆ្នាំ និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០)រៀលទៅមួយរយលាន(១០០.០០០.០០០) រៀល។

១. ផ្តល់ការអនុញ្ញាតណាមួយដែលផ្ទុយ និងបទបញ្ញតិនៃច្បាប់នេះ ។

២. ចូលរួមទាំងស្រុង ឬដោយផ្នែក និងដោយផ្ទាល់ក្នុងសកម្មភាពណាមួយនៃអាជីវកម្មព្រៃឈើ ដែលផ្ទុយ នឹងបទបញ្ញត្តិនៃច្បាប់នេះ ។

៣. អនុគ្រោះចំពោះបទល្មើសព្រៃឈើណាមួយ ។

៤. ប្រកបរបរអាជីវកម្មណាមួយពាក់ព័ន្ធ នឹងវិស័យព្រៃឈើ ទោះធ្វើជាម្ចាស់ទាំងស្រុងក្តី ជាម្ចាស់ភាគហ៊ុនក្តី ឬ ធ្វើជានិយោជិត ឬអ្នកជានាឱ្យអ្នកដទៃក្តី ក្នុងអំឡុងពេលកំពុងកាន់តំណែង ឬក្នុងអំឡុងពេលមួយ (១) ឆ្នាំ ក្រោយពីការឈប់កាន់តំណែងដោយប្រការណាក៏ដោយ ។

៥. មិនបានរាយការណ៍ ឬមិនបានដាក់ពាក្យបណ្តឹងចំពោះបទល្មើសព្រៃឈើថ្នាក់ទី ១ ដែលបានកើតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា ។

៦. ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬផ្តល់ពត៌មាន នូវរបាយការណ៍ក្លែងបន្លំជាលាយលក្ខណ៍ អក្សរ ដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី១ ។

## ៣.១៣. ច្បាប់ភូមិបាល ឆ្នាំ២០០១

ច្បាប់ភូមិបាលនេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី១ បានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រម លេខ នស/រកម/០៨០១ /១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ហើយដែលមានមាត្រាពាក់ព័ន្ធ និងគម្រោងដូចតទៅះ

-មាត្រា១: ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃ កម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀត លើអចលនវត្ថុស្របតាមបទប្បញ្ញត្តិ នៃរដ្ឋ ធម្មនុញ្ញ ឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ។

-មាត្រា៣: ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។ ការ

Draft

គ្រប់គ្រងផ្ទៃករដ្ឋបាលសុរិយោដី លើអចលនវត្ថុដែលជាទ្រព្យសម្បតិរបស់រដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុ ទូទាំង ព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់។ បទបញ្ញា និងនិតិវិធី នៃការគ្រប់គ្រងអចលនវត្ថុ ដែលជាទ្រព្យសម្បតិរបស់រដ្ឋ នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**-មាត្រា៥:** គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះ មិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនិតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ញាបន្ទាប់ពីបាន ផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

**-មាត្រា៧:** របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់ ។

**-មាត្រា៣០:** បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ (ប្រាំ) ឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទ នៃការប្រកាសឱ្យប្រើច្បាប់នេះលើអចលនវត្ថុ ដែលមានលក្ខណៈត្រឹមត្រូវ តាមច្បាប់ក្នុងការកាន់កាប់ជាឯកជនមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។ ក្នុងករណីមានការជំទាស់ដល់ការ ផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថា ខ្លួនឯងផ្ទាល់បានបំពេញល័ក្ខខ័ណ្ឌនៃភោគៈ ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ (ប្រាំ)ឆ្នាំ នៅលើអចលនវត្ថុដែលមានជំទាស់ ឬយកភស្តុតាងដែល ថាខ្លួនបានទិញអចលនវត្ថុ នោះពីភាគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តិតិជនរបស់ខ្លួន។

**-មាត្រា៤២:** បុគ្គលទាំងឡាយណាដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួន ដោយហេតុមិនបានដឹង ឬដោយធ្វេសប្រហែស អ្នកនោះនៅតែមានសិទ្ធិត្រូវបានការពារតាមអំណាចនៃមាត្រា២៩ មាត្រា៣០ និងមាត្រា៣១ នៃច្បាប់នេះ ។

**-មាត្រា៤៣:** ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចជាកម្មវត្ថុនៃលទ្ធកម្មកម្មសិទ្ធិបានឡើយ ទោះក្នុងករណីណាក៏ដោយ។ ស្ថានភាពនៃអ្នកកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ របស់រដ្ឋនៅតែមិនទៀងទាត់ និងខុសច្បាប់ ដដែលប្រសិនជាស្ថានភាពនោះមិនកើតចេញពីការអនុញ្ញាតតាមបែបផែនដែលបានកំណត់ដោយច្បាប់ទេនោះ។ បុគ្គលកាន់កាប់ខុសច្បាប់ ត្រូវបង្ខំឱ្យចាក់ចេញជាបន្ទាន់ហើយត្រូវទទួលទណ្ឌកម្មដែលបានកំណត់ក្នុងមាត្រា ២៥៩ នៃច្បាប់នេះ។ បុគ្គលកាន់កាប់ខុសច្បាប់គ្មានសិទ្ធិទាមទារសំណងសម្រាប់ចំណាយលើការងារ និងការកែលំអ ដែលខ្លួនបានធ្វើនៅលើអចលនវត្ថុនោះឡើយ ។

## ៣.១៤. ច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០០

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តដោយរដ្ឋសភានៅថ្ងៃទី០៦ វិច្ឆិកា ឆ្នាំ២០០០ មាត្រាដែលមានពាក់ព័ន្ធនឹងគម្រោងមានដូចតទៅ:

- **មាត្រា១:** ច្បាប់នេះមានគោលបំណងគ្រប់គ្រង និងរៀបចំក្របខ័ណ្ឌ ការងារសម្រាប់ការផ្គត់ផ្គង់ និងសេវាកម្មអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះមានវិសាលភាពលើរាល់សកម្មភាពនៃការផ្គត់ផ្គង់ ការផ្តល់សេវាការប្រើប្រាស់អគ្គិសនី និងសកម្មភាពផ្សេងៗទៀត លើវិស័យអគ្គិសនី។
- អគ្គិសនីក្នុងច្បាប់នេះ សំដៅប្រើថាមពលអគ្គិសនី ឬសមត្ថភាពក្នុងការផលិតថាមពលអគ្គិសនី។
- សេវាកម្មអគ្គិសនីក្នុងច្បាប់នេះ សំដៅលើការផលិតការបញ្ជូន និងការចែកចាយអគ្គិសនី ព្រមទាំងសេវាកម្មបន្ថែម ឬបន្ទាប់បន្សំ ភ្ជាប់ជាមួយសកម្មភាពទាំងនេះ។
- **មាត្រា២:** ច្បាប់នេះសំដៅបង្កើតឡើងនូវ:

ក- គោលការណ៍សម្រាប់កិច្ចប្រត្តិបត្តិការវិស័យអគ្គិសនី និងរាល់សកម្មភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងការផ្តល់សេវាអគ្គិសនី។

ខ- ល័ក្ខខ័ណ្ឌសមស្របក្នុងការវិនិយោគទុន និងកិច្ចប្រតិបត្តិការពាណិជ្ជកម្មក្នុងវិស័យអគ្គិសនី។

គ- មូលដ្ឋានសម្រាប់បញ្ញាត្តិ ចំពោះការផ្គត់ផ្គង់សេវាកម្មអគ្គិសនីទូទៅព្រះរាជាណាចក្រកម្ពុជា។

ឃ- គោលគាណ៍សំរាប់:

១- ការពារសិទ្ធអ្នកប្រើប្រាស់ ដើម្បីទទួលបាននូវការផ្គត់ផ្គង់សេវាកម្មអគ្គិសនី ដែលមានស្ថេរភាព និងគ្រប់គ្រាន់តាមតម្លៃសមរម្យ។

២- បង្កើនកម្មសិទ្ធិឯកជនលើមធ្យោបាយសម្រាប់ការផ្តល់សេវាកម្មអគ្គិសនី

៣- បង្កើតការប្រកួតប្រជែងនៅទីណា ដែលអាចធ្វើទៅបានក្នុងផ្នែកអគ្គិសនី

ង- គោលការណ៍ក្នុងការផ្តល់សិទ្ធ កាតព្វកិច្ច និងធ្វើការពិន័យចំពោះអ្នកផ្គត់ផ្គង់ អ្នកប្រើប្រាស់អគ្គិសនី សាធារណៈជន និងម្ចាស់កម្មសិទ្ធទីតាំង ដែលទាក់ទិនដល់មធ្យោបាយផលិត និងផ្គត់ផ្គង់អគ្គិសនី និង

ច- អាជ្ញាធរអគ្គិសនីកម្ពុជា សម្រាប់បញ្ញាត្តិ ចំពោះការផ្តល់សេវាកម្មអគ្គិសនី។

អ្នកប្រើប្រាស់ ក្នុងន័យនៃច្បាប់នេះសំដៅលើបុគ្គលណាមួយ ឬអ្នកទទួលសិទ្ធបន្តដែលទិញ ឬទទួលអគ្គិសនី ដើម្បីប្រើប្រាស់ និងមិនមែន ដើម្បីផ្តល់ ឬលក់បន្តឱ្យអ្នកដទៃទៀត។

- **<u>មាត្រា៤:</u>** ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវធានាឱ្យមានទំនាក់ទំនងជាប្រក្រតីជាមួយនឹងអាជ្ញាធរអគ្គិសនីកម្ពុជា ព្រមទាំងត្រូវផ្តល់ពត៌មានដល់អាជ្ញាធរអគ្គិសនីកម្ពុជា អំពីគោលនយោបាយ យុទ្ធសាស្រ្ត ផែនការ អគ្គិសនី និងសេចក្តីសម្រេចស្តីពី:
  - ការវិនិយោគលើការស្តារ និងការអភិវឌ្ឍ វិស័យអគ្គិសនីសម្រាប់រយៈពេលខ្លី មធ្យម និងវែង
  - ការរៀបចំឡើងវិញ ការចូលរួមរបស់ផ្នែកឯកជន និង ឯកជនូបនីយកម្មរបស់សហគ្រាសសាធារណៈ
  - ការលើកទឹកចិត្តចំពោះការប្រើប្រាស់ធនធានថាមពល ដែលមានស្រាប់ក្នុងស្រុក សម្រាប់ការផលិតអគ្គិសនី
  - ការរៀបចំផែនការ និង កិច្ចព្រមព្រៀងលើការនាំចេញ នាំចូលអគ្គិសនី
  - ការឧបត្ថម្ភក្រុមអ្នកជាវជាកំណត់ណាមួយ និងការផ្តល់អាទិភាពដល់អ្នកប្រើប្រាស់អគ្គិសនី
  - ការបង្កើតប្រសិទ្ធិភាពក្នុងការផលិត បញ្ជូនចែកចាយអគ្គិសនី និងការប្រើប្រាស់អគ្គិសនីព្រមទាំងសកម្មភាព ដើម្បីបង្កើតកម្មវិធី សន្សំសំចៃអគ្គិសនី សម្រាប់កម្ពុជា និង
  - កាលៈទេសៈដែលមានភ័យអន្តរាយផ្នែកអគ្គិសនី និង យុទ្ធសាស្រ្តដើម្បីធានាសន្តិសុខផ្នែកថាមពល។
- **<u>មាត្រា៥:</u>** អ្នកផ្គត់ផ្គង់សេវាកម្មអគ្គិសនីនីមួយៗ ត្រូវមានអាជ្ញាប័ណ្ណ ដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ហើយត្រូវអនុវត្តន៍តាមបទប្បញ្ញត្តិ នៃច្បាប់នេះ និងរាល់បញ្ញត្តិដែលកំណត់ក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន ព្រមទាំងបទប្បញ្ញត្តិ និងនីតីវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា និង ការតម្រូវតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

រាល់ការសម្រេចចេញអាជ្ញាប័ណ្ណត្រូវផ្អែកលើគោលនយោបាយ យុទ្ធសាស្រ្ត និងផែនការលើវិស័យអគ្គិសនីរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគោលបំណងកាត់បន្ថយចំណាយម៉ាហ្សីណាល់រយៈពេលវែង និងខ្លីឱ្យបានតិចបំផុត ក្នុងការផ្គត់ផ្គង់អគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសេចក្តីសម្រេចនានា ដូចមានចែងក្នុងមាត្រា ៤ ហើយត្រូវធានាដល់ផលប្រយោជនសាធារណៈ។

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធានាឱ្យអ្នកកាន់អាជ្ញាប័ណ្ណ ប្រតិបត្តិតាមស្តង់ដារទាក់ទងទៅ និងកិច្ចប្រតិបត្តិការបច្ចេកទេស សុវត្ថិភាព និងបរិស្ថានដែលបង្កើតឡើង និងផ្សព្វផ្សាយដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។
អាជ្ញាប័ណ្ណក្នុងច្បាប់នេះសំដៅលើលិខិតអនុញ្ញាត ដើម្បីធ្វើសេវាកម្មអគ្គិសនី។

Draft

អ្នកកាន់អាជ្ញាប័ណ្ណក្នុងច្បាប់នេះសំដៅបុគ្គល ដែលកាន់កាប់អាជ្ញាប័ណ្ណស្របច្បាប់ និងមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

- **មាត្រា២៩:** អាជ្ញាប័ណ្ណដែលស្ថិតក្នុងសមត្ថរបស់អាជ្ញាធរអគ្គិសនីកម្ពុជាដូចមានចែងក្នុងកថាខ័ណ្ឌ " ក " មាត្រា ៧ នៃច្បាប់នេះមាន ប្រភេទដូចខាងក្រោម:

  ១- អាជ្ញាប័ណ្ណផលិតកម្ម

  ២- អាជ្ញាប័ណ្ណបញ្ជូន

  ៣- អាជ្ញាប័ណ្ណបែងចែក

  ៤- អាជ្ញាប័ណ្ណចែកចាយ

  ៥- អាជ្ញាប័ណ្ណលក់ដុំ

  ៦- អាជ្ញាប័ណ្ណលក់រាយ

  ៧- អាជ្ញាប័ណ្ណសេវាកម្មបន្ត

  ៨- អាជ្ញាប័ណ្ណរួម ។

ប្រតិបត្តិការផ្តល់សេវាកម្មអគ្គិសនី ក្រោមអាជ្ញាប័ណ្ណប្រភេទណាមួយដូចមានចែងក្នុងវាក្យខ័ណ្ឌលើខាងលើ ត្រូវមានរូបភាពជាក្រុមហ៊ុន ដែលបំពេញតាមនីតិវិធីជាធរមាន។ ចំពោះប្រតិបត្តិការផ្តល់សេវាកម្មអគ្គិសនីក្រោមអាជ្ញាប័ណ្ណសម្រាប់ផលិតកម្មចែកចាយ និង/ឬ លក់រាយអាចដំណើរការជារូបវន្តបុគ្គលបាន ក្នុងកម្រិតទំហំអាជីវកម្មទ្រង់ទ្រាយតូចដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

- **មាត្រា៣០:** អ្នកកាន់អាជ្ញាប័ណ្ណផលិតកម្ម មានសិទ្ធិធ្វើសេវាកម្មផលិតអគ្គិសនីដោយមធ្យោបាយផលិតកម្មជាកំណត់មួយ។ សិទ្ធិធ្វើសេវាកម្ម ផលិតអគ្គិសនីក្នុងច្បាប់នេះ គឺសិទ្ធជាម្ចាស់ សិទ្ធិដំណើរការ និងសិទ្ធិគ្រប់គ្រង ឬត្រួតត្រាលើមធ្យោបាយផលិតកម្ម ដើម្បីផលិតអគ្គិសនី លក់ពុំមែនដើម្បីប្រើប្រាស់ផ្ទាល់ទេ។

  ការផ្តល់អាជ្ញាប័ណ្ណផលិតកម្ម គឺសម្រាប់គោលបំណងក្នុងការជំរុញកិច្ចដំណើរការដោយសុវត្ថិភាព ស្ថេរភាព និងប្រសិទ្ធិភាពសេដ្ឋកិច្ចនៃបណ្តាញជាតិបញ្ជូនអគ្គិសនី ឬ បណ្តាញចែកចាយនិង មធ្យោបាយតភ្ជាប់។

  សុពលភាពរបស់អាជ្ញាប័ណ្ណផលិតកម្មជាទូទៅ ត្រូវកំណត់ស្មើនឹងអាយុកាលប្រើប្រាស់ដោយប្រសិទ្ធិភាព នៃមធ្យោបាយផលិតកម្ម លើកលែងតែក្នុងករណីដែលកិច្ចព្រមព្រៀងទិញអគ្គិសនីមានចិរវេលាតិចជាង។ អាជ្ញាប័ណ្ណផលិតកម្មអាចដកហូតបានតាមបញ្ញតិនៃច្បាប់នេះ ។

- **មាត្រា៤២:** អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗ ត្រូវគោរពគ្រប់ល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន បទបញ្ជា និងបទប្បញ្ញត្តិទាំងអស់ដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាអាទិ៍បណ្តាច្បាប់ដែលពាក់ព័ន្ធដល់កិច្ចដំណើរការការពារបរិស្ថាន សុវត្ថិភាពពលកម្ម សុខភាព ពន្ធដារ និងអនុវត្តការការពារ និងស្តង់ដារនៃប្រព័ន្ធអគ្គិសនី។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវប្រើប្រាស់ធនធាន និងផ្តល់នូវសេវាផលិតកម្មបញ្ជូនបែងចែក ឬចែកចាយដែលអាចអនុវត្តន៍បានដោយចំណាយទាបបំផុត និងដោយស្របទៅតាមបទពិសោធន៍យ៉ាងប្រុងប្រយ័ត្ន ដែលធ្លាប់មានកន្លងមក។

  អនុលោមតាមបទប្បញ្ញត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណម្នាក់ៗ ត្រូវជូនទៅអាជ្ញាធរអគ្គិសនីកម្ពុជាដោយចំលងជូនទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង អាចឱ្យសាធារណជនដឹងបាននូវ:

  ១- របាយការណ៍សង្ខេបប្រចាំឆ្នាំ នៃបណ្តាសកម្មភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងឆ្នាំកន្លងមក

  ២-ផែនការការងារប្រចាំដែលរៀបរាប់អំពីសកម្មភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណដែលត្រូវអនុវត្តសម្រាប់ឆ្នាំបន្ទាប់

  ៣- របាយការណ៍សេចក្តីប្រកាស និងពត៌មានផ្សេងៗទៀតដែលអាជ្ញាធរអគ្គិសនីកម្ពុជា កំណត់ដោយបទប្បញ្ញត្តិថា ចាំបាច់និង សមស្រប។ អ្នកកាន់អាជ្ញាប័ណណផលិតកម្មនីមួយៗ ត្រូវដាក់ជូនទៅអាជ្ញាធរអគ្គិសនី

កម្ពុជាពិនិត្យ និងសម្រេចនូវរបាយការណ៍ សេចក្តីប្រកាស និងពត៌មានណាមួយ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាកំណត់ដោយបទប្បញ្ញត្តិថា ចាំបាច់សម្រាប់ធានាដំណើរការដោយសុវត្ថិភាព និង ស្ថិរភាពបណ្តាញបញ្ជូន និងមធ្យោបាយតភ្ជាប់។

- **មាត្រា៤៦:** អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវកំណត់ និងពិនិត្យឡើងវិញលើអត្រាថ្លៃលក់ ថ្លៃសេវា និងល័ក្ខខ័ណ្ឌសេវាកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ។

  ក្នុងកំឡុងពេល ៩០ (កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំរបស់អ្នកកាន់អាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវ អនុម័តកែប្រែ ឬ បដិសេធចោលសំណើដែលស្នើសុំកំណត់ ឬ សុំផ្លាស់ប្តូរបញ្ជីថ្លៃលក់នោះ។

  អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវកំណត់ថ្ងៃចូលជាធរមាននៃបញ្ជីថ្លៃលក់អគ្គិសនីថ្មី ឬ ថ្លៃកែសំរួលឡើងវិញ ដែលមិនត្រូវឱ្យហួសរយៈពេល ៩០ (កៅសិប) ថ្ងៃ ដូចបានកំណត់ខាងលើ ។

## ៣.១៥. ច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

ច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧។ នាសម័យប្រជុំលើកទី ៧និតិកាលទី១ ហើយបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដែលមានមាត្រពាក់ព័ន្ធនិងគម្រោងនេះដូចតទៅ:

-មាត្រា២២៩: គ្រប់គ្រឹះស្ថាន និងទីកន្លែងធ្វើការត្រូវរក្សាឱ្យបានស្អាតហើយបង្ហាញថាមានលក្ខខណ្ឌអនាម័យ និងសុខភាពសុខសប្បាយជានិច្ច ឬជាទូទៅត្រូវឱ្យមានលក្ខខណ្ឌការងារ ជាចាំបាច់សម្រាប់សុខភាពរបស់កម្មករ-និយោជិត។

ក្រសួងទទួលបន្ទុកវិស័យការងារ និងក្រសួងពាក់ព័ន្ធត្រូវរៀបចំធ្វើប្រកាស ដើម្បីតាមដានត្រួតពិនិត្យ ការអនុវត្តមាត្រានេះសម្រាប់ឱ្យបាននៅគ្រប់គ្រឹះស្ថាន ដែលស្ថិតនៅក្រោមបទប្បញ្ញាត្តិនៃជំពូកនេះ ជាពិសេសដែលពាក់ព័ន្ធដល់:

- គុណភាពនៃទីកន្លែងធ្វើការ
- ការបោសសំអាត
- ឋបនភ័ណ្ឌសុខាភិបាល ដែលត្រូវមានសម្រាប់សេចក្តីត្រូវការរបស់បុគ្គលិក
- ភេសជ្ជៈ និងអាហារ
- ការស្នាក់នៅជាយថាហេតុរបស់បុគ្គលិក
- ប៉ុស្តិ៍ការងារ និងការរៀបចំអាសនៈធ្វើការ
- វិធានការសម្រាប់ធ្វើឱ្យខ្យល់ចេញចូលបានស្រួល និងការសំអាតបរិយាកាស កន្លែងធ្វើការ
- ឧបករណ៍ការពារផ្ទាល់ខ្លួន និងសំលៀកបំពាក់ការងារ
- ពន្លឺ និងសំឡេងក្នុងកន្លែងធ្វើការ

-មាត្រា២៣០: គ្រប់គ្រឹះស្ថាន និងទីកន្លែងធ្វើការត្រូវរៀបចំយ៉ាងណាឱ្យមានការធានាសុវត្ថិភាព របស់កម្មករនិយោជិត។ គ្រឿងម៉ាស៊ីន គ្រឿងយន្ត បរិធានសម្រាប់ការបញ្ជូនឧបករណ៍តូចធំ និងម៉ាស៊ីន ត្រូវដាក់និងរៀបចំក្នុងលក្ខខណ្ឌប្រសើរបំផុតនៃសន្តិសុខ។ ការចាត់ចែងការងារបច្ចេកទេស ដែលប្រើប្រាស់សម្ភារ ឧបករណ៍តូចធំម៉ាស៊ីន ឬផលិតផលប្រើប្រាស់ រួចត្រូវទុកដាក់ឱ្យបានល្អ ដើម្បីធានាសន្តិសុខរបស់កម្មករនិយោជិត។

ប្រកាសដែលមានចែងក្នុងមាត្រា២២៩ ក៏កំណត់ផងដែរនូវវិធានការសម្រាប់អនុវត្តន៍មាត្រានេះពិសេស ដែលពាក់ព័ន្ធដល់:

- ហានិភ័យនៃការជ្រុះធ្លាក់

Draft

- ការប្តូរទីតាំងនៃវត្ថុធ្ងន់ៗ
- ការការពារម៉ាស៊ីន និងបរិធាន ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់
- វិធានការការពារ ដែលត្រូវចាត់ចែងឱ្យមានក្នុងករណីធ្វើការងារក្នុងកន្លែងចង្អៀត ឬស្ថានភាពការងារដាច់តែឯង
- ហានិភ័យ នៃការហៀរចេញវត្ថុរាវ
- ការការពារអគ្គីភ័យ។

**-មាត្រា២៤៦:** ក្រសួងទទួលបន្ទុកវិស័យការងារ និងក្រសួងសុខាភិបាលត្រូវចេញប្រកាសរួមកំណត់:

ក- លក្ខខណ្ឌរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមពេទ្យការងារ។

ខ- រយៈពេលអតិបរមាដែលពេទ្យការងារត្រូវធ្វើការបំរើបុគ្គលិកនៃគ្រឹះស្ថាន ដែលច្បាប់បានចង្អុលស្របទៅតាមចំនួនបុគ្គលិក និងប្រភេទនៃសកម្មភាពព្រមទាំងមុខការជាចាំបាច់។

គ- ពេលវេលា និងខ្លឹមសាររបាយការណ៍ ដែលសហគ្រាស ឬតំណាងក្រុមអន្តរសហគ្រាសត្រូវធ្វើអំពីការរៀបចំការប្រព្រឹត្តិទៅ និងការគ្រប់គ្រងហិរញ្ញវត្ថុនៃក្រុមពេទ្យ។

**-មាត្រា២៤៨:** ត្រូវចាត់ទុកគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលធ្វើការទោះដោយហេតុយ៉ាងណាក៏ដោយហើយទោះមានកំហុសមកពីកម្មករនិយោជិត ឬគ្មានក៏ដោយគឺគ្រោះថ្នាក់ ដែលធ្លាក់លើរូបកាយកម្មករ និយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តីឥតឈ្នួលក្តីកាន់មុខងារជាអ្វីនៅទីកន្លែងណាក៏ដោយ។

ម៉្យាងទៀត ត្រូវចាត់ទុកជាគ្រោះថ្នាក់ ការងារដែរចំពោះ គ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករនិយោជិត ក្នុងពេលដែលសាម៉ី ខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះ ទៅទីកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅទីកន្លែង ផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ។ ជម្ងឺបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ដូចមានបញ្ជាក់ក្នុងច្បាប់ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ហើយទទួលការជួសជុលដូចគ្នាដែរ ។

**-មាត្រា២៤៩:** នាយកសហគ្រាស ត្រូវទទួលខុសត្រូវលើគ្រោះថ្នាក់ការងារទាំងអស់ ដូចមានរៀបរាប់ក្នុងមាត្រាខាងលើនេះ ទោះបីលក្ខន្តិកៈផ្ទាល់ខ្លួនរបស់កម្មករនិយោជិតម្នាក់ៗ នោះមានលក្ខណៈយ៉ាងណាក៏ដោយ។ ការទទួលខុសត្រូវ ដូចគ្នានេះត្រូវអនុវត្តន៍លើះ

- អ្នកគ្រប់គ្រងគ្រឹះស្ថានព្យាបាលឯកជន ចំពោះតែបុគ្គលិកដែលអ្នកគ្រប់គ្រងនេះប្រើ
- ជនដែលមានវិជ្ជាជីវៈសេរី ចំពោះតែគ្រោះថ្នាក់លើកម្មករនិយោជិតរបស់ជននោះ
- សហគ្រាសសិប្បកម្ម ចំពោះកម្មករនិយោជិតក្រៅពីប្រពន្ធកូនរបស់សិប្បករ
- ម្ចាស់ផ្ទះ ចំពោះតែគ្រោះថ្នាក់លើអ្នកបំរើក្នុងផ្ទះរបស់ខ្លួន
- សហគ្រាសកសិកម្ម ចំពោះគ្រោះថ្នាក់ នៃកម្មករនិយោជិតក្នុងសហគ្រាសនោះ។

ក្រៅពីប្រភេទដូចមានចែងជាក់លាក់ក្នុងកថាខ័ណ្ឌខាងដើមនេះ ជនណាដែលទទួលកម្មករនិយោជិតឱ្យ ប្រកបការណាមួយជាប្រាកដ និងម្តងម្កាលឱ្យខ្លួន ត្រូវតែជួសជុលគ្រោះថ្នាក់ផ្សេងៗ ដែលកម្មករនិយោជិតត្រូវរងគ្រោះក្នុងឱកាស ដែលបំពេញការងារនោះ។

**-មាត្រា២៥០:** នាយកសហគ្រាសគ្រប់រូបត្រូវចាត់ ឬប្រើឱ្យគេចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីបង្ការគ្រោះថ្នាក់ការងារផ្សេងៗ។

Draft

### ៣.១៦. ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣៩ និង ១៤៤ នៃច្បាប់ស្តីពីការងារ ឆ្នាំ ២០០៧

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១៣៩ និង ១៤៤ នៃច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិច្បាប់នេះទាំងស្រុង ដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០២០ ដែលមានមាត្រាពាក់ព័ន្ធនិងគម្រោងនេះដូចទៅ៖

**-មាត្រា១៣៩-ថ្មី** : ក្នុងករណីមានកិច្ចការប្រញាប់ខុសធម្មតា តម្រូវឱ្យកម្មករនិយោជិតធ្វើកាតបន្ថែមក្រៅម៉ោងពេលធម្មតា ម៉ោងពេលបន្ថែមទាំងនេះ ត្រូវឱ្យឈ្នួលតាមអត្រាដំឡើង៥០% (ហាសិបភាគរយ)។ ប្រសិនបើធ្វើការបន្ថែមនីពេលយប់ ចន្លោះពីម៉ោង ២២ ទៅម៉ោង ៥ ភ្លឺ ឬ នៅក្នុងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ត្រូវផ្តល់ប្រាក់បន្ថែមតាមអត្រាដំឡើង ១០០% (មួយរយភាគរយ)។

**-មាត្រា១៤៤-ថ្មី** : ពាក្យថាពេលយប់ក្នុងច្បាប់នេះ មានន័យថា រយៈពេល ១១ (ដប់មួយ) ម៉ោងបន្តបន្ទាប់គ្នាយ៉ាងតិច ដោយក្នុងនោះត្រូវមានពេលពីម៉ោង ២២ ទៅម៉ោង ៥ ភ្លឺផង។ ការងារពេលយប់ត្រូវគិតពីម៉ោង ២២ ទៅម៉ោង ៥ ភ្លឺ។

ក្រៅពីការងារបន្តបន្ទាប់ ដែលក្រុមកម្មករផ្លាស់វេនគ្នាធ្វើការជូនថ្ងៃ ជូនយប់ ការងារនៃសហគ្រាសអាចមានធ្វើមួយផ្នែកនៃពេលយប់ជានិច្ច។ ការងារពេលយប់ ត្រូវឱ្យប្រាក់ឈ្នួលតាមអត្រា ១៣០% (មួយរយសាមសិបភាគរយ) នៃប្រាក់ឈ្នួលការងារពេលថ្ងៃ។

### ៣.១៧. ច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤ ។ ហើយបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រម លេខ០៤នស៩៤/១០ សីហា ១៩៩៤ ហើយដែលមានមាត្រពាក់ព័ន្ធនិងគម្រោងដូចតទៅ៖

**-មាត្រា៤:** ឯកសារទាំងឡាយ ដែលទាក់ទងនឹងការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ត្រូវរៀបចំតាមករណីនីមួយៗឱ្យសមស្របទៅតាមស្ថានភាព លក្ខណៈពិសេសនៃទឹកដី ខេត្ត ក្រុង តំបន់ក្នុងស្មារតីការពារដល់ បេតិកភណ្ឌ ដល់បរិស្ថានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ។

**-មាត្រា៥:** គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំ ទឹកដីនគរូបនីយកម្ម និងសំណង់ ខេត្ត ក្រុង នីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍន៍ នៃរាជធានីខេត្តក្រុងរបស់ខ្លួន។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ និងកំណត់ដោយអនុក្រឹត្យ។ ដើម្បីការពារនូវបេតិកភណ្ឌ ការពារបរិស្ថាន និងដើម្បីធានាអភិវឌ្ឍន៍ សេដ្ឋកិច្ចចំពោះ តំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់គណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់មានភារៈ រៀបចំប្លង់គោលសម្រាប់តំបន់ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត ។

**-មាត្រា៧:** ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ត្រូវតែបញ្ជាក់ឱ្យច្បាស់លាស់អំពីតំបន់ ដែលត្រូវប្រើប្រាស់សម្រាប់ការពារ ជាតិសម្រាប់កសិកម្ម សម្រាប់ពាណិជ្ជកម្ម សម្រាប់ឧស្សាហកម្ម សម្រាប់សិប្បកម្ម វប្បធម៌ទេសចរណ៍ សាសនា ព្រមទាំងសម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខារសាធារណៈ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសម្រាប់សាងសង់។

-មាត្រា៨: ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវគោរពតាមប្លង់គោល ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

**-មាត្រា៩:** ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់សម្រាប់រាជធានី និងខេត្តក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ខេត្ត ក្រុង រួចត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិ រៀបចំទឹកដីនគរូប នីយកម្ម និងសំណង់ទៀត។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរ សាធារណៈទាំងពួងផង ។

**-មាត្រា១១:** រាល់ការកកាយរុករក ឬស្ទង់ដែលមានការប៉ះពាល់ដល់ខាងផ្នែកបុរាណវិទ្យា ចាំបាច់ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។ រាល់ការសាងសង់ ក្នុងករណីជួបប្រទះនូវវត្ថុអ្វីមួយដែលមានអត្ថប្រយោជន៍ខាងផ្នែក បុរាណវិទ្យា ឬប្រវត្តិសាស្ត្រ អ្នកទទួលខុសត្រូវការដ្ឋានត្រូវមានកាតព្វកិច្ចរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ច ឱ្យបានជ្រាបភ្លាមៗ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ឈប់ផ្អាកសំណង់ជាបន្ទាន់ ។

**-មាត្រា១៣:** ការងារសាងសង់ និងការតាំងទីត្រូវធ្វើឡើងដោយគោរពតាមឯកសារ ដែលទាក់ទងនឹងការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់គោរពតាមប្លង់គោលដែលមានចែងក្នុងមាត្រា៤ និង៥ នៃច្បាប់នេះ។

**-មាត្រា១៤:** រាល់ការសាងសង់ រាល់ការកែប្រែទិដ្ឋភាព ឬការកែប្រែការប្រើប្រាស់សំណង់ណាមួយត្រូវមានការអនុញ្ញាត ពីអាជ្ញាធរមានសមត្ថកិច្ច ។ ពាក្យស្នើសុំអនុញ្ញាតសាងសង់ត្រូវមានឯកសារ និងប្លង់ចាំបាច់ ។ និតិវិធី ក្នុងការអនុវត្ត មាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ៣.១៨. ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ ១៩៩៧

ច្បាប់ ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ហើយបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលមានមាត្រាពាក់ព័ន្ធនិងគម្រោងដូចទៅៈ

- **មាត្រា ៥:** ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម :

១– ពន្ធលើប្រាក់ចំណេញអនុវត្តន៍ចំពោះរបបពិត ត្រូវគណនាចេញពីលទ្ធផល នៃគុណ្យការសម្រេចបានក្នុងឆ្នាំសារពើពន្ធកន្លងទៅ។

២– ប្រសិនជាពុំមានគុណ្យការណាមួយ បានបញ្ឈប់ក្នុងកំឡុង នៃឆ្នាំណាមួយទេនោះ ពន្ធដែលត្រូវបង់សម្រាប់ឆ្នាំជាបន្ទាប់ត្រូវគិតយកលើប្រាក់ចំណេញ ក្នុងរយៈវេលាដែលកន្លងទៅ ចាប់តាំងពីថ្ងៃផុតរយៈពេលជាប់ពន្ធដែលកន្លងហួសទៅនោះ។ ចំពោះសហគ្រាសថ្មី ត្រូវគិតចាប់តាំងពីថ្ងៃ ដែលផ្តើមធ្វើប្រតិបត្តិការមកទល់នឹងថ្ងៃទី៣១ ធ្នូ នៃឆ្នាំដែលត្រូវគិតពន្ធ។

៣–កាលបើមានធ្វើគុណ្យការជាច្រើនតៗគ្នា ក្នុងកំឡុងនៃឆ្នាំមួយដដែលនោះ លទ្ធផលនៃគុណ្យការទាំងឡាយនោះត្រូវបូករួមគ្នាធ្វើជាមូលដ្ឋាននៃពន្ធដែលត្រូវបង់។

៤– ពន្ធលើប្រាក់ចំណេញអនុវត្តន៍ចំពោះរបបបំព្រួញ និងរបបម៉ៅការត្រូវគណនាតាមវិធីគណនេយ្យមូលដ្ឋានសាច់ប្រាក់នៅក្នុងឆ្នាំប្រតិទិនកន្លងមក។

៥–សេចក្តីណែនាំនានា ស្តីអំពីការធ្វើរបាយការណ៍ ការដាក់លិខិតប្រកាសចុងក្រោយសម្រាប់សហគ្រាសដែលបញ្ឈប់អាជីវកម្ម ឬរៀបចំឡើងវិញ ឬត្រូវបានលក់ ឬផ្ទេរក្នុងឆ្នាំប្រតិទិនត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- **មាត្រា ៣៨:**

៦– ការគណនាប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

Draft

៧–ក្នុងករណីដែលលទ្ធផលគណនាតាមមាត្រា ៣៧ នៃច្បាប់នេះ មានចំនួនច្រើនជាងផងបូកនៃចំនួនប្រាក់ពន្ធ ដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធតាមមាត្រា២៥នៃច្បាប់នេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញដែលអ្នកជាប់ពន្ធបានបង់ប្រចាំឆ្នាំតាមមាត្រា២៨នៃច្បាប់នេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែមចំនួនដែលលំអៀងនោះ ជូនរដ្ឋបាលសារពើពន្ធ ។

៨–ប្រសិនបើលទ្ធផលគណនាតាមមាត្រា ៣៧ នៃច្បាប់នេះ មានចំនួនតិចជាងផលបូកនៃចំនួនប្រាក់ពន្ធ ដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធតាមមាត្រា ២៥ នៃច្បាប់នេះ ក្រោយពីបានគិតបំណុលពន្ធអប្បបរមារួចហើយ អ្នកជាប់ពន្ធអាចសុំបង្វិលសងវិញនូវចំនួនដែលលំអៀង ឬយោងទៅប្រើជាប្រាក់រំដោះសម្រាប់ ឆ្នាំបន្ទាប់ ។

៩–មុននឹងធ្វើការទូទាត់ប្រាក់ពន្ធតាមកថាខណ្ឌ១ ឬក៏សុំបង្វិលសងតាមកថាខណ្ឌ២ អ្នកជាប់ពន្ធត្រូវតែកំណត់ជាមុននូវបំណុលអប្បបរមា តាមនីតិវិធីដែលមានចែងក្នុងមាត្រា ៣៩ នៃច្បាប់នេះ។

- **មាត្រា ៤៧:**

សម្រាប់ និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជក តាមអត្រាកំណើនតាមថ្នាក់ដូចតទៅ :

| ភាគនៃប្រាក់ចំណេញប្រចាំឆ្នាំ ដែលត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០៖០០ | ដល់ | ៥០០.០០០៖០០ | 0% |
| ពី | ៥០០.០០១៖០០ | ដល់ | ១.២៥០.០០០៖០០ | ៥% |
| ពី | ១.២៥០.០០១៖០០ | ដល់ | ៨.៥០០.០០០៖០០ | ១០% |
| ពី | ៨.៥០០.០០១៖០០ | ដល់ | ១២.៥០០.០០០៖០០ | ១៥% |
| | លើសពី | | ១២.៥០០.០០០៖០០ | ២០% |

### ៣.១៩. ច្បាប់ស្តីពីរបបសន្តិសុខសង្គម ឆ្នាំ ២០០២

របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ។ ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី២។

- **មាត្រា ១:** ច្បាប់នេះ មានគោលបំណងបង្កើតឱ្យមានរបបសន្តិសុខសង្គមសម្រាប់ ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចតទៅ:

១-ផ្នែកប្រាក់សោធនដែលត្រូវទទួលបន្ទុកផ្តល់តាវកាលិកជរាភាព ទុព្វលភាព និងបរណភាព។

២-ផ្នែកហានិភ័យការងារដែលត្រូវទទួលបន្ទុកផ្តល់តាវកាលិកគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ។

ចំពោះផ្នែកដទៃផ្សេងទៀតនឹងត្រូវកំណត់ដោយអនុក្រឹត្យជាបន្តបន្ទាប់ ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ។

- **មាត្រា ៣:** របបសន្តិសុខសង្គមដែលបង្កើតដោយច្បាប់នេះ ត្រូវធានារ៉ាប់រងដោយបេឡាជាតិរបបសន្តិសុខសង្គមសរសេរកាត់ថា "ប.ស.ស"។ បេឡាជាតិរបស់សន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈដែលត្រូវបង្កើតដោយអនុក្រឹត្យអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៦ និងព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈ។

- **មាត្រា ៤:** ជនដែលត្រូវដាក់បញ្ចូលឱ្យនៅក្នុងរបបសន្តិសុខសង្គមតាមច្បាប់នេះ ដោយមិនមានបែងចែកពីពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា គំនិតនយោបាយជាតិកំណើត ដើមកំណើតសង្គម ការចូលជាសមាជិកសហជីពកម្មករនិយោជិក ឬការធ្វើសកម្មភាពក្នុងសហជីពគឺ:

Draft

- កម្មករនិយោជិកទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ប្រសិនបើជនទាំងនោះធ្វើសកម្មភាពការងារនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍សម្រាប់និយោជកម្នាក់ ឬច្រើននាក់ ដោយមិនគិតដល់ប្រភេទ ទម្រង់ និងសុពលភាពនៃកិច្ចសន្យា ឬប្រភេទ និងចំនួននៃប្រាក់ឈ្នួលដែលជននោះបានធ្វើឬបានទទួលឡើយ។
- កម្មករនិយោជិករដ្ឋ កម្មករនិយោជិកនៃអង្គការសាធារណៈ និងបុគ្គលិកទាំងអស់ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឬលក្ខន្តិកៈទូតព្រមទាំងភ្នាក់ងារក្រុមរាជការសាធារណៈដែលតែងតាំងដោយបណ្តោះអាសន្ន។
- សិស្សសាលាវិជ្ជាជីវៈ ជនដែលដាក់ឱ្យធ្វើការងារនៅក្នុងមណ្ឌលបណ្តុះបណ្តាលសម្របសម្រួល និងអប់រំវិជ្ជាជីវៈសារឡើងវិញ និងកូនជាង ត្រូវចាត់ទុកដូចជាកម្មករនិយោជិក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌ ១ នៃមាត្រានេះដែរ។ បែបបទសម្រាប់អនុវត្តន៍បទប្បញ្ញត្តិផ្នែកនេះ ត្រូវកំណត់ដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។
- ជនដែលប្រកបមុខរបរក្នុងវិជ្ជាជីវៈសេរី ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។
- កម្មករនិយោជិកធ្វើការម្តងម្កាល ឬតាមរដូវ។ បែបបទចាំបាច់ដោយឡែកផ្សេងទៀតសម្រាប់ការអនុវត្តបទប្បញ្ញត្តិនៃផ្នែកនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។
- សមាសភាព និងការប្រព្រឹត្តទៅនៃក្រុកប្រឹក្សាបច្ចេកទេស ត្រូវកំណត់ដោយអនុក្រឹត្យ។

- **មាត្រា ៥:**

១-ជនទាំងឡាយណាដែលត្រូវបានចូលក្នុងរបបសន្តិសុខសង្គមក្នុងរយៈពេលយ៉ាងតិចប្រាំមួយ (៦)ខែ ជាបន្តបន្ទាប់មកហើយៗអស់លទ្ធភាពបំពេញលក្ខខណ្ឌ នៃការងារបញ្ចូលក្នុងរបបសន្តិសុខសង្គមនៃច្បាប់នេះ ប៉ុន្តែចង់បន្តដោយស្ម័គ្រចិត្តនៅក្នុងផ្នែកសោធនតទៅទៀត ត្រូវដាក់ពាក្យសុំក្នុងរយៈពេលបីខែក្រោយពីថ្ងៃដែលខ្លួនបានបញ្ចប់កាលបរិច្ឆេទតាមសេចក្តីតម្រូវការនៃការបញ្ចូលទៅក្នុងរបបនេះ។

២-បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ត្រូវចេញប្រកាសកំណត់អំពីបែបបទអនុវត្តន៍ចំពោះការធានារ៉ាប់រង ផ្នែកសោធនតាមការស្ម័គ្រចិត្តដូចមានចែងក្នុងមាត្រនេះ។

- **មាត្រា ៦:** និយោជក និងកម្មករនិយោជិកទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវមានកាតព្វកិច្ចបង់ភាគទានជូនដល់ ប.ស.ស។ បែបបទ និងនីតិវិធីនៃការបង់ភាគទាននិងការទទួលការកាលិកត្រូវកំណត់ក្នុងអនុក្រឹត្យស្តីពីការបង្កើត ប.ស.ស ដូចមានចែងក្នុងមាត្រា ៣ ខាងលើ។
- **មាត្រា ១២:** ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលធ្លាប់លើរូបកាយកម្មករនិយោជិកដោយធ្វើការ ឬក្នុងពេលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសពីកម្មករនិយោជិក ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាប់លើរូបកាយកម្មករនិយោជិក ក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វីនៅទីណាក៏ដោយ។

ម្យ៉ាងទៀត ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើរូបកាយកម្មករនិយោជិក ក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ។

- **មាត្រា ១៤:**

១-អ្នករងគ្រោះដោយគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬអ្នកតំណាងនៃនិយោជកនោះ អំពីគ្រោះថ្នាក់ដែលធ្លាក់មកលើខ្លួន លើកលែងតែក្នុងករណីប្រធានសក្តិ ឬការមិនមានលទ្ធភាពជាស្ថាពរ ឬក៏មានមូលហេតុសមហេតុសមផល។ កាតព្វកិច្ចដូចគ្នានេះដែរ បើក្នុងករណីមានគ្រោះថ្នាក់បណ្តាលឱ្យបាត់បង់ជីវិត ត្រូវធ្លាក់ទៅលើអ្នកសិទ្ធិវន្ត។

២-និយោជកត្រូវជូនដំណឹងទៅ ប.ស.ស ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំបី (៤៨)ម៉ោង ចំពោះគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈដែលធ្លាក់លើរូបកាយនិយោជិតកម្មករដែលធ្វើការក្នុងសហគ្រាសរបស់ខ្លួន។ ការជូនដំណឹងនេះ ត្រូវធ្វើតាមទំរង់បែបបទដែលមានកំណត់ក្នុងប្រកាសរួមនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស។

៣-បែបបទនៃការត្រួតពិនិត្យ និងកាតព្វកិច្ចនៃអ្នករងគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈត្រូវកំណត់ដោយប្រកាសរួមនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងក្រសួងសុខាភិបាល។

- **មាត្រា ១៥:**

តាវកាលិកនៃហានិភ័យការងារមានៈ

ក-ការថែទាំ និងព្យាបាលមុខរបួសដែលបណ្តាលមកពីគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ទោះបីគ្រោះថ្នាក់នោះបណ្តាលឱ្យមានការអាក់ខានធ្វើការក្តី ឬគ្មានក្តី។

ខ-ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់គ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្ន។

គ-ការផ្តល់ធនលាភ ឬប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ ចំពោះគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍។

ឃ-ការផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយសម្រាប់បូជាសព និងធនលាភចំពោះឧត្តរជីវីនៃជនរងគ្រោះ។

- **មាត្រា ១៦:**

ការថែទាំនិងព្យាបាលមានជាអាទ៍ដូចខាងក្រោមៈ

ក-ការជួយរ៉ាប់រងក្នុងការព្យាបាលការវះកាត់ កិច្ចការទន្តសាស្ត្រព្រមទាំងការពិនិត្យដោយវិទ្យុកាំរស្មី ការពិនិត្យរបស់មន្ទីរពិសោធន៍ និងការវិភាគផ្សេងៗ។

ខ-ការផ្គត់ផ្គង់ឱសថសម្រាប់ព្យាបាល និងសម្ភារប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល។

គ-ការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការថែទាំអ្នករងគ្រោះនៅក្នុងមន្ទីរពេទ្យ ឬក្នុងទីផ្សេងទៀត។

ឃ-ការផ្គត់ផ្គង់ ការថែទាំ ឬជួសជុលជថ្មីនូវឧបករណ៍អវយវៈសិប្បនិម្មិត ឬការកែទម្រង់កាយដោយគ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យទទួលស្គាល់ដោយ ប.ស.ស តម្រូវឱ្យធ្វើ ឬការកែលំអសម្របសម្រួលមុខងារ ឬការអប់រំវិជ្ជាជីវៈឡើងវិញ។

ង-ការសម្របសម្រួលមុខងារ ការអប់រំវិជ្ជាជីវៈឡើងវិញ ការចាត់ថ្នាក់ការងារឡើងវិញតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។

ច-ការដឹកជនរងគ្រោះពីកន្លែងគ្រោះថ្នាក់ទៅកាន់កន្លែងព្យាបាល ឬទៅកាន់លំនៅស្ថាន។

- **មាត្រា ២១:**

១-ចំពោះសមាជិក ប.ស.ស ដែលបានទទួលប្រាក់ធនលាភដោយការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ដោយផ្នែក ប៉ុន្តែត្រូវរងនូវហានិភ័យការងារជាថ្មីម្តងទៀត ត្រូវមានការគិតគូរឡើងវិញនូវចំនួនប្រាក់ធនលាភថ្មី ដោយផ្អែកលើកម្រិតនៃការបាត់បង់សមត្ថភាពការងារថ្មីនោះ។ ទោះជាយ៉ាងនេះក៏ដោយ បើក្នុងពេលគ្រោះថ្នាក់ខាងក្រោមនេះ អ្នករងគ្រោះទទួលប្រាក់ឈ្នួលនេះសម្រាប់ជាមូលដ្ឋានក្នុងការគណនាប្រាក់ធនលាភថ្មី។



Draft

២-ចំពោះសមាជិក ប.ស.ស ដែលកំពុងទទួលប្រាក់វិភាជន៍ដោយការបាត់បង់សមត្ថភាពការងារ ប៉ុន្តែត្រូវរងហានិភ័យការងារជាថ្មីបណ្តាលឱ្យបាត់បង់សមត្ថភាពការងារយ៉ាងតិចម្ភៃភាគរយ (២០%) ជននេះ មានសិទ្ធិទទួលនូវប្រាក់ធនលាភតាមកម្រិតបាត់បង់សមត្ថភាពការងារជាក់ស្តែងរបស់ខ្លួន។ បើនៅពេលរងគ្រោះថ្នាក់ខាងក្រោយនេះ អ្នករងគ្រោះទទួលបានប្រាក់ឈ្នួលមធ្យមខ្ពស់ជាងមុន ត្រូវយកប្រាក់នេះសម្រាប់គណនាប្រាក់ធនលាភ។

៣-គ្រប់ករណីទាំងអស់ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារនៅតែចាត់ទុកថាជាប្រាក់បណ្តោះអាសន្នជានិច្ច។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាពជាកាលិកចំពោះអ្នករងគ្រោះដែលទទួលប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ។

អ្នករងគ្រោះមិនអាចជំទាស់នឹងការពិនិត្យសុខភាព ដែលធ្វើឡើងតាមបញ្ជារបស់បេឡាជាតិរបបសន្តិសុខសង្គមបានឡើយ។

- **មាត្រា ២២:** នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីសកម្មភាពសុខាភិបាលនិងសង្គមកិច្ច ប.ស.ស ត្រូវរៀបចំឱ្យមានការបង្ការចំពោះហានិភ័យការងារមានជាអាទិ៍ វិធានការផ្នែកអនាម័យនិងសន្តិសុខការងារចំពោះកម្មករនិយោជិកដែលមានកំណត់នៅក្នុងច្បាប់ស្តីពីការងារ និងអត្ថបទណែនាំអនុវត្តន៍ច្បាប់នេះ។

## ៣.២០. ច្បាប់ស្តីពីផ្លូវថ្នល់ ឆ្នាំ ២០១៤

ច្បាប់ ស្តីពីផ្លូវថ្នល់ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ ២០១៤ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ដែលមានមាត្រាពាក់ព័ន្ធនិងគម្រោងដូចទៅ៖

**-មាត្រា២៥:** អ្នកប្រើប្រាស់យានយន្តដឹកជញ្ជូនលើផ្លូវថ្នល់ ត្រូវអនុវត្តន៍តាមការកំណត់អំពីការផ្ទុកទម្ងន់ដូចមានចែងក្នុងមាត្រា២៦ នៃច្បាប់នេះ និងត្រូវចូលត្រួតពិនិត្យថ្លឹងទម្ងន់នៅស្ថានីយថ្លឹងយានយន្ត ដែលស្ថិតនៅតាមបណ្តាញផ្លូវថ្នល់នីមួយៗ ព្រមទាំងផ្លូវកម្រិតកំណត់។

បទដ្ឋានបច្ចេកទេសទំហំផ្លូវកម្រិតកំណត់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

ការត្រួតពិនិត្យយានយន្តដឹកជញ្ជូន លើសទម្ងន់កម្រិតកំណត់ ជាសមត្ថកិច្ច របស់ គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យ យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ គោរពតាមបទដ្ឋានបច្ចេកទេសទំហំត្រូវកំណត់ដោយអនុក្រឹត្យ។

**-មាត្រា២៦:** ទម្ងន់ដឹកជញ្ជូនអតិបរមាលើបណ្តាញផ្លូវថ្នល់ មានដូចតទៅ៖

១- លើផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវរាជធានី ផ្លូវក្រុង ផ្លូវទីប្រជុំជននានាក្នុងខេត្តផ្លូវជនបទ ត្រូវអនុវត្តន៍ ដូចខាងក្រោម ៖

ក- ការកម្រិតទម្ងន់អតិបរមាសង្កត់លើភ្លៅរថយន្ត រ៉ឺម៉ក ឬសឺមីរ៉ឺម៉កត្រូវកំណត់ត្រឹម ៖

- ៦(ប្រាំមួយ)តោន សម្រាប់ភ្លៅទោលដែលមានកង់២(ពីរ) ស្ថិតនៅផ្នែកចង្កូតរថយន្ត
- ១១(ដប់មួយ)តោន សម្រាប់ភ្លៅភ្លោះដែលមានកង់៤(បួន) ស្ថិតនៅផ្នែកចង្កូតរថយន្ត
- ១០(ដប់)តោន សម្រាប់ភ្លៅទោលដែលមានកង់៤(បួន)
- ១៩(ដប់ប្រាំបួន)តោន សម្រាប់ភ្លៅភ្លោះដែលមានកង់៨(ប្រាំបី)
- ២៤(ម្ភៃបួន)តោន សម្រាប់ភ្លៅបីជិតគ្នាដែលមានកង់១២(ដប់ពីរ)។

ខ- ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្ត ត្រូវកំណត់ត្រឹម ៖

- ១៦(ដប់ប្រាំមួយ)តោន សម្រាប់រថយន្តដែលមានភ្លៅ២(ពីរ) គឺភ្លៅទោលផ្នែកខាងមុខរថយន្ត ដែលមានកង់២ (ពីរ) និងភ្លៅទោលផ្នែកខាងក្រោយរថយន្តដែលមានកង់៤(បួន)
- ២៥(ម្ភៃប្រាំ)តោន សម្រាប់រថយន្តដែលមានភ្លៅ៣(បី) គឺភ្លៅទោលផ្នែកខាងមុខរថយន្ត ដែលមានកង់២(ពី) និង ភ្លៅភ្លោះផ្នែកខាងក្រោយរថយន្តដែលមានកង់៨(ប្រាំបី)
- ៣០(សាមសិប)តោន សម្រាប់រថយន្តដែលមានភ្លៅ៤(បួន) គឺភ្លៅភ្លោះផ្នែកខាងមុខរថយន្ត ដែល មានកង់៤(បួន) និងមានភ្លៅភ្លោះផ្នែកខាងក្រោយរថយន្តដែលមានកង់៨ (ប្រាំបី) ។

គ- ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្តសណ្ដោងរ៉ឺម៉កត្រូវកំណត់ត្រឹម ៖

- ៣៥(សាមសិបប្រាំ)តោន សម្រាប់រថយន្តសណ្ដោងរ៉ឺម៉កដែលមានភ្លៅ៤(បួន) គឺភ្លៅទោល ផ្នែកខាងមុខរថយន្ត ដែលមានភ្លៅ២(ពីរ) ភ្លៅទោលផ្នែកខាងក្រោយរថយន្តដែលមានកង់ ៤(បួន) និងភ្លៅទោលផ្នែកខាងក្រោយ រ៉ឺម៉កដែលមានកង់៤(បួន)
- ៤០(សែសិប)តោន សម្រាប់រថយន្តសណ្ដោងរ៉ឺម៉កដែលមានភ្លៅចាប់ពី៥(ប្រាំ) ឡើងទៅ ។

ឃ- ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមា របស់រថយន្តសណ្ដោងសីមីរ៉ឺម៉កត្រូវកំណត់ត្រឹម ៖

- ៣៥(សាមសិបប្រាំ)តោន សម្រាប់រថយន្តសណ្ដោងសីមីរ៉ឺម៉កដែលមានភ្លៅ៤(បួន) គឺភ្លៅទោលផ្នែកខាងមុខ រថយន្តដែលមានកង់២(ពី) ភ្លៅទោលផ្នែកខាងក្រោយ។

## ៣.២១. ច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ឆ្នាំ ២០១៤

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ និតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទំរង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៦ នីតិកាលទី៣ និងបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ នាថ្ងៃទី៦ ខែមករា ឆ្នាំ២០១៥ ដែលមាត្រាពាក់ព័ន្ធ និងគម្រោងមានដូចខាងក្រោម៖

- **មាត្រា១:** ច្បាប់នេះមានគោលបំណងធានាសុវត្ថិភាព សណ្ដាប់ធ្នាប់ចរាចរណ៍ផ្លូវគោក និងធានាការពារសុខភាព និងអាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន។

- **មាត្រា៤:** វាក្យសព្ទដែលប្រើប្រាស់ក្នុងច្បាប់នេះ មាននិយមន័យដូចខាងក្រោម៖
  - **ផ្លូវថ្នល់** ហៅថាផ្លូវ សំដៅដល់ទំហំទាំងមូលរួមមានតួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវ ឬចិញ្ចើមផ្លូវ ស្ពាន ស្ពានអាកាស ស្ពានរំលង ផ្លូវរូង និងកំពង់ចម្លងតភ្ជាប់ផ្លូវថ្នល់។
  - **ផ្លូវជាតិ** សំដៅដល់ផ្លូវដែលមានចរាចរណ៍ច្រើន៖

    ក- ផ្លូវភ្ជាប់ពីចេញពីរាជធានីភ្នំពេញ ឆ្ពោះទៅកាន់ក្រុងនៃខេត្តនីមួយៗ នៅទូទាំងប្រទេស។

    ខ- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយទៀត។

    គ- ផ្លូវភ្ជាប់ចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវជាតិ។

    ឃ- ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយ។

    ង- ផ្លូវបែកចេញពីផ្លូវជាតិ ឬផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់តំបន់សំខាន់ៗ ដូចជា កំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារព្រំដែន តំបន់មានសក្ដានុពលសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត។

Draft

ច- ផ្លូវសំខាន់ៗរបស់ជាតិមានចរាចរណ៍ច្រើន ដែលកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន។

- **ផ្លូវខេត្ត** សំដៅដល់ផ្លូវដែលមានចរាចរណ៍មធ្យមៈ
  - ក- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ។
  - ខ- ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវខេត្ត។
  - គ- ផ្លូវបែកចេញពីផ្លូវខេត្ត ឬផ្លូវក្រុង ឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ។
  - ឃ- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ផ្លូវខេត្ត។
  - ង- ផ្លូវបែកចេញពីផ្លូវខេត្ត ឆ្ពោះទៅកាន់ផ្លូវខេត្ត។
  - ច- ផ្លូវបែកចេញពីផ្លូវខេត្ត ឬផ្លូវក្រុង ឬផ្លូវទីប្រជុំជននានាក្នុងខេត្តទៅកាន់តំបន់សំខាន់ៗ ដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារព្រំដែនទ្វេភាគី តំបន់មានសក្តានុពលសេដ្ឋកិច្ចមធ្យមផ្សេងទៀត។
- **ផ្លូវជនបទ** សំដៅដល់ៈ
  - ក- ផ្លូវដែលភ្ជាប់ពីផ្លូវជាតិ ផ្លូវខេត្ត ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ ទីប្រជុំជន ឃុំ សង្កាត់ និងទៅភូមិ។
  - ខ- ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ។
  - គ- ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ទៅទីប្រជុំជនឃុំ សង្កាត់។
  - ឃ- ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ទៅទីប្រជុំជនឃុំ សង្កាត់។
  - ង- ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ទៅភូមិ។
  - ច- ផ្លូវដែលភ្ជាប់ពីភូមិទៅភូមិ។
  - ឆ- ផ្លូវក្នុងភូមិ។
- **ផ្លូវល្បឿនលឿន** សំដៅដល់ផ្លូវសម្រាប់យានយន្តធ្វើចរាចរណ៍ មានបរិក្ខារចែកទ្រូងផ្លូវជាពីរចំណែកខុសទិសគ្នា ឬចែកជាគន្លងផ្លូវគ្មានកន្លែងផ្លូវប្រសព្វលើផ្ទៃរាបមួយ ឬត្រូវមានផ្លូវប្រសព្វតិចបំផុតក្នុងករណីចាំបាច់ និងបំពាក់គ្រប់គ្រាន់នូវបរិក្ខារផ្លូវថ្នល់ដើម្បីធានានូវលំហូរចរាចរណ៍អត់ឈប់ សុវត្ថិភាព និងដើម្បីបន្ថយពេលវេលាធ្វើដំណើរ និងមានកន្លែងកំណត់សម្រាប់ឱ្យយានយន្តចេញ និងចូលផ្លូវល្បឿនលឿន។
- **បរិក្ខារផ្លូវថ្នល់** សំដៅដល់ទីចំណត ទីសំចត ភ្លើងសញ្ញា ផ្លាកសញ្ញាកំណត់ល្បឿន ផ្លាកសញ្ញាបង្ហាញផ្លូវ សញ្ញាចន្លោះគម្លាត គំនូសសញ្ញា ឬរបាំង ឬបរិក្ខារបែងចំណែកផ្លូវរង្វង់មូល ខឿនបែងចែកទិសចរាចរណ៍ ថ្មចិញ្ចើមផ្លូវ ជញ្ជាំង របងការពារ បង្គោលគីឡូម៉ែត្រ បង្គោលសញ្ញាកំណត់ព្រំ ព្រមទាំងផ្លាកសញ្ញា និងឧបករណ៍បំពាក់ផ្សេងទៀតនៅតាមបណ្តោយផ្លូវថ្នល់។
- **ទ្រូងផ្លូវ** សំដៅដល់ចំណែកនៃផ្លូវទុកសម្រាប់ឱ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍។
- **ជាយផ្លូវ** សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្រៅទីប្រជុំជន ដែលយានជំនិះអាចចតនៅទីនោះបានក្នុងករណីចាំបាច់។
- **ចិញ្ចើមផ្លូវ** សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្នុងទីប្រជុំជន ដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ដាំដើមឈើ និងបង្កប់បរិក្ខារបម្រើផលប្រយោជន៍សេវាសាធារណៈ។

- **គន្លងផ្លូវ** សំដៅដល់ចំណែកមួយនៃទ្រូងផ្លូវ ខណ្ឌដោយគំនូស ឬបរិក្ខារបែងចំណែកផ្លូវតាមបណ្តោយទ្រូងផ្លូវ ដែលមានទទឹងគ្រប់គ្រាន់អាចឱ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍បានមួយជួរ។
- **ទីប្រជុំជន** សំដៅដល់ទីកន្លែងដែលមានអគារ ឬគេហដ្ឋានសង់ជិតៗគ្នា ហើយផ្លូវចេញ ឬចូលនៅទីនោះមានដាក់ផ្លាកសញ្ញាប្រាប់ទីប្រជុំជន ឈ្មោះទីប្រជុំជនសម្គាល់ការចូល ឬឈ្មោះទីប្រជុំជនដែលមានគំនូសបន្ទាត់ទ្រូងពណ៌ក្រហមសម្គាល់ការចេញពីទីប្រជុំជនតាមដងផ្លូវ និងមានមនុស្សធ្វើចរាចរណ៍ឆ្លងកាត់ទៅមកច្រើន។
- **កន្លែងផ្លូវប្រសព្វ ឬផ្លូវប្រសព្វ** សំដៅដល់កន្លែងប្រសព្វនៃផ្លូវពីរ ឬច្រើន ដែលមានផ្ទៃតែមួយ និងមិនកំណត់មុំនៃអ័ក្សរបស់ទ្រូងផ្លូវឡើយ។ ផ្លូវប្រសព្វអាចមានរាងជា +, X, T, Y ឬ រង្វង់មូលជាដើម។
- **រង្វង់មូល** សំដៅដល់កន្លែងផ្លូវប្រសព្វដែលនៅចំកណ្តាលមានខឿនជារាងរង្វង់មូលមានផ្លាកសញ្ញាបង្ហាញទិសចរាចរណ៍ និងមានទ្រូងផ្លូវឯកទិសព័ទ្ធជុំវិញដោយសញ្ញាព្រួញប្រាប់ទិសចរាចរណ៍។
- **ច្រកចេញចូលផ្ទះឯកជន** សំដៅដល់ច្រកផ្លូវចេញចូលផ្ទះ ដែលមានផ្ទៃរាបស្មើភ្ជាប់ជាមួយផ្លូវសាធារណៈ និងមិនមែនជាចិញ្ចើមផ្លូវ។
- **ឈប់** សំដៅដល់ការនៅស្ងៀមនៃយានជំនិះលើទ្រូងផ្លូវមួយរយៈពេលខ្លី ដែលមានអ្នកបើកបរស្ថិតនៅជាប់នឹងចង្កូត ឬក្បែរយានជំនិះខ្លួន ដើម្បីឱ្យអ្នកដំណើរ ឬយានជំនិះដទៃទៀតឆ្លងកាត់ ឬដើម្បីអែបខាងដាក់ទំនិញ ឬអ្នកដំណើរឡើងចុះ។
- **ចត** សំដៅដល់ការទុកឱ្យយានជំនិះនៅស្ងៀមក្នុងរយៈពេលយូរ ឬឆាប់ដែលអ្នកបើកបរអាចដើរចោលយានជំនិះរបស់ខ្លួនបាន។
- **អ្នកបើកបរ** សំដៅដល់អ្នកបញ្ជាយានជំនិះគិតទាំងអ្នកជិះសត្វ អ្នកដឹកសត្វ និងអ្នកបរសត្វនៅលើផ្លូវ។
- **មួកសុវត្ថិភាព** សំដៅដល់មួកសុវត្ថិភាពតាមស្តង់ដាជាតិដែលទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ចសម្រាប់ពាក់នៅពេលធ្វើដំណើរតាមទោចក្រយានយន្ត ឬត្រីចក្រយានយន្ត ក្នុងគោលបំណងកាត់បន្ថយហានិភ័យនៃការរងរបួសក្បាលនៅពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង
- **ឧបករណ៍បច្ចេកទេស** សំដៅដល់ឧបករណ៍សម្រាប់ត្រួតពិនិត្យល្បឿន ឬជាតិអាល់កុល ឬសារធាតុញៀន ឬឧបករណ៍ប្រមូលរូបភាព និងព័ត៌មានជាអាទិ៍។
- **ឧបករណ៍សញ្ញា** សំដៅដល់ឧបករណ៍ប្រើប្រាស់ដោយភ្នាក់ងារចរាចរណ៍សម្រាប់ផ្តល់ជាសញ្ញាក្នុងការបញ្ជាឱ្យឈប់។ ឧបករណ៍សញ្ញានេះបញ្ចេញភ្លើងពណ៌ក្រហមនៅពេលងងឹត
- **យានជំនិះ ឬយាន** សំដៅដល់យានសម្រាប់ដឹកមនុស្ស ឬទំនិញនៅលើផ្លូវ ឬសម្រាប់សណ្តោង ឬត្រូវគេសណ្តោងទោះមាន ឬគ្មានម៉ាស៊ីន។
- **រថយន្តដឹកជញ្ជូនអ្នកដំណើរធុនតូច** សំដៅដល់រថយន្តដឹកអ្នកដំណើរមានចំណុះចាប់ពី១០(ដប់) នាក់ដល់២០(ម្ភៃ) នាក់ដោយគិតទាំងអ្នកបើកបរ។
- **រថយន្តដឹកជញ្ជូនអ្នកដំណើរធុនធំ** សំដៅដល់រថយន្តដឹកអ្នកដំណើរមានចំណុះលើសពី២០(ម្ភៃ)នាក់ដោយគិតទាំងអ្នកបើកបរ។
- **យានយន្ត** សំដៅដល់យានគ្រប់ប្រភេទដែលធ្វើចរាចរណ៍ដោយម៉ាស៊ីននៅលើផ្លូវថ្នល់។

Draft

- **រថយន្តគ្រួសារ** សំដៅដល់រថយន្ត ដែលមានផ្ទុកមនុស្សមិនលើសពី៩(ប្រាំបួន) នាក់ដោយគិតទាំងអ្នកបើកបរ។ រថយន្តប្រភេទនេះអាចត្រូវបានប្រើប្រាស់ជាលក្ខណៈគ្រួសារ។
- **រថយន្តធុនស្រាល** សំដៅដល់រថយន្តដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥ (បីក្បៀសប្រាំ) តោនឡើងទៅ។
- **រថយន្តក្រុង** សំដៅដល់រថយន្តដឹកជញ្ជូនអ្នកដំណើរធុនធំដែលបម្រើសេវាដឹកជញ្ជូនសាធារណៈលើកំណាត់ផ្លូវមានកំណត់ក្នុងរាជធានី ឬទីក្រុង និងយកកម្រៃ។
- **យានយន្តកសិកម្មកែច្នៃ** សំដៅដល់យានយន្តបករណ៍កែច្នៃសម្រាប់បម្រើការងារកសិកម្មដូចជាយានយន្តច្រូតស្រូវ យានយន្តបោកបែនស្រូវ និងយានយន្តកិនស្រូវជាអាទិ៍
- **យានយន្តុបករណ៍** សំដៅដល់យានពិសេសដែលមានឧបករណ៍ គ្រឿងចក្របំពាក់បន្ថែមគ្មានផ្ទុកមនុស្ស ឬគ្មានផ្ទុកទំនិញនៅក្រៅកាប៊ីន ដូចជារថយន្តលាយស៊ីម៉ងត៍ ឬរថយន្តសម្រាប់បម្រើការងារសាងសង់ផ្លូវស្ពានជាអាទិ៍។
- **រថយន្តធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ និងអ្នកដំណើរ** សំដៅដល់រថយន្តធ្វើអាជីវកម្មដឹកជញ្ជូនទំនិញរបស់អ្នកដទៃ ឬផ្ទាល់ខ្លួន និងដឹកជញ្ជូនអ្នកដំណើរ
- **អ្នកប្រើប្រាស់ផ្លូវ** សំដៅដល់អ្នកបើកបរ និងថ្មើរជើងដែលធ្វើដំណើរនៅលើផ្លូវ
- **ទម្ងន់ទទេរបស់យាន** សំដៅដល់ទម្ងន់របស់យានដែលគ្មានមនុស្ស ឬគ្មានទំនិញ ប៉ុន្តែមានប្រេងឥន្ធនៈសម្រាប់ផ្តល់ឱ្យយាន មានឧបករណ៍ជួសជុល និងកង់បម្រុង
- **ទម្ងន់ផ្ទុកអតិបរមារបស់យាន** សំដៅដល់ផលបូកទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញដែលកំណត់ដោយរោងចក្រផលិតយាន។
- **ទម្ងន់សរុបអតិបរមារបស់យាន** សំដៅដល់ផលបូកសរុបទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកអតិបរមារបស់យាន។ ប្រសិនបើយានមានសណ្តោង ទម្ងន់សរុបអតិបរមារបស់យាន គឺជាផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ
- **ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន** សំដៅដល់ផលបូកទម្ងន់ទទេរបស់យានជាមួយ នឹងទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញអនុញ្ញាត។ ប្រសិនបើយានមានសណ្តោងទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន គឺជាផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ
- **ទម្ងន់សរុបជាក់ស្តែងរបស់យាន** សំដៅដល់ផលបូកទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញជាក់ស្តែង
- **ទំនិញ** សំដៅដល់សម្ភារ វត្ថុ ដី ថ្ម ក្រួស ខ្សាច់ ប្រេងឥន្ធនៈ សត្វ និងវត្ថុផ្សេងៗទៀត ដែលដឹកជញ្ជូនតាមយានជំនិះ។
- **រ៉ឺម៉ក** សំដៅដល់យានសម្រាប់ថ្កក់ជាមួយរថយន្ត ឬយានជំនិះផ្សេងទៀត
- **សឺមីរ៉ឺម៉ក** សំដៅដល់យានសម្រាប់ថ្កក់ជាប់នឹងក្បាលរថយន្តសណ្តោង។

• មាត្រា៥: សញ្ញាចរាចរណ៍ផ្លូវគោករួមមានផ្លាកសញ្ញាចរាចរណ៍នៅតាមផ្លូវ ភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍នៅលើផ្លូវសញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ និងសញ្ញាផ្សេងៗទៀត។

ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍រនៅលើផ្លូវ ត្រូវរៀបចំជាប្រព័ន្ធទាក់ទងស៊ីចង្វាក់គ្នាជាហូរហែនៅតាមកន្លែងមានសារប្រយោជន៍ ដែលធ្វើឱ្យអ្នកប្រើប្រាស់ផ្លូវងាយស្រួលមើលឃើញ។

សញ្ញាគ្រោះថ្នាក់នៅតាមដងផ្លូវ ដែលមានលក្ខណៈមិនអចិន្ត្រៃយ៍ ត្រូវដាក់ក្នុងចម្ងាយសមស្របល្មមគ្រប់គ្រាន់តាមប្រភេទផ្លូវ ចំណាត់ថ្នាក់ផ្លូវ និងស្ថានភាពផ្លូវដែលអាចធ្វើឱ្យអ្នកបើកបរមានស្មារតីប្រុងប្រយ័ត្នជាមុន។

ហាមបិទក្រដាស ឬរបស់ផ្សេងៗទៀត ឬគូសវាសនៅលើផ្លាកសញ្ញា ឬប្រើប្រាស់ទម្រផ្លាកសញ្ញា ឬនៅលើសម្ភារអ្វីផ្សេងៗទៀត ដែលប្រើប្រាស់សម្រាប់សញ្ញាចរាចរណ៍ ដែលជាហេតុធ្វើឱ្យអ្នកបើកបរមិនអាចមើលឃើញសញ្ញាចរាចរណ៍ច្បាស់បានល្អ ឬយល់ខ្លឹមសារសញ្ញាចរាចរណ៍មិនបានត្រឹមត្រូវ ឬធ្វើឱ្យអ្នកបើកបរចាំងភ្នែក។

រូបភាពនិងខ្លឹមសារស្ដីពីសញ្ញាចរាចរណ៍ផ្លូវគោក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន។

- **មាត្រា១៧**: ក្នុងគ្រប់ករណីអ្នកបើកបរត្រូវគ្រប់គ្រងលើល្បឿនបើកបររបស់ខ្លួនជានិច្ច ហើយត្រូវបើកបរក្នុងល្បឿនសមស្របទៅតាមស្ថានភាពជាក់ស្ដែង ដើម្បីអាចបញ្ឈប់យានជំនិះបានទាន់ពេលវេលា និងដោយគ្មានគ្រោះថ្នាក់។

អ្នកបើកបរត្រូវបន្ថយល្បឿន ក្នុងករណីដូចខាងក្រោមៈ

១- ពេលជៀសគ្នានៅលើផ្លូវចង្អៀត។

២- ពេលជៀសរថយន្តដឹកជញ្ជូនអ្នកដំណើរ ឬរថយន្តដឹកជញ្ជូនកុមារ ដែលកំពុងឈប់ដាក់អ្នកដំណើរ ឬកុមារឡើងចុះ។

៣- ពេលទៅជិតដល់ស្ពាន ឬជិតដល់ផ្លូវរថភ្លើងកាត់។

៤- ពេលអាកាសធាតុមិនល្អដែលមិនអាចមើលឃើញបានឆ្ងាយ និងច្បាស់។

៥- ពេលប្ដូរទិសចរាចរណ៍។

៦- កន្លែងផ្លូវបត់ ផ្លូវកោង ផ្លូវរអិល ផ្លូវប្រសព្វ ឬរង្វង់មូល។

៧- ពេលជិតដល់ទួលខ្ពស់ ឬពេលចុះចំណោត។

៨- ពេលជៀស ឬជែងក្បួនយានកំពុងឈប់ ឬនៅពេលជៀស ឬជែងក្បួនដង្ហែផ្សេងៗ។

- **មាត្រា២៣**: ការឈប់និងការចតនៅលើផ្លូវថ្នល់ ត្រូវអនុវត្តន៍ដូចខាងក្រោមៈ

១- គ្រប់យានជំនិះដែលឈប់ ឬចត មិនត្រូវបង្កឱ្យរំខានដល់យានជំនិះផ្សេងៗ ទៀតដែលកំពុងធ្វើចរាចរណ៍។

២- នៅក្នុងទីប្រជុំជន គ្រប់យានជំនិះត្រូវឈប់ ឬចតនៅតាមទិសដែលខ្លួនកំពុងធ្វើចរាចរណ៍ដោយអនុវត្តន៍តាមបទប្បញ្ញត្តិដូចខាងក្រោមៈ

- ចំពោះទ្រូងផ្លូវដែលមានទិសចរាចរណ៍ពីរ ត្រូវចតឬឈប់ខាងស្ដាំតាមទិសចរាចរណ៍របស់ខ្លួន
- ចំពោះទ្រូងផ្លូវឯកទិស ត្រូវចត ឬឈប់ខាងស្ដាំ ឬខាងឆ្វេងតាមទិសចរាចរណ៍

៣- នៅក្រៅទីប្រជុំជន យានជំនិះ ឬសត្វពាហនៈត្រូវឈប់ ឬចតនៅក្រោមទ្រូងផ្លូវ។ បើគ្មានទីណាផ្សេងទៀត យានជំនិះអាចចតបានក្រៅពីទ្រូងផ្លូវទេនោះ ត្រូវអនុវត្តន៍តាមបទប្បញ្ញត្តិ ដែលមានចែងក្នុងចំណុចទី១ ខាងលើ

៤- នៅក្រៅទីប្រជុំជន គ្រប់យានជំនិះដែលខូចគាំង ឬត្រូវបង្ខំឱ្យឈប់ ឬចតបានលើទ្រូងផ្លូវត្រូវប្រើភ្លើងសញ្ញាអាសន្ន ឬដាក់សញ្ញាត្រីកោណចម្ងាយយ៉ាងតិច ៣០(សាមសិប)ម៉ែត្រ ដែលអាចមើលឃើញយ៉ាងតិច១០០(មួយរយម៉ែត្រ)។ ក្នុងករណីបញ្ហាខាងលើនេះ កើតឡើងនៅកន្លែងហាមឈប់ ឬចតត្រូវជូនដំណឹងដល់សមត្ថកិច្ចដែលនៅជិតដើម្បីមានវិធានការបន្ថែម។

៥- នៅក្នុងទីប្រជុំជន គ្រប់យានជំនិះត្រូវឈប់ឬចតដាក់ទំនិញ ឬមនុស្សឡើងចុះនៅចម្ងាយ មិនលើសពី២៥ (ម្ភៃប្រាំ) សង់ទីម៉ែត្រពីគែមចិញ្ចើមផ្លូវ និងយ៉ាងតិច៥ (ប្រាំ) ម៉ែត្រពីផ្លូវប្រសព្វ ឬ

ផ្លូវបត់ ឬផ្លូវកោង និងចន្លោះយ៉ាងតិច១០(ដប់)ម៉ែត្រពីផ្លូវប្រសព្វ ឬផ្លូវបត់ ឬផ្លូវកោងនៃមហាវិថី។ នៅក្រៅទីប្រជុំជន យានទាំងអស់ត្រូវឈប់ ឬចតយ៉ាងតិចបំផុត ១០ (ដប់) ម៉ែត្រពីផ្លូវប្រសព្វ ឬផ្លូវបត់ ឬផ្លូវកោង។

៦- ក្នុងការចតមុនពេលដើរឆ្ងាយពីយានជំនិះរបស់ខ្លួន អ្នកបើកបរត្រូវចាប់ហ្វ្រាំងដៃ ឬមានវិធានការផ្សេងៗ ដើម្បីការពារគ្រោះថ្នាក់ជាយថាហេតុ នៅពេលដែលខ្លួនអវត្តមាន។

៧- ហាមឈប់ ឬចតយានជំនិះនៅទីកន្លែងដូចខាងក្រោម៖

- នៅលើទ្រូងផ្លូវ ចិញ្ចើមផ្លូវដែលទុកបម្រុងឱ្យថ្មើរជើង និងក្នុងចន្លោះយ៉ាងតិច ៥(ប្រាំ) ម៉ែត្រពីមុខគំនូសឆ្នូតកាត់ទទឹងទ្រូងផ្លូវ សម្រាប់ថ្មើរជើងឬនៅលើគំនូសនេះ នៅលើផ្លូវ សម្រាប់ថ្មើរជើង
- លើកន្លែងបម្រុងទុកសម្រាប់ការឈប់ ឬចតនៃយានប្រភេទខ្លះ
- នៅចន្លោះគែមទ្រូងផ្លូវ និងខ្សែគំនូសបង្ខូត ប្រសិនបើនៅចន្លោះគំនូសបង្ខូត និងយានចតនេះតិចជាង ៣(បី) ម៉ែត្រ ដែលមិនអាចឱ្យយានមួយផ្សេងទៀត បរបានដោយឥតឆ្លងកាត់ ឬជាន់លើខ្សែគំនូសបង្ខូត
- នៅជិតបង្គោលភ្លើងសញ្ញាចរាចរណ៍ ឬផ្លាកសញ្ញាចរាចរណ៍ ដែលធ្វើឱ្យបាំងភ្នែកអ្នកប្រើប្រាស់ផ្លូវមិនអាចមើលឃើញ សញ្ញាចរាចរណ៍ទាំងនេះបាន
- នៅគ្រប់ទីកន្លែងដែលធ្វើឱ្យរាំងស្ទះដល់ច្រកចេញចូល ការចត ឬការឈប់នៃយានដទៃទៀត
- នៅលើស្ពាន លើផ្លូវក្រោមស្ពាន លើផ្លូវរូង លើផ្លូវប្រសព្វ លើផ្លូវកាត់ផ្លូវរថភ្លើង លើផ្លូវ ក្នុងរង្វង់មូល ផ្លូវកោងខ្លាំង ឬផ្លូវចោតខ្លាំងដែលមិនអាចមើលយានផ្សេងទៀតពីចម្ងាយបាន
- នៅចន្លោះតិចជាង ២០(ម្ភៃ) ម៉ែត្រពីផ្លូវរថភ្លើងឆ្លងកាត់
- នៅចន្លោះតិចជាង១០(ដប់) ម៉ែត្រពីមុខ និងពីក្រោយទីតាំងបូមទឹករបស់យានពន្លត់អគ្គីភ័យ និងនៅមុខស្ថានីយពន្លត់អគ្គីភ័យ
- លើច្រកចេញចូលនៃអគារសាធារណៈ
- នៅលើទ្រូងផ្លូវមុខច្រកចេញចូលផ្ទះឯកជន លើកលែងតែយានរបស់ម្ចាស់ផ្ទះ ដែលជា កម្មសិទ្ធិតែមួយ
- ជាពីជួរទន្ទឹមគ្នា
- នៅលើគែមទ្រូងផ្លូវម្ខាង បើនៅគែម ម្ខាងទៀតដែលឈមុខគ្នាជាកន្លែងទុកសម្រាប់ឱ្យ យានជំនិះចត លើកលែងតែក្នុងករណីដែលអាចចតបានទាំងសងខាង
- ជាកន្លែងដែលមានសញ្ញាហាមឈប់ ឬហាមចត
- នៅលើទ្រូងផ្លូវថ្នល់លើសពី ២៤ ម៉ោង
- នៅចន្លោះតិចជាង១០(ដប់)ម៉ែត្រពីមុខ និងពីក្រោយផ្លាកសញ្ញាកន្លែងរបស់រថយន្តក្រុងឈប់
- នៅចន្លោះតិចជាង ១(មួយ)ម៉ែត្រពីមុខ ឬពីក្រោយរថយន្តដែលឈប់ ឬចតបន្តកន្ទុយគ្នា
- នៅជិតផ្លូវប្រសព្វ ឬផ្លូវបត់។

- **មាត្រា២៦**: នៅពេលមានថ្មើរជើងឆ្លងកាត់ អ្នកបើកបរត្រូវអនុវត្តន៍ដូចខាងក្រោម ៖

១- គ្រប់ករណីទាំងអស់ អ្នកបើកបរត្រូវតែឈប់នៅពេលថ្មើរជើងកំពុងឆ្លងកាត់ ឬរៀបនឹងឆ្លងកាត់ នៅកន្លែងដែលមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

២- នៅត្រង់កន្លែងផ្លូវប្រសព្វ ឬនៅជិតកៀកផ្លូវប្រសព្វ អ្នកបើកបរត្រូវហាមឃាត់ក្នុងការធ្វើឱ្យអាក់ខាន ឬរាំងស្ទះដល់ថ្មើរជើងដែលកំពុងឆ្លងកាត់ទ្រូងផ្លូវ ទោះបីគ្មានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់



Draft

ក៏ដោយ

៣- ក្នុងករណីមានគំនូសសញ្ញាសម្រាប់ថ្មើរឆ្លងកាត់ នៅត្រង់ផ្លូវប្រសព្វដែលមានភ្លើងសញ្ញាចរាចរណ៍ ឬមានភ្នាក់ងារបញ្ជាចរាចរណ៍នៅទីនោះ ទោះបីមានភ្លើងពណ៌បៃតង ឬមានសញ្ញាភ្នាក់ងារ ឱ្យទៅមុខក៏ដោយ អ្នកបើកបរមិនត្រូវធ្វើឱ្យរំខាន ឬធ្វើឱ្យរាំងស្ទះដល់ថ្មើរជើងដែលកំពុងឆ្លងកាត់ នៅលើគំនូសសញ្ញាថ្មើរជើងឆ្លងកាត់ឡើយ។ ចំពោះអ្នកបើកបរ ដែលបត់ចូលទ្រូងផ្លូវផ្សេងទៀត ហើយនៅទ្រូងផ្លូវនោះមានថ្មើរជើងកំពុងឆ្លងកាត់ អ្នកបើកបរត្រូវបន្ថយល្បឿន បើចាំបាច់ត្រូវឈប់ ដើម្បីផ្តល់សិទ្ធិឱ្យថ្មើរជើងឆ្លងកាត់រួចរាល់សិន។

៤- ក្នុងករណីមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់នៅត្រង់ផ្លូវប្រសព្វដែរគ្មានភ្លើងសញ្ញាចរាចរណ៍ ឬគ្មានភ្នាក់ងារបញ្ជាចរាចរណ៍នៅទីនោះ អ្នកបើកបរត្រូវបន្ថយល្បឿន ឬត្រូវឈប់ដើម្បីផ្តល់សិទ្ធិឱ្យថ្មើរជើងដែលកំពុងឆ្លងកាត់ ឬរៀបនឹងឆ្លងកាត់។

- **មាត្រា៥១**: ម្ចាស់យានយន្តដែលតម្រូវឱ្យមានការធានារ៉ាប់រង ជាកាតព្វកិច្ចធានារ៉ាប់រងស្របតាមច្បាប់ស្តីពីការធានារ៉ាប់រង និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការធានារ៉ាប់រង នៅពេលដែលយានយន្តត្រូវបានយកទៅធ្វើចរាចរណ៍នៅលើផ្លូវថ្នល់។
- **មាត្រា៥៥**: គ្រប់យានយន្ត ឬរ៉ឺម៉កដែលកំពុងធ្វើសកម្មភាព អាជីវកម្មដឹកជញ្ជូន ត្រូវមាន ៖
  - ក- បណ្ណសម្គាល់យានយន្ត ឬបណ្ណសម្គាល់រ៉ឺម៉ក និងផ្លាកលេខ
  - ខ- បណ្ណបើកបរត្រឹមត្រូវតាមប្រភេទយានយន្ត
  - គ- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត
  - ឃ- លិខិតអនុញ្ញាតឱ្យយានយន្ត ឬរ៉ឺម៉កធ្វើអាជីវកម្មដឹកជញ្ជូន
  - ង- វិញ្ញាបនបត្រធានារ៉ាប់រងចេញដោយក្រុមហ៊ុនធានារ៉ាប់រង
  - ច- លិខិតអនុញ្ញាតផ្សេងទៀតចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។
- **មាត្រា៥៧**: ការផ្ទុកទំនិញលើរថយន្ត រ៉ឺម៉ក ឬសឺមីរ៉ឺម៉ក មិនត្រូវឱ្យលើសទម្ងន់សរុបអតិបរមារបស់យាន ដែលកំណត់ដោយរោងចក្រ ផលិតយាន និងមិនត្រូវឱ្យលើសទម្ងន់អតិបរមាសង្កត់លើភ្លៅ និងទម្ងន់សរុបអតិបរមា របស់យានដែលបានអនុញ្ញាតដូចមានចែងក្នុងច្បាប់ស្តីពីផ្លូវថ្នល់។

នៅពេលឆ្លងកាត់ស្ពាន គ្រប់អ្នកបើកបររថយន្ត រថយន្តសណ្តោងរ៉ឺម៉ក ឬសឺមីរ៉ឺម៉ក ត្រូវគោរពតាមទម្ងន់សរុបអនុញ្ញាតអតិបរមាដែលកំណត់ក្នុងស្លាកសញ្ញាដាក់តាំងនៅពីមុខស្ពាន។

ទំហំរថយន្ត និងរថយន្តសណ្តោងរ៉ឺម៉ក ឬសឺមីរ៉ឺម៉ក ត្រូវដូចខាងក្រោម ៖

- ប្រវែងទទឹងអតិបរមាមិនត្រូវឱ្យលើស ២,៥០ (ពីរក្បៀសហាសិប) ម៉ែត្រ លើកលែងតែ យានយន្តបករណ៍ដែលមិនត្រូវឱ្យលើសពី ៣ (បី) ម៉ែត្រ
- ប្រវែងកម្ពស់អតិបរមាមិនត្រូវឱ្យលើសពី៤,២០(បួនក្បៀសម្ភៃ) ម៉ែត្រ
- ប្រវែងបណ្តោយអតិបរមានៃរថយន្តនីមួយៗមិនត្រូវឱ្យលើសពី១២,២០ (ដប់ពីរក្បៀសម្ភៃ) ម៉ែត្រ
- ប្រវែងបណ្តោយអតិបរមានៃរថយន្តនីមួយៗ ដែលមានសណ្តោងសឺមីរ៉ឺម៉ក មិនត្រូវឱ្យលើសពី ១៦ (ដប់ប្រាំមួយ) ម៉ែត្រ
- ប្រវែងបណ្តោយអតិបរមានៃរថយន្តនីមួយៗ ដែលមានសណ្តោងរ៉ឺម៉កមិនត្រូវឱ្យលើសពី១៨ (ដប់ប្រាំបី) ម៉ែត្រ

ទំហំអតិបរមារថយន្ត និងរថយន្តសណ្តោងរ៉ឺម៉ក ឬសឺមីរ៉ឺម៉កដែលគ្មានចែងនៅក្នុងចំណុចខាងលើនេះ ត្រូវសុំលិខិតអនុញ្ញាតពិសេសពីរដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន បទដ្ឋានបច្ចេកទេសលម្អិត ស្តីពីទំហំ និងទម្ងន់យានជំនិះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

Draft

- **មាត្រា៩២:** ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃ ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៧ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ។

## ៣.២២. ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ឆ្នាំ ១៩៩៦

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនាសម័យប្រជុំរដ្ឋសភា លើកទី៥ នីតិកាលទី១ និងបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ នាថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលមានមាត្រាពាក់ព័ន្ធនឹងគម្រោងមានដូចតទៅៈ

- **មាត្រា១:** ច្បាប់នេះមានគោលដៅថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិនិងសម្បត្តិវប្បធម៌ទូទៅ ប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូលដោយខុសច្បាប់ ។

- **មាត្រា២:** បេតិកភណ្ឌវប្បធម៌ជាតិគឺជាសម្បត្តិវប្បធម៌ដែលត្រូវបានបង្កើតឡើង ឬក៏បានរកឃើញនៅក្នុងទឹកដីនៃមាតុភូមិ។

- **មាត្រា៣:** ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ជាចលនៈ និងអចលនៈ ទោះបីជាកម្មសិទ្ធិសាធារណៈក្តី ឬជាឯកជនក្តី ហើយកិច្ចការពារនេះគឺជាផលប្រយោជន៍សាធារណៈ។

  លើកលែងតែមានបទបញ្ញត្តិផ្ទុយពីច្បាប់នេះ ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ដែលជាចំណែកនៃបេតិកភណ្ឌវប្បធម៌ជាតិតែប៉ុណ្ណោះ។

- **មាត្រា៣៧:** នៅពេលកំពុងដំណើរការការងារផ្សេងៗ ឬសកម្មភាពផ្សេងៗទៀត ហើយបានប្រទះសម្បត្តិវប្បធម៌ដូចជាប្រាសាទបាក់បែក វត្ថុបុរាណ សំណល់ផ្ទះសំបែងបុរាណ ទីបញ្ចុះសពបុរាណ សិលាចារឹក ឬសម្បត្តិវប្បធម៌ដែលទាក់ទងដល់បុរេប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យា ឬក៏សាខាដទៃទៀតនៃវិទ្យាសាស្ត្រ ដែលសិក្សាពីអតីតកាលមនុស្សសាស្ត្រ អ្នកដែលប្រទះឃើញ សម្បត្តិទាំងនេះនិងម្ចាស់អចលនវត្ថុ ត្រូវតែបញ្ឈប់ការងារ ឬសកម្មភាពនោះ រួចរាយការណ៍បន្ទាន់ជូនភ្នាក់ងារនគរបាលក្នុងតំបន់។ ភ្នាក់ងារនគរបាលនោះ ត្រូវបញ្ជូនរបាយការណ៍នេះយ៉ាងប្រញាប់ជូនទៅអភិបាលខេត្ត-ក្រុង។ អភិបាលខេត្ត-ក្រុង ត្រូវជូនពត៌មាននេះដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់វិធានការចាំបាច់ ដើម្បីធានាសង្គ្រោះសម្បត្តិវប្បធម៌និងរមណីយដ្ឋានវប្បធម៌នោះ។

- **មាត្រា៣៨:** ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលសេចក្តីរាយការណ៍ដូចបានចែងក្នុងមាត្រា៣៧ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ជាលាយល័ក្ខណ៍អក្សរ ស្តីពីការផ្អាកជាបណ្តោះអាសន្ននូវការងារជួលជុល ឬសាងសង់ និងស្តីពីវិធានការសង្គ្រោះដែលត្រូវអនុវត្ត។

  បើក្នុងរយៈពេល ៣០ថ្ងៃ អាជ្ញាធរមានសមត្ថកិច្ចមិនបានធ្វើកំណត់ជាលាយល័ក្ខណ៍អក្សរជូនពត៌មានទៅម្ចាស់អចនវត្ថុទេនោះ ការផ្អាកជាបណ្តោះអាសន្នត្រូវទុកជាអាសារបង់។

  អាជ្ញាធរមានសមត្ថកិច្ចត្រូវសំរេចជាស្ថាពរនូវវិធានការចំពោះការប្រទះឃើញដោយចៃដន្យ។

-**មាត្រា៣៩:** សម្បត្តិវប្បធម៌ជាចលនវត្ថុដែលប្រទះឃើញដោយចៃដន្យ ត្រូវចាត់ទុកជាសម្បត្តិសាធារណៈ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកប្រទះឃើញដោយចៃដន្យ ដោយកំណត់តាមការស្រុះស្រួលគ្នា ឬតាមការវាយតម្លៃរបស់អ្នកជំនាញ ក្នុងរយៈពេលបីសប្តាហ៍ក្រោយពីបានរកឃើញ។

## ៣.២៣. ច្បាប់ស្តីពីសម្បទាន ឆ្នាំ ២០០៧

ច្បាប់ ស្តីពីសម្បទាន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វី

Draft

ឡើយ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានមាត្រាពាក់ព័ន្ធ និងគម្រោងនេះដូចតទៅះ

- **មាត្រា១:** ច្បាប់នេះមានគោលបំណងជំរុញ និងសម្រួលការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដោយហិរញ្ញប្បទានឯកជននៅព្រះរាជាណាចក្រកម្ពុជា ដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងបំពេញសេចក្តីត្រូវការរបស់សង្គម និងសេដ្ឋកិច្ចជាតិ។
- **មាត្រា២:** ច្បាប់នេះមានវិសាលភាពគ្រប់គ្រងសម្បទានទាំងឡាយ ដូចមានចែងក្នុងមាត្រា៥ នៃច្បាប់នេះ។

  សម្បទានត្រូវផ្តល់តាមរយៈកិច្ចសន្យាសម្បទាន ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ។
- **មាត្រា៣:** វាក្យស័ព្ទសំខាន់ៗនៅក្នុងច្បាប់នេះមានន័យដូចខាងក្រោមះ

  - **ការអនុញ្ញាត** សំដៅដល់ការអនុញ្ញាត ការជម្រះបញ្ជី ការយល់ព្រម ការផ្តល់អាជ្ញាប័ណ្ណ ការផ្តល់លិខិតអនុញ្ញាត ឬការចុះបញ្ជីនានា ដែលត្រូវទទួលយកពីស្ថាប័នមានសមត្ថកិច្ច ដើម្បីអនុវត្តន៍គម្រោងសម្បទានដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

  - **សម្បទាន** សំដៅដល់ទង្វើណាមួយជារបស់រដ្ឋ ដែលស្ថាប័នមានសមត្ថកិច្ចផ្តល់ទង្វើនោះ ទៅឱ្យឯកជននៃផ្នែកណាមួយ ឬទាំងស្រុងនៃការអនុវត្តគម្រោងលើផ្នែកហេដ្ឋារចនាសម្ព័ន្ធណាមួយ ដែលជាធម្មតាស្ថាប័នមានសមត្ថកិច្ចនោះ ជាអ្នកទទួលខុសត្រូវ ហើយដែលឯកជននោះ ទទួលភារកិច្ចមួយផ្នែកធំលើការសាងសង់ និង/ឬហានិភ័យ ឬទទួលបាននូវផលចំណេញ តាមរយៈការទូទាត់សងវិញពីរដ្ឋាភិបាលនូវប្រាក់ចំណូល ឬកម្រៃ និងការយកថ្លៃឈ្នួល ដែលបានប្រមូលយកមកពីអ្នកប្រើប្រាស់ ឬពីអតិថិជន។ ទង្វើរបស់រដ្ឋទាំងនោះ ចាប់ពីពេលនេះតទៅនឹងត្រូវកំណត់ថា "សម្បទាន" នៅក្រោមច្បាប់នេះ ដោយមិនគិតពីឈ្មោះស្របច្បាប់ដែលបានប្រើប្រាស់សម្រាប់ទង្វើនោះឡើយ។

  - **សម្បទានិក** សំដៅដល់បុគ្គល ដែលអនុវត្តន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្រោមកិច្ចសន្យាសម្បទាន ដែលបានធ្វើជាមួយស្ថាប័នជាប់កិច្ចសន្យា។

  - **កិច្ចសន្យាសម្បទាន** សំដៅដល់កិច្ចព្រមព្រៀងដែលភ្ជាប់កាតព្វកិច្ចទៅវិញទៅមក រវាងស្ថាប័នជាប់កិច្ចសន្យាជាមួយសម្បទានិក ក្នុងនោះមានកំណត់ពីគោលការណ៍ និងលក្ខខណ្ឌសម្រាប់អនុវត្តន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធ។

  - **បុគ្គល** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល។

  - **គម្រោងសម្បទាន** សំដៅដល់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ នៅក្រោមការផ្តល់សម្បទានណាមួយ។

  - **ស្ថាប័នជាប់កិច្ចសន្យា** សំដៅដល់ស្ថាប័នមានសមត្ថកិច្ចដែលមានសិទ្ធិចុះកិច្ចសន្យាសម្បទាន ដូចមានចែងក្នុងមាត្រា៤ នៃច្បាប់នេះ។

  - **សំណង់ហេដ្ឋារចនាសម្ព័ន្ធ** សំដៅដល់សំណង់ជារូបវន្ត និងប្រព័ន្ធដែលផ្តល់សេវាកម្មដោយផ្ទាល់ ឬដោយប្រយោលដល់សាធារណជនទូទៅ។

  - **គម្រោងហេដ្ឋារចនាសម្ព័ន្ធ** សំដៅដល់គំនូរប្លង់ ការសាងសង់ ការថែទាំ ឬការធ្វើអាជីវកម្មនៃសំណង់ហេដ្ឋារចនាសម្ព័ន្ធថ្មី ឬការធ្វើទំនើបភាវូបនីយកម្ម ការធ្វើនីតិសម្បទា ការពង្រីក ការគ្រប់គ្រង ឬការធ្វើអាជីវកម្មនៃសំណង់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។

- **គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** សំដៅដល់គម្រោងវិនិយោគដែលទទួលបាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយអនុលោមទៅតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

- **មាត្រា៥:** កិច្ចសន្យាសម្បទាន ដែលមានទំនាក់ទំនងទៅនឹងសំណង់ហេដ្ឋារចនាសម្ព័ន្ធតាមរយៈការផ្គត់ផ្គង់សេវាដោយផ្ទាល់ ឬដោយប្រយោល ដើម្បីជាប្រយោជន៍សាធារណៈត្រូវបានចូលរួមដោយស្ថាប័នពាក់ព័ន្ធលើវិស័យដូចតទៅ៖

ក- ការផលិត ការបញ្ជូន និងការចែកចាយ ថាមពលអគ្គិសនី។

ខ- ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធដឹកជញ្ជូន មានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ព្រលាន យន្តហោះ កំពង់ផែ ផ្លូវដែក ព្រែកជីក។

គ- ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ។

ឃ- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន។

ង- ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្ភារ បម្រើឱ្យគម្រោងផ្នែកទេសចរណ៍មានជាអាទិ៍ រមណីយដ្ឋានទេសចរណ៍ សារមន្ទីរ។

ច- ហេដ្ឋារចនាសម្ព័ន្ធ បម្រើឱ្យវិស័យឧស្ម័ន និងប្រេង មានជាអាទិ៍ បំពង់បង្ហូរប្រេង និងឧស្ម័ន។

ឆ- ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបូមស្តារ។

ជ- ប្រព្រឹត្តិកម្ម និងការគ្រប់គ្រងសំណល់។

ឈ- ហេដ្ឋារចនាសម្ព័ន្ធសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ និងវិស័យកីឡា។

ញ- ហេដ្ឋារចនាសម្ព័ន្ធ បម្រើឱ្យតំបន់សេដ្ឋកិច្ចពិសេស និងលំនៅឋានសង្គម។

ដ- ហេដ្ឋារចនាសម្ព័ន្ធ បម្រើឱ្យប្រព័ន្ធធារាសាស្ត្រ និងការងារកសិកម្ម។

ឋ- វិស័យផ្សេងៗទៀត ដែលច្បាប់ដោយឡែកណាមួយអនុញ្ញាតឱ្យមានការផ្តល់នូវសម្បទាន។

- **មាត្រា៦:** កិច្ចសន្យាសម្បទាន អាចអនុវត្តន៍តាមទម្រង់ដូចខាងក្រោម៖
  - សាងសង់ អាជីវកម្ម និងផ្ទេរ
  - សាងសង់ ជួល និងផ្ទេរ
  - សាងសង់ ផ្ទេរ និងអាជីវកម្ម
  - សាងសង់ ធ្វើម្ចាស់ និងអាជីវកម្ម
  - សាងសង់ ធ្វើម្ចាស់ អាជីវកម្ម និងផ្ទេរ
  - សាងសង់ សហការ និងផ្ទេរ
  - ពង្រីក អាជីវកម្ម និងផ្ទេរ
  - ទំនើបភាវូបនីយកម្ម អាជីវកម្ម និងផ្ទេរ
  - ទំនើបភាវូបនីយកម្ម ធ្វើម្ចាស់ និងអាជីវកម្ម

- ជួល និងអាជីវកម្ម គ្រប់គ្រង ឬកិច្ចព្រមព្រៀងគ្រប់គ្រង ឬជម្រើសដទៃទៀតនៃទម្រង់ទាំងនោះ ឬទម្រង់ប្រហាក់ប្រហែល ដោយរួមបញ្ចូលទាំងការអនុវត្តសំណង់ហេដ្ឋារចនាសម្ព័ន្ធនៃសម្ព័ន្ធអាជីវកម្មរួមរវាងសាធារណៈ និងឯកជន។

- **មាត្រា៧:** កិច្ចសន្យាសម្បទានណាមួយអាចត្រូវចាប់ផ្តើមធ្វើបាន លុះត្រាតែគម្រោងហេដ្ឋារចនាសម្ព័ន្ធនោះ ត្រូវបានអនុម័តជាមុនថាជាគម្រោងសម្បទានស្របតាមនីតិវិធីដែលមានចែងនៅក្នុងអនុក្រឹត្យ។
- **<u>មាត្រា១១:</u>** ស្ថាប័នជាប់កិច្ចសន្យា ត្រូវធ្វើការជ្រើសរើសសម្បទានិក តាមវិធីដេញថ្លៃជាលក្ខណៈជាតិ ឬអន្តរជាតិ ឬ តាមនីតិវិធីចរចា ដោយផ្អែកទៅតាមកាលៈទេសៈ។

  នីតិវិធីនៃការជ្រើសរើសសម្បទានិកនឹងមានចែងនៅក្នុងអនុក្រឹត្យ។
- **<u>មាត្រា១២:</u>** នៅពេលដែលដំណើរការជ្រើសរើសសម្បទានិកត្រូវបានបំពេញសព្វគ្រប់ ហើយស្ថាប័នជាប់កិច្ចសន្យាក៏បានត្រៀមក្នុងការទទួលពាក្យដេញថ្លៃចុងក្រោយ ឬការស្នើចរចាហើយនោះ ស្ថាប័នជាប់កិច្ចសន្យាត្រូវតែទទួលបាននូវការអនុម័តជាគោលការណ៍សម្រាប់លក្ខខណ្ឌចុងក្រោយនៃកិច្ចសន្យាសម្បទាន តាមការតម្រូវនឹងស្របតាមនីតិវិធីដែលនឹងមានចែងនៅក្នុងអនុក្រឹត្យ។

  ប្រសិនបើការពិនិត្យឡើងវិញនូវកិច្ចសន្យាសម្បទានដែលបានរៀបចំស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះធ្វើឱ្យបេក្ខជនដែលបានជ្រើសរើសតាមនីតិវិធីត្រឹមត្រូវ ហើយរងនូវផលប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន បេក្ខជននោះអាចដកពាក្យដេញថ្លៃ ឬការស្នើររបស់ខ្លួនដោយមិនទទួលរងនូវការបាត់បង់ប្រាក់តម្កល់សម្រាប់ធានាការដេញថ្លៃឡើយ។
- **មាត្រា១៣:** បន្ទាប់ពីបានទទួលការអនុម័តយល់ព្រមដូចមានចែងក្នុងមាត្រា១២ នៃច្បាប់នេះ ស្ថាប័នជាប់កិច្ចសន្យាត្រូវចេញសេចក្តីជូនដំណឹងពីការយល់ព្រមផ្តល់សម្បទានទៅបេក្ខជនដែលបានជ្រើសរើស មុននឹងអនុវត្តការចុះកិច្ចសន្យាសម្បទាននេះ។

  ស្ថាប័នជាប់កិច្ចសន្យា និងសម្បទានិក ត្រូវចុះហត្ថលេខាលើកិច្ចសន្យាសម្បទានក្នុងរយៈពេល៦ (ប្រាំមួយ)ខែ បន្ទាប់ពីការជូនដំណឹងស្តីពីការផ្តល់សម្បទាន។

  រយៈពេលនេះអាចពន្យារបាន ប្រសិនបើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងស្ថាប័នជាប់កិច្ចសន្យា និងសម្បទានិក។ ការខកខានរបស់ស្ថាប័នជាប់កិច្ចសន្យាក្នុងការអនុវត្តស្របតាមមាត្រា១៣ កថាខ័ណ្ឌទី២ នៃច្បាប់នេះ នឹងអាចឱ្យសម្បទានិកមានសិទ្ធិក្នុងការដកពាក្យដេញថ្លៃ ឬ ដកការស្នើចរចា ដោយមិនទទួលរងនូវការបាត់បង់ប្រាក់តម្កល់សម្រាប់ធានាការដេញថ្លៃឡើយ។
- **<u>មាត្រា១៦:</u>** សម្បទានិកត្រូវអនុវត្តន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធ ដោយសាមីខ្លួនទទួលបន្ទុកការចំណាយទាំងអស់ និងរ៉ាប់រងរាល់ហានិភ័យ ហើយមិនត្រូវពឹងផ្អែកលើការសុំឥណទាន ឬការធានាពីស្ថាប័នជាប់កិច្ចសន្យាឡើយ។ ក្នុងកាលៈទេសៈពិសេស ការធានាអាចត្រូវផ្តល់បាន តែការធានានោះត្រូវអនុវត្តន៍ស្របទៅនឹងនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។
- **មាត្រា១៩:** សិទ្ធិ និងកាតព្វកិច្ចរបស់សម្បទានិកដែលមានចែងក្នុងកិច្ចសន្យាសម្បទាន មិនអាចផ្ទេរទៅតតិយជនបានទេ ប្រសិនបើគ្មានការអនុញ្ញាតជាមុនពីស្ថាប័នជាប់កិច្ចសន្យា។

  ការគ្រប់គ្រងផលប្រយោជន៍របស់សម្បទានិក ដែលមានចែងនៅក្នុងកិច្ចសន្យាសម្បទានមិនអាចផ្ទេរទៅតតិយជនបានឡើយ ប្រសិនបើគ្មានការអនុញ្ញាតជាមុនពីស្ថាប័នជាប់កិច្ចសន្យាលើកលែងតែចំពោះការអនុវត្តសិទ្ធិប្រាតិភោគ ដែលបានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ។
- មាត្រា២០: លើកលែងតែមានការចែងនៅក្នុងកិច្ចសន្យាសម្បទានច្បាស់លាស់ សម្បទានិកត្រូវទទួលខុសត្រូវលើគំនូរប្លង់ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដោយសាមីខ្លួនទទួលបន្ទុកការចំណាយទាំងអស់ និងរ៉ាប់រង

រាល់ហានិភ័យ។ គំនូរប្លង់ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធត្រូវតែស្របជាមួយនឹងច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចសន្យាសម្បទានអាចតម្រូវឱ្យមានអ្នកជំនាញការឯករាជ្យ ដើម្បីធ្វើរបាយការណ៍ជូនស្ថាប័នជាប់កិច្ចសន្យាលើករណីផ្សេងៗដែលទាក់ទងទៅនឹងសំណង់ហេដ្ឋារចនាសម្ព័ន្ធ។

- **មាត្រា២១:** លើកលែងតែមានចែងនៅក្នុងកិច្ចសន្យាសម្បទានច្បាស់លាស់ សម្បទានិកត្រូវធ្វើអាជីវកម្ម និងថែរក្សាសំណង់ហេដ្ឋារចនាសម្ព័ន្ធ ដោយសាមីខ្លួនទទួលបន្ទុកការចំណាយទាំងអស់ និងរ៉ាប់រងរាល់ហានិភ័យស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

  លើកលែងតែមានចែងនៅក្នុងកិច្ចសន្យាសម្បទាន សម្បទានិកត្រូវធានានូវនិរន្តរភាពក្នុងការផ្តល់សេវាកម្ម។ ដូចដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន ស្ថាប័នជាប់កិច្ចសន្យាមានសិទ្ធិកាន់កាប់ការងារអាជីវកម្មនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធជាបណ្តោះអាសន្ន ដើម្បីធានានូវប្រសិទ្ធិភាពនៃការផ្តល់សេវាកម្មដោយគ្មានរអាក់រអួល ក្នុងករណីសម្បទានិកមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន តែតម្រូវឱ្យស្ថាប័នជាប់កិច្ចសន្យាធ្វើការជូនដំណឹងដល់សម្បទានិក ដើម្បីធ្វើការកែតម្រូវការខកខានមិនបានអនុវត្តន៍ក្នុងរយៈពេលនោះ ដូចមានចែងនៅក្នុងកិច្ចសន្យាសម្បទាន ឬប្រសិនបើពុំមានចែងទេ គឺត្រូវធ្វើក្នុងពេលសមស្របណាមួយ។

- **មាត្រា២២:** ដើម្បីធានាការអនុវត្តដោយសម្បទានិកនូវកាតព្វកិច្ច ដែលមានចែងក្នុងកិច្ចសន្យាសម្បទាន និងដោយផ្អែកតាមតម្រូវការនៃកិច្ចសន្យា សម្បទានិកត្រូវប្រាក់ធានាការអនុវត្តកិច្ចសន្យាឱ្យបានពេញលេញសម្រាប់ដំណាក់កាលជាកំណត់នៃគម្រោងសម្បទានជូនស្ថាប័នជាប់កិច្ចសន្យា និងទៅតាមទម្រង់ពេលវេលា និងបរិមាណដែលមានចែងនៅក្នុងកិច្ចសន្យាសម្បទាន។

- **មាត្រា២៣:** កិច្ចសន្យាសម្បទានអាចផ្តល់កាលានុវត្តភាពឱ្យសហគ្រាស និងស្ថាប័នស្រាវជ្រាវក្នុងស្រុកមានលទ្ធភាពចូលរួមនៅក្នុងការអភិវឌ្ឍបច្ចេកវិទ្យាកម្មន្តសាល ឬសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដោយសហប្រតិបត្តិការជាមួយសម្បទានិក។ សហប្រតិបត្តិការ ដែលអាចនាំមកនូវប្រាក់ចំណូលបន្ថែមដល់សម្បទានិកត្រូវតែផ្តល់ឱ្យសហគ្រាស និងស្ថាប័នរដ្ឋ ឯកជន ក្នុងស្រុកនូវឱកាសដ៏ពិតៗ ដើម្បីទទួលបាននូវការបញ្ជាទិញ ការផ្គត់ផ្គង់ទំនិញ ការផ្តល់សេវាកម្មក្នុងស្រុក និងក្រៅប្រទេស ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍបច្ចេកវិទ្យាពាក់ព័ន្ធទៅនឹងសកម្មភាពហេដ្ឋារចនាសម្ព័ន្ធ។

  នៅពេលដែលធ្វើការវាយតម្លៃឯកសារដេញថ្លៃ ស្ថាប័នជាប់កិច្ចសន្យាអាចគិតគូរដល់សក្តានុពលទូលំទូលាយនៃការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ដែលលើកឡើងដោយអ្នកដេញថ្លៃ ហើយដែលអាចកំណត់ជាលក្ខណៈវិនិច្ឆ័យនៅក្នុងសេចក្តីជូនដំណឹងអំពីការដេញថ្លៃទាក់ទងទៅនឹងគម្រោងហេដ្ឋារចនាសសម្ព័ន្ធ។

- **មាត្រា២៥:** នៅពេលណាដែលកិច្ចសន្យាសម្បទានបានតម្រូវឱ្យសម្បទានិកផ្ទេរ នៅពេលបញ្ចប់គម្រោងសម្បទាននូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធជូនដល់ស្ថាប័នជាប់កិច្ចសន្យា ឬអ្នកដែលទទួលបានការតែងតាំងការផ្ទេរនោះ ត្រូវស្របទៅនឹងពេលវេលាដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន។

  សំណង់ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវផ្ទេរនោះ ត្រូវមានលក្ខណៈល្អស្របទៅតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន និងត្រូវបានជម្រះឱ្យបានជ្រះស្រឡះនូវរាល់បំណុលបន្ទុក សិទ្ធិប្រាតិភោគ និងការតវ៉ាទាមទារនានា។

- **មាត្រា៣២:** រាល់សកម្មភាពដែលទាក់ទងនឹងការអនុវត្តច្បាប់នេះ ត្រូវអនុវត្តន៍ឱ្យស្របទៅនឹងតម្រូវការនៃបមាណីសុខភាព និងសុវត្ថិភាព និងការងារបរិស្ថាន ដោយសម្បទានិកត្រូវថែរក្សាគ្រប់ពេលវេលានូវផែនការជាយថាហេតុនេះ ដើម្បីទប់ទល់នឹងគ្រោះថ្នាក់ និងភាពអាសន្នបន្ទាន់ដែលអាចនាំឱ្យ បាត់បង់ជីវិត ឬរងរបួសការពុល ឬការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិដែលតម្រូវឱ្យមានដោយច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចសន្យាសម្បទាន។

- **មាត្រា៣៧:** កិច្ចសន្យាសម្បទាន ត្រូវបញ្ជាក់អំពីរយៈពេលសម្បទាន ដែលមិនត្រូវលើសពី **៣០ (សាមសិប)ឆ្នាំ** គិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាសម្បទាន ដោយផ្អែកតាមមាត្រា១៣ នៃច្បាប់នេះ។ ក្នុងករណីចាំបាច់ ដោយយោងទៅលើប្រភេទនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ រាជរដ្ឋាភិបាលកម្ពុជាអាចកំណត់រយៈពេលសម្បទាន វែងជាងនេះ។

  រយៈពេលសម្បទាន ដែលបានកំណត់នៅក្នុងកិច្ចសន្យាសម្បទាន មិនអាចពន្យារបានឡើយ លើកលែងតែជាលទ្ធផលដែលចេញមកពីស្ថានភាពដូចខាងក្រោម៖

  ១-ពន្យាដើម្បីបង្កើយការងារ ឬការបង្អាក់ដំណើរការដោយមូលហេតុនៃការរំលោភកិច្ចសន្យាដោយស្ថាប័នជាប់កិច្ចសន្យា ឬ ដោយទង្វើនៃស្ថាប័នមានសមត្ថកិច្ចដទៃទៀត។

  ២-ពន្យារដើម្បីបង្កើយការងារ ឬការបង្អាក់ដំណើរការដោយហេតុការណ៍ប្រធានសក្តិ ដូចដែលមានបញ្ជាក់ក្នុងកិច្ចសន្យាសម្បទាន ហើយដែលនាំឱ្យសម្បទានិកមិនអាចមានលទ្ធភាពបំពេញបានមកវិញនូវការចំណាយ ឬការខាតបង់ដែលបានបណ្តាលមកពីស្ថានភាពខាងលើ រួមទាំងការធានារ៉ាប់រងលើគម្រោងសម្រាប់រយៈពេលសម្បទានដំបូង។

**មាត្រា៤០:** ស្ថាប័នជាប់កិច្ចសន្យាជាអ្នកទទួលខុសត្រូវ ដើម្បីធានាថា កិច្ចសន្យាសម្បទានត្រូវអនុវត្តន៍ដោយត្រឹមត្រូវ និងត្រូវបង្កើតនូវយន្តការព្រមទាំងនីតិវិធីសម្រាប់ត្រួតពិនិត្យសម្របសម្រួលការអនុវត្ត និងដំណើរការនៃកិច្ចសន្យាសម្បទាន ហើយរាយការណ៍ស្តីពីការគ្រប់គ្រងកិច្ចសន្យាសម្បទាន ក្នុងរបាយការណ៍ថវិកាប្រចាំឆ្នាំនៃស្ថាប័នជាប់កិច្ចសន្យា ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង/ឬក្រសួងពាក់ព័ន្ធដែលទទួលខុសត្រូវ។

Draft

## ៣.២៤. អនុក្រឹត្យ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ ១៩៩៩

អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានអនុម័តនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ។ មាត្រាដែលពាក់ព័ន្ធនិងគម្រោងនេះមានដូចតទៅៈ

- <u>មាត្រា១.-</u>

  អនុក្រឹត្យនេះមានគោលបំណង ៖

- កំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុននឹងដាក់ជូនរាជរដ្ឋាភិបាលសម្រេច
- កំណត់ប្រភេទ និងទំហំគម្រោង សកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បំផុសឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង។

- មាត្រា២.-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគម្រោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំណុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ជាក្រសួង-ស្ថាប័នរដ្ឋ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ លើកលែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់ជាបន្ទាន់ ដែលសម្រេចដោយរាជរដ្ឋាភិបាល។

- មាត្រា៧.-

ម្ចាស់គម្រោង ត្រូវដាក់ពាក្យសុំពិនិត្យ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍សិក្សាបុរេលទ្ធភាពទៅក្រសួងបរិស្ថាន។

- មាត្រា៨.-

ម្ចាស់គម្រោង ត្រូវដាក់ពាក្យសុំពិនិត្យ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការណ៍សិក្សាលទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគម្រោងដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ដល់ធនធានធម្មជាតិ អេកូស៊ីស្តែម សុខភាព និងសុខុមាលភាពសាធារណៈ។

- មាត្រា១១.-

ម្ចាស់គម្រោង ត្រូវបង់ថ្លៃសេវាការងារ សម្រាប់ការពិនិត្យលើរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការតាមដាន ឃ្លាំមើលការនុវត្តគម្រោង។ តម្លៃសេវាការងារនេះ ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួងបរិស្ថាន ដែលត្រូវបញ្ចូលក្នុងថវិកាជាតិ។

- មាត្រា១២.-

ម្ចាស់គម្រោង ត្រូវបង់វិភាគទានចូលរួមក្នុងមូលនិធិ ទាយជ្ជទានបរិស្ថាន សម្រាប់កិច្ចការពារបរិស្ថាន ដូចមានចែងក្នុងមាត្រ ១៩ ជំពូកទី៨ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

- មាត្រា១៤.-

ម្ចាស់គម្រោង ត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា៧ ទៅក្រសួងបរិស្ថាន និងផ្តល់លិខិតចម្លងទៅស្ថាប័នអនុម័តគម្រោង។

- មាត្រា១៦.-

ក្នុងករណីដែលក្រសួងបរិស្ថាន តម្រូវឱ្យមានរបាយការណ៍ ដូចមានចែងក្នុងមាត្រា៨ ទៅក្រសួងបរិស្ថានជាមួយនឹងការដាក់ពាក្យសុំវិនិយោគទៅស្ថាប័នអនុម័តគម្រោង។

- មាត្រា១៧.-

ក្រសួងបរិស្ថាន ត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា១៦ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើទៅម្ចាស់គម្រោង និងស្ថាប័នអនុម័តគម្រោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការចាប់ពីថ្ងៃ ដែលក្រសួងបានទទួលរបាយការណ៍សិក្សាលទ្ធភាព និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញពីម្ចាស់គម្រោង។

ក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹតលេខ៧២អនក្របក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ អំពីចំណាត់ថ្នាក់តម្រូវឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទាក់ទងនឹងគម្រោងនេះ គឺស្ថិតក្នុងប្រភេទអាជីវកម្ម ផ្នែកឧស្សាហកម្មផ្សេងៗ ដូចជារោងចក្រវារីអគ្គិសនី រោងចក្រអគ្គិសនីជាដើម។

## ៣.២៥. អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ឆ្នាំ ២០០៣

អនុក្រឹត្យលេខ/១៩ អនក្រ.បក ស្តីពីសម្បទានដីសង្គមកិច្ច អនុម័តនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ដោយរាជរដ្ឋាភិបាល ។

-មាត្រា ១: អនុក្រឹត្យនេះ កំណត់នីតិវិធី លក្ខណៈវិនិច្ឆ័យ និង យន្តការសម្រាប់ធ្វើការផ្តល់សម្បទានដីសង្គមកិច្ច ដើម្បីសង់លំនៅឋាន ឬ/និងដើម្បីធ្វើ កសិកម្មជាលក្ខណៈគ្រួសារ ។

-មាត្រា ២: ពាក្យទាំងឡាយខាងក្រោមនេះ មានន័យដូចតទៅៈ

១. សម្បទានដីសង្គមកិច្ចគឺជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋតាមផ្លូវច្បាប់សម្រាប់គោលបំណងសង្គមកិច្ចដល់ ជនក្រីក្រដែលខ្វះខាតដីសម្រាប់ សង់លំនៅឋាន ឬ/និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

២. ដីសម្បទានសង្គមកិច្ច គឺជាដីដែលជាកម្មវត្ថុនៃសម្បទានដីសង្គមកិច្ច។

៣. ការធ្វើកសិកម្មជាលក្ខណៈគ្រួសារ សំដៅសកម្មភាពដាំដំណាំ ឬចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ដើម្បីបំពេញ សេចក្តីត្រូវការជាមូលដ្ឋាន។

**-មាត្រា ៣:** ដីសម្បទានសង្គមកិច្ច អាចត្រូវផ្តល់ឱ្យសម្រាប់គោលដៅសង្គមកិច្ចដោយអនុលោមតាមគោលដៅណាមួយ ឬគោលដៅច្រើន ដូចមានខាងក្រោមនេះ៖

១- ផ្តល់ដី ដល់គ្រួសារក្រីក្រ ដែលគ្មានទីលំនៅសម្រាប់សង់លំនៅឋាន ។

២- ផ្តល់ដី ដល់គ្រួសារក្រីក្រសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។

៣- ផ្តល់ដីដល់គ្រួសារដែលត្រូវផ្លាស់ប្តូរទី លំនៅបណ្តាលមកពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈសម្រាប់ការតាំងលំនៅឋានជាថ្មី ។

៤- ផ្តល់ដី ដល់គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ ។

៥- ផ្តល់ដី ដល់គ្រួសារមាតុភូមិនិវត្តន៍ ។

៦- ផ្តល់ដី ដល់យោធិនរំសាយ និងគ្រួសារយុទ្ធជនពលី ពិការ ។

៧- ជួយសម្រួល ដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។

៨- ជួយសម្រួល ដល់សម្បទានដីសេដ្ឋកិច្ច ដោយផ្តល់ដីឡូត៍ដល់កម្មករចំការធំៗសម្រាប់សង់លំនៅឋាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។

៩- អភិវឌ្ឍតំបន់ដែលពុំទាន់ត្រូវបានអភិវឌ្ឍសមស្រប ។

**-មាត្រា ៤:** កម្មវិធីសម្បទានដីសង្គមកិច្ចមាន៖

១. កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន។

២. កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

**-មាត្រា ៦:** ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន តាមរយៈក្រុមការងារថ្នាក់ស្រុក ខណ្ឌ ទៅគណៈកម្មាធិការប្រើប្រាស់ និង បែងចែកដីថ្នាក់ខេត្ត ក្រុង ដើម្បីសុំការសម្រេចយល់ព្រម។ គណៈកម្មាធិការប្រើប្រាស់ និង បែងចែកដីថ្នាក់ខេត្ត ក្រុងអាចផ្តល់ការសម្រេចយល់ព្រមលើផែនការសម្បទានដី សង្គមកិច្ចថ្នាក់មូលដ្ឋានប្រសិនបើ ផែនការសម្បទានដីសង្គមកិច្ចនោះ ត្រឹមត្រូវតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ដោយអនុក្រឹត្យនេះ និងប្រសិនបើពិនិត្យឃើញថា ដីនោះជាដីឯកជនរបស់រដ្ឋដែលនៅទំនេរហើយសមស្របសម្រាប់ ផែនការសម្បទានដីសង្គមកិច្ច។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវជូនដំណឹង ដល់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិអំពីផែនការនីមួយៗ ដែលគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុងបានផ្តល់ការសម្រេចយល់ព្រម។ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចពិនិត្យកែសម្រួលផែនការ ឬ លុបចោលសេចក្តីសម្រេចយល់ ព្រមរបស់គណៈកម្មាធិការប្រើប្រាស់ និង បែងចែកដីថ្នាក់ខេត្ត ក្រុង ក្នុងរយៈពេលហុកសិប (៦០)ថ្ងៃ គិតពីថ្ងៃបានទទួលផែនការសម្បទានដីសង្គមកិច្ចនេះ ប្រសិនបើៈ

ក- ផែនការសម្បទានដីសង្គមកិច្ចនោះ មិនស្របនឹងអាទិភាពនៃការប្រើប្រាស់ដីថ្នាក់ជាតិ មានកំហុសបច្ចេកទេស ឬរំលោភបទប្បញ្ញត្តិ ទាំងឡាយនៃអនុក្រឹត្យនេះ ឬច្បាប់ផ្សេងទៀត ។

ខ- ផែនការដែលបានយល់ព្រម មិនស្របនឹងលក្ខខណ្ឌចាំបាច់ នៃកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

បន្ទាប់ពីបានការយល់ព្រម ក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានជំនួយបច្ចេកទេស ពីក្រុមការងារថ្នាក់ស្រុកខណ្ឌ ជាអ្នកអនុវត្តន៍កម្មវិធីសម្បទានដី សង្គមកិច្ចថ្នាក់មូលដ្ឋាន។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដែលបានទទួលការសម្រេចយល់ព្រមរួចហើយ ត្រូវបើកចំហជាសាធារណៈ នៅសាលាឃុំ សង្កាត់ពាក់ព័ន្ធនៅគណៈកម្មា

Draft

ធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង និងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ច ថ្នាក់ជាតិក្នុងអំឡុងពេលម៉ោងធ្វើការ ។

## ៣.២៦. អនុក្រឹត្យស្តីពីការបង្កើតឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ឆ្នាំ ២០១៦

អនុក្រឹត្យលេខ ៨១ អនក្រ.បក ការបង្កើតឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល បានអនុម័តនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ ២០១៦ ដែលមានមាត្រាពាក់ព័ន្ធនិងគម្រោងនេះដូចតទៅ៖

- **មាត្រា១:** ត្រូវបានបង្កើតឧទ្យានជាតិជួរភ្នំក្រវាញកណ្តាលដែលមានផ្ទៃដីទំហំ៤០១.៣១៣(បួនសែនមួយពាន់បីរយដប់បី) ហ.ត ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកោះកុង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ស្ពឺ ដូចមានភ្ជាប់ផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា(Datum: WGS1984)ដូចខាងក្រោម៖

| និយាមកាគោល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ID | X | Y | ID | X | Y | ID | X | Y |
| 1 | 302246 | 1330806 | 14 | 366633 | 1278272 | 27 | 348773 | 1340824 |
| 2 | 311340 | 1301719 | 15 | 371451 | 1284900 | 28 | 347729 | 1342509 |
| 3 | 318398 | 1300809 | 16 | 376851 | 1289153 | 29 | 347226 | 1347470 |
| 4 | 324985 | 1295695 | 17 | 374781 | 1292207 | 30 | 346239 | 1349545 |
| 5 | 326362 | 1294875 | 18 | 374529 | 1309300 | 31 | 344393 | 1352278 |
| 6 | 325962 | 1291064 | 19 | 373286 | 1326361 | 32 | 344135 | 1353338 |
| 7 | 344184 | 1304987 | 20 | 370302 | 1334979 | 33 | 343841 | 1355758 |
| 8 | 345606 | 1306401 | 21 | 368424 | 1332849 | 34 | 342773 | 1359998 |
| 9 | 346904 | 1304778 | 22 | 364808 | 1333640 | 35 | 333527 | 1362699 |
| 10 | 350167 | 1301687 | 23 | 362012 | 1334553 | 36 | 323826 | 1365894 |
| 11 | 344069 | 1286886 | 24 | 358629 | 1329500 | 37 | 313904 | 1357440 |
| 12 | 340568 | 1286359 | 25 | 356018 | 1328962 | 38 | 309435 | 1358923 |
| 13 | 358513 | 1276581 | 26 | 354765 | 1339075 | | | |

- **មាត្រា២:** អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖
- ការពារតួនាទីខាងផ្នែកប្រព័ន្ធអេកូឡូស៊ីរបស់តំបន់ ដែលបានកំណត់សម្រាប់ជាផលប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងតួនាទីមុខងារនៃតំបន់នោះ
- ផ្តល់ជាមូលដ្ឋានដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះពុំបង្កការគំរាមកំហែងដលបរិស្ថានធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រងការការពារ និងអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់។
- **មាត្រា៣:** ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលដែនដីខេត្តកោះកុង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ស្ពឺ ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។
- **មាត្រា៤:** អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការបង្កើតតំបន់ព្រៃការពារអភិរក្ស ដីជម្រាលជួរភ្នំក្រវាញភាគកណ្តាល និងជីវៈចំរុះ និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។
- **មាត្រា៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា

Draft

ប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

## ៣.២៧. អនុក្រឹត្យ ស្ដីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេងឆ្នាំ ២០០០

អនុក្រឹត្យលេខ ៤២ អនក្រ.បក ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងបានអនុម័តនៅ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០០ ដែលមានមាត្រាពាក់ព័ន្ធ និងគម្រោងនេះដូចតទៅះ

**-មាត្រា១:** អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ដើម្បីទប់ស្កាត់ និងការកាត់បន្ថយសារធាតុ ដែលបំពុលខ្យល់ និងសំឡេងក្នុងបរិយាកាស សំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ។

**-មាត្រា២:** អនុក្រឹត្យនេះមានវិសាលភាពអនុវត្តន៍ និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និង អចល័តទាំងឡាយ ដែលបង្កឱ្យមានការបំពុលខ្យល់ និងការរំខានដោយសំឡេងនៅក្នុងបរិយាកាស។

**-មាត្រា៤:** កម្រិតកំនត់ស្តង់ដារគុណភាពខ្យល់មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ១ និងកម្រិតកំណត់ស្តង់ដារអតិបរមា នៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតឱ្យមាននៅក្នុងខ្យល់មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ២។

**-មាត្រា១៣:** ការបញ្ចេញសារធាតុពុល និងសំឡេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវផ្ញើរសេចក្តីចំលង នៃពាក្យសុំនោះទៅក្រសួងស្ថាប័នពាក់ព័ន្ធ។

**-មាត្រា១៥:** ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំឡេងដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះនឹងត្រូវអនុវត្តន៍ទៅលើប្រភពបំពុលទាំងគម្រោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការលើកលែងតែគម្រោង ដែលមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានរួចហើយ។

**-មាត្រា២០:** ក្រសួងបរិស្ថានត្រូវចុះយកគំរូតាងនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល។ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការណ៍ និងបង្កលក្ខណៈងាយស្រួល ដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង បំពេញការងារតាមលក្ខណៈបច្ចេកទេស។

**-មាត្រា២២:** ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូលបង់ថ្លៃសម្រាប់វិភាគតាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជូទានបរិស្ថាន។

**-មាត្រា២៤:** ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពទាំងអស់ត្រូវៈ

- ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុពុល និងឧបករណ៍សម្រាប់កាត់បន្ថយសំឡេង ដើម្បីឱ្យឆ្លើយតបទៅ និងកម្រិតកំណត់ស្តង់ដារ។
- ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុល ដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន នឹងត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់៣ខែម្តង។
- ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវ ក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ ។

**-មាត្រា២៦:** ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា។

**-មាត្រា៣០:** ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថាប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសំឡេង ឬរំញ័របង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ។

**-មាត្រា៣១:** ក្នុងករណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនៃការបំពុលខ្យល់ ឬការរំខានដោយសំឡេងក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះនឹងត្រូវជូនព័ត៌មានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

**ឧបសម្ព័ន្ធ១ ៖ កម្រិតកំណត់ស្តង់ដារគុណភាពខ្យល់**

| ល.រ | ប៉ារ៉ាម៉ែត្រ | រយៈពេល 1 ម៉ោង ជាមធ្យម mg/m³ | រយៈពេល 8 ម៉ោង ជាមធ្យម mg/m³ | រយៈពេល 24 ម៉ោង ជាមធ្យម mg/m³ | រយៈពេល 1ឆ្នាំ ជាមធ្យម mg/m³ |
|---|---|---|---|---|---|
| ១ | កាបូនអុកស៊ីត CO | 40 | 20 | | |
| ២ | អាសូតអុកស៊ីត $NO_2$ | 0,3 | | 0,10 | |
| ៣ | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 0,5 | | 0,30 | 0,10 |
| ៤ | អូសូន $O_3$ | 0.2 | | | |
| ៥ | សំណ Pb | | | 0,005 | |
| ៦ | សារធាតុអណ្តែតក្នុងខ្យល់ TSP | | | 0,33 | 0,10 |

Draft

**ឧបសម្ព័ន្ធ៧ ៖ កម្រិតកំណត់ស្តង់ដារសម្រាប់ត្រួតពិនិត្យសំឡេងក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម**

| កម្រិតសំឡេង (dB (A)) | រយៈពេលអតិបរមា (ម៉ោង) | កំណត់បង្ហាញ |
|---|---|---|
| 75 | 32 | ត្រូវផ្តល់ឧបករណ៍ការពារត្រចៀកដល់អ្នកបំរើការ ដែលធ្វើការនៅកន្លែងមានសំឡេងលើសពី80dB (A) |
| 80 | 16 | |
| 85 | 8 | |
| 90 | 4 | |
| 95 | 2 | |
| 100 | 1 | |
| 105 | 0,5 | |
| 110 | 0.25 | |
| 115 | 0,125 | |

## ៣.២៨. អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក ឆ្នាំ ១៩៩៩

អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក បានអនុម័តនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩។ អនុក្រឹត្យនេះ ៖

- មានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ។
- មានវិសាលភាពអនុវត្តន៍ចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយ ដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ។

មាត្រានៃអនុក្រឹត្យនេះ ដែលមានពាក់ព័ន្ធនឹងគម្រោងមានដូចតទៅ:

**-មាត្រា១០:** ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវធ្វើរសេចក្តីចំលង នៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ។

**-មាត្រា១១:** ប្រភេទនៃប្រភពបំពុល ដែលតម្រូវឱ្យសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ហើយដែលចែកចេញជាពីរប្រភេទដូចតទៅ:

ក- ប្រភពបំពុលប្រភេទថ្នាក់ទី១ តម្រូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណ សំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង១០ម៉ែត្រគូប ក្នុងមួយថ្ងៃ ដោយពុំគិតបញ្ចូល នូវបរិមាណទឹកដែលប្រើប្រាស់សម្រាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ។

ខ- ប្រភពបំពុលប្រភេទថ្នាក់ទី២ ចាំបាច់តម្រូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន។

**-មាត្រា១៣:** ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដទៃ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន៖

- ឱ្យបានមុន ៤០ ថ្ងៃសម្រាប់គម្រោងនៅភ្នំពេញ និង ៦០ថ្ងៃសម្រាប់គម្រោងនៅតាមខេត្តក្រុង នៃការចាប់ផ្តើមដំណើរការ សម្រាប់ប្រភពបំពុលដែលជាគម្រោងថ្មី។
- ឱ្យបានក្នុងរយៈពេល ៣០ថ្ងៃសម្រាប់ប្រភពបំពុលនៅភ្នំពេញ និង៥០ថ្ងៃ សម្រាប់ប្រភពបំពុលនៅតាមខេត្តក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សម្រាប់ប្រភពបំពុលដែលកំពុងដំណើរការ។

Draft

**ឧបសម្ព័ន្ធ១: ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់:**

១- សមាសធាតុសរីរាង្គអាឡូសែន និងសារធាតុ ដែលអាចបង្កើតបានជាសមាសធាតុសរីរាង្គ អាឡូសែន ទាំងនោះនៅក្នុងបរិស្ថានទឹក

២- សមាសធាតុសរីរាង្គផូស្វ័រ

៣- សមាសធាតុសរីរាង្គទីន

៤- សារធាតុដែលបង្កឱ្យមានជំងឺមហារីក

៥- បារត និងសមាសធាតុរបស់វា

៦- កាត់មូម និងសមាសធាតុរបស់វា

៧- សមាសធាតុប្រេងអសរីរាង្គដែលមិនបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

៨- សមាសធាតុសំយោគដែលមិនបំបែកធាតុ ដែលអាចបណ្តែតនៅលើផ្ទៃទឹក ឬលិចក្នុងទឹកហើយដែលអាចជ្រាបចូលទៅក្នុងការប្រើប្រាស់ទឹក

៩- សារធាតុវិទ្យុសកម្ម

១០- លោហៈ និងសមាសធាតុ របស់វាដូចជា ៖

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម (Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរីយ៉ូម (Te) |

សំណ (Pb) ទីតានីយ៉ូម (Ti) អ៊ុយរ៉ាញ៉ូម (U) ប្រាក់ (Ag)

១១- សមាសធាតុសរីរាង្គពុលមិនបំបែកធាតុស៊ីលីស្យូម

១២- សមាសធាតុអសរីរាង្គផូស្វរ

១៣- សមាសធាតុប្រេងជាសរីរាង្គបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

១៤- សមាសធាតុស៊ីអានីត និងក្លួយអរ

១៥- សារធាតុដែលមានឥទ្ធិពលលើអុកស៊ីសែន ដូចជា អាម៉ូញាក់ នីទ្រីត ។ល។

**ឧបសម្ព័ន្ធ៤: កម្រិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិរក្សជីវចំរុះនៅក្នុងទឹក**

**១.សម្រាប់ទន្លេ**

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដា |
|---|---|---|---|
| 1 | pH | | 6,5 – 8,5 |
| 2 | BODs | mg/l | 1 – 10 |
| 3 | Suspended Solid | mg/l | 25– 100 |
| 4 | Dissolved Oxygen (DO) | mg/l | 2.0 – 7.5 |
| 5 | Coliform | MPN/100ml | <5000 |

**២.សម្រាប់បឹង និងអាងស្តុកទឹក**

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដា |
|---|---|---|---|
| 1 | pH | | 6,5 – 8,5 |
| 2 | COD | mg/l | 1 – 8 |
| 3 | Suspended Solid | mg/l | 1 – 15 |
| 4 | Dissolved Oxygen (DO) | mg/l | 2.0 – 7.5 |
| 5 | Coliform | MPN/100ml | <1000 |
| 6 | Total Nitrogen | mg/l | 0.1 – 0.6 |
| 7 | Total Phosphorus | mg/l | 0.005 – 0.05 |

## ៣.២៩. អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង ឆ្នាំ ១៩៩៩

អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង បានអនុម័តនៅថ្ងៃទី ២៧ ខែមេសា ឆ្នាំ១៩៩៩ មាត្រា ដែលមានពាក់ព័ន្ធនឹងគម្រោងមានដូចតទៅ:

-មាត្រា១: អនុក្រឹត្យនេះមានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការពារសុខភាពសាធារណៈគុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ។

-មាត្រា២: អនុក្រឹត្យនេះមានវិសាលភាពអនុវត្តន៍ ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់។

-មាត្រា៣: និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ:

ក- **សំណល់រឹង**" គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កម្ទេចកំទីដែលលែងត្រូវការប្រើប្រាស់ ហើយត្រូវបានគេបោះបង់ចោលមានបំណងនឹងបោះបង់ចោល ឬតម្រូវឱ្យបោះបង់ចោល។



Draft

ខ- **សំរាម៖** គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកម្សាន្ត។ល។

គ- **សំណល់ប្រកបដោយគ្រោះថ្នាក់៖** គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កឱ្យមានជំងឺមហារីក ចំលងជំងឺ ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញ ដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពី លំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្ម អាជីវកម្មរ៉ែ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

-មាត្រា៧: ហាមឃាត់ដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

-មាត្រា១៣: ម្ចាស់សំណល់ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្រប និងមានសុវត្ថិភាព។

-មាត្រា១៤: ម្ចាស់សំណល់ ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងនឹងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួនរួមមានៈ

ក- ប្រភេទ និងបរិមាណសំណល់

ខ- វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ- វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬបំបាត់សំណល់។

-មាត្រា១៥: ការទុកដាក់ស្តុក ដឹកជញ្ជូន និងការបោះចោល ឬចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវអនុវត្តន៍ដាច់ដោយឡែកពីសំរាមធម្មតាដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន។

ហាមឃាត់ជាដាច់ខាតការបោះចោល ឬការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភព ឬបណ្តោញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ។

-មាត្រា១៨: ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ ដែលទាក់ទងទៅនឹងសំណល់ដែលបានដឹកយកមកចាក់ចោល ឬ ស្តុកនៅកន្លែងរបស់ខ្លួនរួមមានៈ

ក- ប្រភេទ និងបរិមាណសំណល់

ខ- ប្រភពដើមរបស់សំណល់

គ- ការដឹកជញ្ជូន និងមធ្យោបាយវេចខ្ចប់

ឃ- ដំណើរការ និងការគ្រប់គ្រងសំណល់នៅក្នុងទីកន្លែងរបស់ខ្លួន។

**តារាងឧបសម្ព័ន្ធ: ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់**

ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់មានចែងនៅក្នុងឧបសម្ព័ន្ធ ចំណុចដែលពាក់ព័ន្ធមានដូចខាងក្រោមៈ

- សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន
- សំណល់ដែលមានផ្ទុកជាតិអាស៊ីត
- សំណល់ដែលមានផ្ទុកជាតិបាស

Draft

- សំណល់អំពូលអគ្គិសនី និងបន្ទះគ្រឿងអេឡិចត្រូនិចអគ្គិសនី
- សំណល់អាគុយ និងថ្មពិល
- សំណល់ដែលនាំឱ្យមានចំលងមេរោគ ឬជំងឺ
- ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់
- សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសំអាតទឹកកខ្វក់ ឬដីខូចគុណភាព

## ២.៣០ អនុក្រឹត្យ ស្តីពីការគ្រប់គ្រងអាងទន្លេ ឆ្នាំ២០១៥

អនុក្រឹត្យលេខ ៩៨ អនក្រ.បក ស្តីពីការការគ្រប់គ្រងអាងទន្លេ បានអនុម័តនៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៥ ដោយរាជរដ្ឋាភិបាល ដែលមានមាត្រាពាក់ព័ន្ធនឹងគម្រោងមានដូចតទៅ:

**-មាត្រា១:** អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍អាងទន្លេឱ្យមានប្រសិទ្ធភាពនិងនិរន្តរភាពដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

**-មាត្រា២:** អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនីតិវិធីនៃការរៀបចំ និងការអនុវត្តផែនការនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ អាងទន្លេ អាងទន្លេរង ទឹកលើដីជម្រាល ទឹកក្រោមដី និងល្ហាងទឹកក្រោមដី។

**-មាត្រា៣:** អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តន៍លើគ្រប់អាងទន្លេក្នុងព្រះរាជាណាចក្រកម្ពុជា សហការជាមួយប្រទេស ជិតខាងក្នុងការប្រើប្រាស់ទឹកលើគ្រប់វិស័យ។

**-មាត្រា៥:** ដើម្បីគ្រប់គ្រងអាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យមានតុល្យភាពប្រសិទ្ធភាព និង និរន្តរភាពគោលការណ៍មួយចំនួនត្រូវបានកំណត់ដូចខាងក្រោម៖

- គ្រប់គ្រងប្រភពទឹកដើម្បីបម្រើដល់ការប្រើប្រាស់ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹកនៅក្នុងអាងទន្លេ
- គ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍ធនធានទឹកដោយឈរលើមូលដ្ឋាននៃទស្សនាទាន និងវិធីសាស្ត្រស្តីពីការគ្រប់គ្រងធនធានទឹកចម្រុះដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- គ្រប់គ្រងធនធានទឹកក្នុងអាងទន្លេ ដោយមិនគិតពីព្រំដែនរដ្ឋបាល និងស្ថិរភាពរវាងផ្នែកខាងលើនិងផ្នែកខាងក្រោមដោយឈរលើគោលការណ៍សមធម៌ និងសង្គតិភាព
- រក្សាលំហូរទឹកអប្បបរមានៃផ្លូវទឹក និងនិរន្តរភាពកម្រិតកម្ពស់ទឹកក្រោមដី រួមចំណែកទ្រទ្រង់ដល់ប្រព័ន្ធអេកូឡូស៊ី
- គ្រប់គ្រងធនធានទឹកក្នុងអាងទន្លេអន្តរជាតិ ដោយឈរលើកិច្ចព្រមព្រៀងអន្តរជាតិ គោរពអធិបតេយ្យភាពជាតិ និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក
- អភិវឌ្ឍន៍និងប្រើប្រាស់ធនធានទឹកឱ្យមានសង្គតិភាព ជាមួយនឹងធនធានធម្មជាតិដទៃទៀត ដែលមាននៅក្នុងអាងទន្លេ
- បែងចែកការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពនិងសមភាព
- រួមចំណែកលើកស្ទួយកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោយគិតគូរលើបរិមាណនិងគុណភាពទឹក
- លើកទឹកចិត្តដល់ការអភិរក្ស និងការអភិវឌ្ឍធនធានទឹកក្នុងអាងទន្លេ
- សហការជាមួយប្រទេសជិតខាងក្នុងការប្រើប្រាស់ទឹកលើគ្រប់វិស័យ។

**-មាត្រា៦:** យោងតាមលក្ខណៈភូមិសាស្ត្រ និងរបបជលសាស្ត្រ អាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជា

មានចំនួន៣៩ (សាមសិបប្រាំបួន) ដែលត្រូវបានកំណត់ជា៧(ប្រាំពីរ)តំបន់។

ផែនទីកំណត់តំបន់អាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានចែងក្នុងឧបសម្ព័ន្ធទី១ នៃ អនុក្រឹត្យនេះ។ តារាងឈ្មោះនិងទំហំផ្ទៃអាងទន្លេនីមួយៗមានចែងក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**-មាត្រា៧:** ក្រសួងធនធានទឹកនិងឧតុនិយម ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំធ្វើបញ្ជីសារពើភណ្ឌអាងទន្លេ រួមមានតំបន់ឆ្នេរ ទន្លេ ស្ទឹង ព្រែក បឹង អាងទឹកនិងល្អាងទឹកក្រោមដី។ បញ្ជីសារពើភណ្ឌនេះបង្ហាញពីឈ្មោះ ទីតាំងព្រំដែន បរិមាណ និងគុណភាពនៃធនធានទាំងនោះ។ បញ្ជីសារពើភណ្ឌអាងទន្លេត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

**-មាត្រា៨:** ដីចំណីមាត់ច្រាំងនិងឆ្នេរនៃតំបន់អាងទន្លេត្រូវកំណត់ចម្ងាយដូចតទៅ៖

- ឆ្នេរនិងពាមសមុទ្រ ចម្ងាយ១០០(មួយរយ)ម៉ែត្រគិតពីមាត់ឆ្នេរនិងមាត់(ពេលទឹកជោរអតិបរមា)
- ទន្លេ ចម្ងាយ៥០(ហាសិប)ម៉ែត្រ គិតពីមាត់ច្រាំងទន្លេ
- ស្ទឹង ចម្ងាយ៣០(សាមសិប)ម៉ែត្រ គិតពីមាត់ច្រាំងស្ទឹង
- ព្រែក ចម្ងាយ២០(ម្ភៃ)ម៉ែត្រ គិតពីមាត់ច្រាំងព្រែក
- អូរ ចម្ងាយ១០(ដប់)ម៉ែត្រ គិតពីមាត់ច្រាំងអូរ
- ប្រឡាយមេ ចម្ងាយ១០(ដប់)ម៉ែត្រ គិតពីជើងទេភ្លឺប្រឡាយផ្នែកខាងក្រៅ
- ប្រឡាយរង ចម្ងាយ៥(ប្រាំ)ម៉ែត្រ គិតពីជើងទេភ្លឺប្រឡាយផ្នែកខាងក្រៅ
- ប្រឡាយស្រោចស្រព ចម្ងាយ៣(បី)ម៉ែត្រ គិតពីជើងទេរភ្លឺប្រឡាយផ្នែកខាងក្រៅ
- អាងទឹក ចម្ងាយ១០០(មួយរយ)ម៉ែត្រគិតពីក្រិតកម្ពស់ទឹកអតិបរមា ដែលបាន តម្កល់នៅក្នុងអាងទឹក
- បឹងបួ ចម្ងាយ៥០(ហាសិប)ម៉ែត្រគិតពីក្រិតកម្ពស់ទឹកអតិបរមា ដែលបាន តម្កល់នៅក្នុងអាងទឹក
- ទំនប់អាងទឹក ចម្ងាយ២០(ម្ភៃ)ម៉ែត្រ គិតពីជើងទេរផ្នែកខាងក្រោមទំនប់អាងទឹកដែលមានកម្ពស់ទឹកតិចជាង៤(បួន)ម៉ែត្រ។ ចម្ងាយ១០០(មួយរយ)ម៉ែត្រ គិតពីជើងទេរផ្នែកខាងក្រោមទំនប់អាងទឹកដែលមានកម្ពស់ ពី៤(បួន)ម៉ែត្រទៅ៨(ប្រាំបី)ម៉ែត្រ។ ក្នុងករណីទំនប់ដែលមានកម្ពស់ លើសពី៨(ប្រាំបី)ម៉ែត្រឡើងទៅត្រូវបានកំណត់អនុក្រឹត្យ ដោយឡែក។

ដីចំណីមាត់ច្រាំង ឆ្នេរ និងពាមសមុទ្រនៅតំបន់រាជធានីឬក្រុងនៃខេត្តឬទីប្រជុំជន និងតំបន់អភិវឌ្ឍន៍ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

ដីចំណីមាត់ច្រាំង ឆ្នេរ និងពាមសមុទ្រនៃតំបន់អាងទន្លេបានកំណត់ខាងលើ ជាសម្បត្តិសាធារណៈរបស់ រដ្ឋ។

ការកំណត់ដីចំណីមាត់ច្រាំងនិងឆ្នេរខាងលើ គ្មានអានុភាពប្រតិសកម្ម ពេលអនុក្រឹត្យនេះចូលជាធរមាន។

**-មាត្រា៩:** ស្ថានភាពបច្ចុប្បន្ន និងហានិភ័យចំពោះធនធានទឹកក្នុងអាងទន្លេ ត្រូវបានធ្វើចំណាត់ថ្នាក់ជា៣(បី)កម្រិតដូចខាងក្រោម៖

- កម្រិត១: ធនធានទឹកដែលទទួលរងហានិភ័យ ដោយមិនបង្កផលប៉ះពាល់ខូចខាតធ្ងន់ធ្ងរ

ដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

- កម្រិត២: ធនធានទឹកដែលទទួលរងហានិភ័យដោយបង្កផលប៉ះពាល់ ខូចខាត និងគំរាមកំហែងជាយថាហេតុក្នុងរយៈពេលខ្លីដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ និងហេដ្ឋារចនាសម្ព័នរូបវន្ត
- កម្រិត៣: ធនធានទឹកដែលរងហានិភ័យដោយបង្កមហន្តរាយធ្ងន់ធ្ងរ និងយូរអង្វែងដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

ចំណាត់ថ្នាក់ហានិភ័យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

**-មាត្រា១០:** ក្រសួងធនធានទឹកនិងឧតុនិយម ជាស្ថាប័នមានសមត្ថកិច្ចដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ ស្របតាមស្មារតី នៃច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**-មាត្រា១១:** ដើម្បីគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍អាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យមានប្រសិទ្ធភាព និងនិរន្តរភាពត្រូវរៀបចំយន្តការដូចខាងក្រោម៖

១- រៀបចំបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

២- រៀបចំបង្កើតគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

**-មាត្រ១២:** គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន១រូប | អនុប្រធាន |
| ៤- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៥- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម១រូប | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល១រូប | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងផែនការ១រូប | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប | សមាជិក |
| ១៧- តំណាងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា១រូប | សមាជិក |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**-មាត្រា១៣:** គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំគោលការណ៍ណែនាំដល់គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេក្នុងការរៀបចំផែនការមេផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់ការគ្រប់គ្រងការការពារ ការអភិរក្ស

Draft

និងការអភិវឌ្ឍអាងទន្លេស្រប តាមគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិលើវិស័យធនធានទឹក ព្រមទាំងអនុម័តលើផែនការទាំងនោះ

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រងការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ
- សម្របសម្រួលក្នុងការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធ ដែលអាស្រ័យផលពីធនធានទឹកក្នុងអាងទន្លេលើការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រងការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ
- ជូនដំណឹងឱ្យបានទាន់ពេលវេលាដល់ប្រជាជនក្នុងមូលដ្ឋានអំពីសកម្មភាពនានាដែលទាក់ទងនឹងទឹក
- សម្របសម្រួលនិងដោះស្រាយវិវាទនានានៅក្នុងការគ្រប់គ្រងការការពារការអភិរក្សនិងការអភិវឌ្ឍអាងទន្លេ
- រក្សាទុកឯកសារ និងព័ត៌មាននានាស្តីពីបញ្ហា និងសកម្មភាពធនធានទឹកក្នុងអាងទន្លេ
- សហការជាមួយនឹងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធដើម្បីសិក្សា និងស្រាវជ្រាវទាក់ទង នឹងការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍ អាងទន្លេ
- រៀបចំរបាយការណ៍ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**-មាត្រា១៤:** គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវប្រជុំយ៉ាងតិច១(មួយ)ដង ក្នុងមួយឆ្នាំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានត្រូវផ្ទេរសិទ្ធិជូនអនុប្រធានដើម្បីដឹកនាំ អង្គប្រជុំ។

ក្នុងករណីចាំបាច់ ប្រធានអាចអញ្ជើញតំណាងមកពីក្រសួង ស្ថាប័នផ្សេងៗ មន្ត្រីជំនាញ អ្នកបច្ចេកទេស ឬតំណាងវិស័យឯកជន ដើម្បីចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឬការស្រាវជ្រាវបញ្ហាទាក់ទងនឹងសកម្មភាពពាក់ព័ន្ធ ការគ្រប់គ្រងអាងទន្លេ។

**-មាត្រា១៥:** គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេមានលេខាធិការដ្ឋានមួយ ដែលមានទីតាំងនៅក្នុងក្រសួងធនធានទឹក និងឧតុនិយម សម្រាប់កិច្ចដំណើរការសកម្មភាពរបស់ខ្លួន។

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេមានសិទ្ធិប្រើត្រារបស់ក្រសួងធនធានទឹកនិងឧតុនិយម។

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ ដឹកនាំដោយប្រធានលេខាធិការដ្ឋានមួយរូបនិងមានអនុប្រធាន លេខាធិការដ្ឋានមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

**-មាត្រា១៦:** គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេមានសមាសភាពដូចតទៅះ

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| - អភិបាលរងរាជធានី ខេត្ត | អនុប្រធាន |
| - ប្រធានមន្ទីរធនធានទឹកនិងឧតុនិយម | សមាជិកអចិន្ត្រៃយ៍ |
| - ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - ប្រធានមន្ទីរកសិកម្ម | សមាជិក |
| - ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| - ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូន | សមាជិក |

Draft

- ប្រធានមន្ទីរឧស្សាហកម្មនិងសិប្បកម្ម សមាជិក
- ប្រធានមន្ទីររ៉ែនិងថាមពល សមាជិក
- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ សមាជិក
- ប្រធានមន្ទីរទេសចរណ៍ សមាជិក
- ប្រធានមន្ទីររៀបចំដែនដី នគររូបនីយកម្ម និង សុរិយោដី សមាជិក
- ប្រធានមន្ទីរផែនការ សមាជិក
- នាយខណ្ឌរដ្ឋបាលព្រៃឈើ សមាជិក
- នាយខណ្ឌរដ្ឋបាលជលផល សមាជិក
- អភិបាលស្រុក ខណ្ឌ ក្រុង មេឃុំ ចៅសង្កាត់ដែលមានការពាក់ព័ន្ធ សមាជិក។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការអាចអញ្ជើញមន្ត្រីជំនាញ ឬបុគ្គលដែលតំណាងឱ្យសហគមន៍ផ្សេងៗទៀត ដែលបានទទួលផលក្នុងអាងទន្លេឱ្យចូលរួមជាអ្នកអង្កេតការណ៍នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការខាងលើ។

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

-មាត្រា១៧: គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវមានលេខាធិការដ្ឋានមួយដើម្បីធានា ដល់កិច្ចដំណើរការ ឱ្យមានប្រសិទ្ធិភាពខ្ពស់និងអាចប្រើគ្រាដោយឡែករបស់ខ្លួន។ លេខាធិការដ្ឋានមានទីតាំងស្ថិតនៅក្នុងមន្ទីរធនធានទឹកនិងឧតុនិយម រាជធានី ខេត្តដែលមានអភិបាលនៃ គណៈអភិបាលរាជធានី ខេត្តជាប្រធានគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។ ប្រធានមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត នេះជាប្រធានលេខាធិការដ្ឋាន។

គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេត្រូវកោះប្រជុំយ៉ាងតិច២(ពីរ) ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ អាចកោះប្រជុំជាវិសាមញ្ញបាន។

ប្រធានគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវរាយការណ៍ពីលទ្ធផលរាល់កិច្ចប្រជុំនិងសកម្មភាពការងារប្រចាំឆ្នាំជូនប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

-មាត្រា១៨: គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេមានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំទបញ្ហាផ្ទៃក្នុង និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការអភិរក្ស ការបែងចែកទឹក ការស្តារឡើងវិញ និងការអភិវឌ្ឍអាងទន្លេស្របតាមគោលនយោបាយជាតិលើវិស័យធនធានទឹក
- បញ្ជូនរាល់ផែនការទៅគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ ដើម្បីពិនិត្យនិងសម្រេច
- តាមដាននិងសម្របសម្រួល រាល់សកម្មភាពទាំងអស់របស់ក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តផែនការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍អាងទន្លេ
- បន្តណែនាំអំពីវិធានការសម្រាប់ការពារបរិស្ថានទឹក ការធ្វើអាជីវកម្ម ការប្រើប្រាស់និងការអភិវឌ្ឍធនធានទឹក និងវិធានការសម្រាប់បង្ការហានិភ័យ និងការកាត់បន្ថយគ្រោះអាសន្នដែលបង្កដោយទឹកក្នុងអាងទន្លេ
- បន្តណែនាំអំពីវិធានការដល់ភ្នាក់ងារជំនាញដើម្បីឆ្លើយតបនឹងសកម្មភាពនានាដែលបំពុលទឹក
- ជូនដំណឹងដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងអាងទន្លេឱ្យបានទាន់ពេលវេលាអំពីគ្រោះអាសន្ន ដែលបណ្តាលមកពីទឹក
- សម្របសម្រួលនិងដោះស្រាយរាល់ទំនាស់នានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេប្រគល់ជូន។

Draft

-**មាត្រា១៩:** លេខាធិការដ្ឋាននៃគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេមានតួនាទីនិងភារកិច្ច ដូចតទៅៈ

១. ផ្តល់ការគាំទ្រផ្នែករដ្ឋបាលនិងការសម្របសម្រួលផ្នែកហិរញ្ញវត្ថុ ដល់គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រង អាងទន្លេ ក្នុងការរៀបចំផែនការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍អាងទន្លេ។

២. សម្របសម្រួលក្នុងការប្រមូលព័ត៌មាន ការចងក្រងប្រព័ន្ធទិន្នន័យ និងការរៀបចំរបាយការណ៍ជូនគណៈកម្មាធិការ រាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

៣. តាមដាននិងត្រួតពិនិត្យការអនុវត្តសេចក្តីសម្រេចនានា ដែលបានដាក់ចេញដោយគណៈកម្មាធិការ រាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

៤. ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មាធិការរាជធានីខេត្តគ្រប់គ្រងអាងទន្លេប្រគល់ជូន។

-**មាត្រា២០:** គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ និងគណៈកម្មាធិការរាជធានីខេត្ត គ្រប់គ្រងអាងទន្លេត្រូវមានថវិកាសម្រាប់ដំណើរការរដ្ឋបាល។ ថវិកានេះត្រូវស្ថិតក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំ របស់ក្រសួងធនធានទឹក និងឧតុនិយម និងហិរញ្ញប្បទានពីដៃគូរ អភិវឌ្ឍន៍។

-**មាត្រា២១:** គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេឱ្យស្របនឹងគោលនយោបាយជាតិ ផែនការយុទ្ធ សាស្ត្រអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល។

ក្នុងការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្សអាងទន្លេគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវចាត់ឱ្យមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយពីក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធហើយអនុម័តលើផែនការមេផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពទាំងនេះដើម្បីធ្វើការបោះពុម្ពផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានា។

-**មាត្រា២២:** ការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ ត្រូវពិនិត្យពិចារណាដោយឈរលើគោលការណ៍ដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ។

-**មាត្រា២៣:** អាណត្តិរបស់ផែនការមេមានសុពលភាពពី១០(ដប់)ទៅ១៥(ដប់ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃទទួលបានការអនុម័តពីគណៈ កម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

អាណត្តិរបស់ផែនការយុទ្ធសាស្ត្រមានសុពលភាពពី៣(បី)ទៅ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃទទួលបានការអនុម័តពីគណៈ កម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

អាណត្តិរបស់ផែនការសកម្មភាពពី ១(មួយ)ទៅ៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃទទួលបានការ អនុម័តពី គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវដឹកនាំ សម្របសម្រួល ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្ត ផែនការគ្រប់គ្រងអាងទន្លេ រៀងរាល់ឆមាសនៃឆ្នាំនីមួយៗ។

ក្នុងករណីដែលការអនុវត្តផែនការគ្រប់គ្រងអាងទន្លេដំណើរការបានល្អ គណៈកម្មាធិកាជាតិគ្រប់គ្រងអាងទន្លេអាច ពន្យាសុពលភាពបន្តបាន ប៉ុន្តែមិនត្រូវលើសពី៥(ប្រាំ)ឆ្នាំ គិតពីថ្ងៃដែលអាណត្តិរបស់ផែនការគ្រប់គ្រងអាងទន្លេអស់ សុពលភាព។ រាល់ផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេណាមួយដែលពិនិត្យឃើញថា មិនអាចអនុវត្តន៍បន្តទៅមុខបាន គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវ ណែនាំឱ្យរៀបចំកែសម្រួលជាថ្មីឡើងវិញ ស្របតាមកាលានុវត្តភាព។

Draft

នីតិវិធីនៃការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

**-មាត្រា២៤:** វិធានការសំខាន់ៗសម្រាប់គ្រប់គ្រងអាទន្លេមានការគ្រប់គ្រងបរិមាណនិងគុណភាពទឹក វិធីការពារប្រភពទឹក ការបង្ការនិងកាត់បន្ថយគ្រោះអាសន្នបង្កឡើងដោយទឹក។

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ ត្រូវរៀបចំសៀវភៅណែនាំលម្អិត ស្តីពី គោលការណ៍ និងវិធានការនៃការគ្រប់គ្រងអាងទន្លេ។

**-មាត្រា២៥:** គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ និងគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវរៀបចំអនុវត្តន៍ការត្រួតពិនិត្យនិងការវាយតម្លៃធនធានទឹក និងធនធានពាក់ព័ន្ធ។

សកម្មភាពសម្រាប់ត្រួតពិនិត្យ និងការវាយតម្លៃធនធានទឹក និងធនធានពាក់ព័ន្ធក្នុងអាងទន្លេរួមមាន៖

- ធ្វើអង្កេតនិងធ្វើបញ្ជីសារពើភណ្ឌធនធានទឹក ដោយផ្តោតទៅលើបរិមាណនិងគុណភាពទឹកលើដីនិងក្រោមដីក្នុងអាងទន្លេនីមួយៗ
- ធ្វើអង្កេតអំពីបរិស្ថានពាក់ព័ន្ធ និងធនធានទឹកក្នុងអាងទន្លេ ដោយគិតបញ្ចូលទាំងការត្រួតពិនិត្យអំពីផលប៉ះពាល់ដែលអាចកើតមានឡើងពីការប្រែប្រួលអាកាសធាតុ
- រៀបចំចងក្រងទិន្នន័យនិងព័ត៌មានដោយធ្វើផែនទីស្តីពីស្ថានភាពអាងទន្លេ ផែនទីអភិរក្ស ធនធានទឹក ផែនទីទឹកក្រោមដី រួមទាំងផែនតំបន់ប្រភពទឹកសម្រាប់បំពេញទឹកក្រោមដីឡើងវិញ
- រៀបចំបញ្ជីកំណត់ទីតាំងធនធានទឹកដែលរងការបំពុល ការថយចុះបរិមាណ គុណភាព និងការធ្វើអាជីវកម្មទឹក ការប្រើប្រាស់ធនធានទឹក និងការបង្ហូរទឹកសំណល់ចូលក្នុងប្រភពទឹកអាងទន្លេ
- បង្កើតនិងរក្សាទុកនូវប្រព័ន្ធព័ត៌មាននិងមូលដ្ឋានទិន្នន័យ។

## ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យ៩៨ អនក្រ.បក
## ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ

តារាងឈ្មោះនិងទំហំផ្ទៃអាងទន្លេនីមួយៗ

| ល.រ | លេខកូដអាងទន្លេ | ឈ្មោះទន្លេ | ផ្ទៃអាងទន្លេ គម² |
|---|---|---|---|
| ១.តំបន់មាត់សមុទ្រ | | | |
| ១ | ១ | ព្រែកកំពង់បាយ | ៣០១៨ |
| ២ | ២ | ព្រែកទឹកសាប | ១៥២៩ |
| ៣ | ៣ | ព្រែកស្រែអំបិល | ២៦៥៣ |
| ៤ | ៤ | ព្រែកអណ្តូងទឹក | ២៤៦០ |
| ៥ | ៥ | ព្រែកត្រពាំងរូង | ២៦១៥ |
| ៦ | ៦ | ព្រែកតាតៃ | ១៦១៩ |
| ៧ | ៧ | ព្រែកកោះប៉ោ | ៣១០៩ |
| ៨ | ៨ | ស្ទឹងមេទឹក | ១០៤៣ |
| | | **សរុប១** | ១៨០៤៥ |
| ២.តំបន់ទន្លេបាសាក់ | | | |
| ៩ | ៩ | ស្ទឹងតន់ហន់ | ១៧៦៥ |
| ១០ | ១០ | ស្ទឹងស្លាគូ | ២៤៨៥ |
| ១១ | ១១ | ស្ទឹងព្រែកត្នោត | ៧០៥៥ |
| | | **សរុប២** | ១១៣០៥ |
| ៣.តំបន់ទន្លេសាប | | | |
| ១២ | ស្ទឹងក្រាំងន្លៃ | | ៣០៣៣ |
| ១៣ | ស្ទឹងបរិបូណ៌ | | ៣០០៣ |
| ១៤ | ស្ទឹងបំណក់ | | ១១១៦ |

| ល.រ | លេខកូដអាងទន្លេ | ឈ្មោះទន្លេ | ផ្ទៃអាងទន្លេ គម² |
|---|---|---|---|
| ១៥ | ស្ទឹងពោធិ៍សាត់ | | ៥៩៦៤ |
| ១៦ | ស្ទឹងស្វាយដូនកែវ | | ២២២៨ |
| ១៧ | ស្ទឹងមោងឫស្សី ស្ទឹងដូនទ្រី | | ១៤៦៨ |
| ១៨ | ស្ទឹងសង្កែ | | ៦០៥២ |
| ១៩ | ស្ទឹងមង្គលបូរី | | ៥២៦៤ |
| ២០ | ស្ទឹងសិរីសោភ័ណ | | ៥៥៩៣ |
| ២១ | ស្ទឹងស្រែង | | ៩៩៣១ |
| ២២ | ស្ទឹងសៀមរាប | | ៣៦១៩ |
| ២៣ | ២៣ | ស្ទឹងជីក្រែង | ២ ៧១៤ |
| ២៤ | ២៤ | ស្ទឹងស្ទោង | ៤ ៣៥៧ |
| ២៥ | ២៥ | ស្ទឹងសែន | ១៦ ៣៤២ |
| ២៦ | ២៦ | ស្ទឹងជីនិត | ៨ ២៣៦ |
| ២៧ | ៣៩ | បឹងទន្លេសាប | ២ ៧៤៣ |
| | | **សរុប ៣** | ៨១ ៦៦៣ |
| **៤. តំបន់ទន្លេភាគឦសាន** | | | |
| ២៨ | ២៧ | ទន្លេសេកុង | ៥ ៥៦៤ |
| ២៩ | ២៨ | ទន្លេសេសាន | ៧ ៦២១ |
| ៣០ | ២៩ | ទន្លេស្រែពក | ១២ ៧៨០ |
| ៣១ | ៣០ | ព្រែកព្រះ | ២ ៣៩៩ |
| ៣២ | ៣១ | ព្រែកក្រៀង | ៣ ៣៣១ |
| ៣៣ | ៣២ | ព្រែកកាំពីរ | ១ ១៤២ |
| ៣៤ | ៣៣ | ព្រែកទេ | ៤ ៣៦៣ |
| ៣៥ | ៣៤ | ព្រែកឆ្លូង | ៥ ៥៩៩ |
| | | **សរុប ៤** | ៤២ ៨០០ |
| **៥. តំបន់មេគង្គលើ(កម្ពុជា)** | | | |
| ៣៦ | ៣៥ | ដៃស្ទឹង ព្រែកទន្លេមេគ | ១០ ៣៧៣ |
| | | **សរុប ៥** | ១០ ៣៧៣ |
| **៦. តំបន់ភាគអាគ្នេយ៍** | | | |
| ៣៧ | ៣៦ | ទន្លេវ៉ៃគោ | ៦ ៦១៨ |
| | | **សរុប ៦** | ៦ ៦១៨ |
| **៧. តំបន់ដីសណ្តមេគង្គក្រោម** | | | |
| ៣៨ | ៣៧ | មេគង្គដីសណ្តកម្ពុជា | ៨ ៧២៣ |
| ៣៩ | ៣៨ | តំបន់លិចទឹកទន្លេមេគង្គ | ១ ៥០៨ |
| | | **សរុប ៧** | ១០ ២៣១ |
| | | **សរុបរួម** | ១៨១ ០៣៥ |

## ៣.៣១. អនុក្រឹត្យស្តីពី ការកំណត់ប្រភេទផល ផលិតផលជលផល ដែលកំពុងរងគ្រោះថ្នាក់ ឆ្នាំ២០០៩

អនុក្រឹត្យលេខ/១២៣អនក្រ.បក ស្តីពីការកំណត់ប្រភេទផលផលិតផលជលផល ដែលកំពុងរងគ្រោះថ្នាក់អនុម័ត នៅថ្ងៃទី ១២ ខែសីហា ២០០៩ ដោយរាជរដ្ឋាភិបាល ដែលមានមាត្រាពាក់ព័ន្ធនិងគម្រោងនេះដូចតទៅ ៖

-មាត្រា១: អនុក្រឹត្យនេះ កំណត់អំពីប្រភេទផល ផលិតផលជលផលទឹកសាប និងសមុទ្រ ដែលមានប្រភព ចេញពីធនធានជលផល កំពុងរងគ្រោះថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារ គ្រប់គ្រង និងអភិរក្សឱ្យមាននិរន្តរភាព ស្របតាមច្បាប់ស្តីពីជលផល។

-មាត្រា២: ប្រភេទធនធានជលផល ដែលកំពុងរងគ្រោះថ្នាក់ ត្រូវបានចាត់ថ្នាក់ជាបីក្រុមទៅតាមលក្ខខណ្ឌ និងស្ថានភាព នៃភាពកំពុងរងគ្រោះដូចខាងក្រោម:

១. **ក្រុមប្រភេទជិតផុតពូជ៖** ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរងគ្រោះថ្នាក់ ដែលចំពោះមុខ ផលស្តុកក្រុមប្រភេទនេះ កំពុងប្រឈមទៅនឹងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរហើយអាច

វិនាសផុតពូជទាំងស្រុង នៅក្នុងធម្មជាតិនាពេលអនាគតដ៏ខ្លីខាងមុខ ដោយបរិមាណសរុបបានថយចុះយ៉ាង តិច៨០ (ប៉ែតសិប) ភាគរយក្នុងរយៈពេល ១០ (ដប់)ឆ្នាំចុងក្រោយ ឬក្នុងរយៈពេលបីជំនាន់តំណពូជ កន្លងមកតាមរយៈការអង្កេត ការប៉ាន់ប្រមាណ ឬការសន្និដ្ឋាន។

២. **ក្រុមប្រភេទកំពុងរងគ្រោះ ៖** ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរងគ្រោះថ្នាក់ដែលមានភស្តុតាង បង្ហាញច្បាស់ថាក្រុមប្រភេទនេះ កំពុងប្រឈមនឹងគ្រោះថ្នាក់ដ៏ខ្លាំង ហើយអាចវិនាសផុតពូជនៅក្នុងធម្មជាតិនាពេលអនាគតមិនយូរប៉ុន្មាន ដោយបរិមាណសរុបបានថយចុះយ៉ាងតិច ៥០(ហាសិប)ភាគរយក្នុងរយៈពេល ១០(ដប់)ឆ្នាំចុងក្រោយ ឬក្នុងរយៈពេលបីជំនាន់តំណពូជ កន្លងមកតាមរយៈការអង្កេត ការប៉ាន់ប្រមាណ ការសន្និដ្ឋាន ឬការរំពឹងទុក។

៣. **ក្រុមប្រភេទងាយរងគ្រោះ ៖** ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរងគ្រោះដែលងាយគ្រោះថ្នាក់ដ៏ខ្លាំង ហើយអាចវិនាសផុតពូជនៅក្នុងធម្មជាតិ នាពេលអនាគតខាងមុខដោយ បរិមាណសរុបបានថយចុះយ៉ាងតិច២០(ម្ភៃ) ភាគរយក្នុងរយៈពេល១០(ដប់)ឆ្នាំចុងក្រោយ ឬរយៈពេលបីជំនាន់តំណពូជកន្លងមកតាមរយៈការង្កេត ការប៉ាន់ប្រមាណ ការសិន្នដ្ឋាន ឬការរំពឹងទុក។

## ៣.៣២. អនុក្រឹត្យ ស្តីពីការបង្កើតមូលនិធិបរិស្ថាននិងសង្គម ឆ្នាំ ២០១៦

Draft

អនុក្រឹត្យលេខ ២៣៨ អនក្រ.បក ស្តីពីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គមបានអនុម័តនៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ដោយរាជរដ្ឋាភិបាល ដែលមានមាត្រាពាក់ព័ន្ធនិងគម្រោងនេះដូចតទៅ ៖

- **មាត្រា១**

អនុក្រឹត្យនេះ មានគោលបំណងបង្កើត "មូលនិធិបរិស្ថាន និងសង្គម" ដែលសរសេរជាអក្សរកាត់ថា "មប.ស." ដែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រង ចាត់ចែង និងការទទួលខុសត្រូវ "គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម" ដែលសរសេរជាអក្សរកាត់ថា "គម.ន.ស."។

- **មាត្រា២**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែង "មូលនិធិបរិស្ថាន និងសង្គម" ឱ្យមានប្រសិទ្ធភាព ស័ក្តសិទ្ធភាព តម្លាភាព ដើម្បីស្តារបរិស្ថានឡើងវិញ គាំពារបរិស្ថាន អភិរក្សជីវៈចម្រុះ និងប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប មាននិរន្តរភាព និងការរស់នៅដោយចីរភាពសម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

- **មាត្រា៣**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើសកម្មភាពទាក់ទង នឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម។

- **មាត្រា៤**

មូលនិធិបរិស្ថាននិងសង្គម ស្ថិតនៅក្រោមការគ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវដោយគណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម ដែលមានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រី ឬថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងបរិស្ថាន | ១រូប | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | អនុប្រធាន |
| - តំណាងក្រសួងបរិស្ថាន | ១រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានគាំពារបរិស្ថាន | ១រូប | សមាជិកអចិន្ត្រៃយ៍ |

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

- **មាត្រា៥**

គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- កំណត់នូវគោលនយោបាយ និងយុទ្ធសាស្ត្រប្រមូល គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម
- ជុំរុញម្ចាស់គម្រោងឱ្យបង់មូលនិធិបរិស្ថាននិងសង្គម
- ចាត់វិធានការរដ្ឋបាលនិងផ្លូវច្បាប់ ក្នុងការប្រមូលមូលនិធិបរិស្ថាន និងសង្គមពីម្ចាស់គម្រោង ដែលមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថាន នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន
- ធ្វើការសម្របសម្រួលជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន និងសប្បុរសជន ក្នុងការកៀរគរមូលនិធិបរិស្ថាន និងសង្គម
- ពិនិត្យ និងសម្រេចលើគម្រោងចំណូល ចំណាយរបស់មូលនិធិសម្រាប់បម្រើឱ្យការស្តារបរិស្ថានឡើងវិញ ការគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប មាននិរន្តរភាព និងការរស់នៅដោយចីរភាព
- គ្រប់គ្រង ប្រើប្រាស់ និងបែងចែកមូលនិធិដែលទទួលបាន ពីគម្រោងអភិវឌ្ឍឯកជន និងសាធារណៈ
- ពិនិត្យសម្រេចសំណើសុំប្រើប្រាស់មូលនិធិ បរិស្ថាននិងសង្គម សម្រាប់បម្រើដល់វិស័យបរិស្ថាន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តប្រើប្រាស់មូលនិធិនិងសង្គម ដែលបានផ្តល់ឱ្យ
- ធ្វើការណែនាំបច្ចេកទេសលើការគ្រប់គ្រង និងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម សម្រាប់គម្រោងបម្រើវិស័យបរិស្ថាន
- ធ្វើរបាយការណ៍ អំពីស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍វឌ្ឍនភាពរបស់មូលនិធិបរិស្ថាន និងសង្គម រៀងរាល់ត្រីមាស ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន

- **មាត្រា៦**

គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គមមានលេខាធិការដ្ឋាននៅអគ្គនាយកដ្ឋានគាំពារបរិស្ថាន។
ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

- **មាត្រា៧**

គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គមប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន សម្រាប់ដំណើរការការងារ។

- **មាត្រា៨**

មប.ស មានប្រភពចំណូលមកពី៖

- បុព្វលាភពីម្ចាស់គម្រោងអភិវឌ្ឍឯកជន និងសាធារណៈ ដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន
- ប្រាក់ចំណូលពីកិច្ចគាំពារបរិស្ថាន សេវាប្រព័ន្ធអេកូឡូស៊ី និងអភិរក្សចំរុះ
- អំណោយ ឬជំនួយថវិកា សម្ភារ ឧបករណ៍នានាពីសប្បុរសជន ដៃគូអភិវឌ្ឍ ស្ថាប័នឯកជនជាតិ ឬអន្តរជាតិនានា
- កម្រៃសេវាផ្សេងៗពីវិស័យបរិស្ថាន
- ប្រភពផ្សេងៗទៀត។

- **មាត្រា៩**
- ម.ប.ស ត្រូវរក្សាទុកក្នុងគណនីមួយរបស់រតនាគារជាតិ ឬធនាគារពាណិជ្ជជាដៃគូណាមួយ តាមការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- **មាត្រា១០**

មូលនិធិបរិស្ថាន និងសង្គមត្រូវប្រើប្រាស់ក្នុងសកម្មភាព ដូចខាងក្រោម៖

- ការគាំពារបរិស្ថាន និងការអភិរក្សព្រៃឈើ ជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ីឡើងវិញ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងធ្វើឱ្យប្រសើរឡើង នូវជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ដែលរស់ក្នុងនិងក្បែរតំបន់គម្រោងអភិវឌ្ឍ ឬតំបន់ផ្សេងៗទៀត
- ការសិក្សាស្រាវជ្រាវបច្ចេកទេស និងវិទ្យាសាស្ត្រជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ី
- ការសិក្សាស្រាវជ្រាវបច្ចេកទេស និងវិទ្យាសាស្ត្រលើវិស័យបរិស្ថាន
- ការផ្សព្វផ្សាយអំពីវិស័យបរិស្ថាន
- ទ្រទ្រង់កម្មវិធីបង្កើតសហគមន៍ការពារធម្មជាតិ និងសហគមន៍នានាបម្រើឱ្យវិស័យបរិស្ថាន
- ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យបរិស្ថាន និងធនធានធម្មជាតិ
- ការអប់រំផ្សព្វផ្សាយលើតំបន់ការពារធម្មជាតិ។
- ការសិក្សាស្រាវជ្រាវបច្ចេកទេស និងវិទ្យាសាស្ត្រលើវិស័យបរិស្ថាន

- **មាត្រា១១**

នីតិវិធីនៃការគ្រប់គ្រងការប្រមូលចំណូល និងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គមត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៣.៣៣. គោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ ២០០៩

ក្រសួងបរិស្ថានបានចេញ គោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ដែលមានប្រការពាក់ព័ន្ធនិងគម្រោងនេះដូចតទៅ៖

**-ប្រការ២:** ម្ចាស់គម្រោងជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬក្រុមហ៊ុនរដ្ឋ ជាក្រសួង/ស្ថាប័នរដ្ឋ ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញលើគម្រោង ស្នើឡើង ព្រមទាំងសកម្មភាព ដែលមានស្រាប់ និងកំពុងដំណើរការ ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៧២អនក្រ.បកចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ស្តីពី "កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន" ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យនិងផ្តល់យោបល់លើកលែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ដែលសម្រេចដោយរាជរដ្ឋាភិបាល។

**-ប្រការ៤:** ម្ចាស់គម្រោងដូចមានចែងនៅក្នុងប្រការ២ និង៣ខាងលើ អាចប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនទីប្រឹក្សា ដែលជាអ្នកទទួលខុសត្រូវ ផ្ទាល់ក្នុងការរៀបចំរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញដោយគោរពទៅតាមគោលការណ៍ណែនាំទូទៅនេះ។

**-ប្រកាស៧:** នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត ត្រូវពិនិត្យ និងផ្តល់យោបល់លើទីតាំងគម្រោង ដូចមានចែងនៅក្នុងប្រការ ២ និង ៣ខាងលើ ដើម្បី



Draft

កំណត់ឱ្យច្បាស់លាស់ថា គម្រោងនេះគួរតម្រូវឱ្យរៀបចំរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។

## ៣.៣៤. គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ឆ្នាំ ២០១៣

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង បានទទួលការឯកភាពពីគណៈរដ្ឋមន្រ្តីក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣។ ដែលមានចំណុចពាក់ព័ន្ធនឹងគម្រោងមានដូចខាងក្រោមៈ

**១.សេចក្តីផ្តើមៈ**

សំដៅរួមចំណែកដល់កិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងព្រៃឈើ ការសិក្សាគុណភាពទឹក ដី ខ្យល់ និងសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ីប្រកបដោយប្រសិទ្ធភាព និងតាមទិសដៅ របស់អង្គការសហប្រជាជាតិស្តីពី “អនាគតដែលយើងចង់បាន” ដែលរាជរដ្ឋាភិបាលបាន នឹងកំពុងអនុវត្តន៍រាល់ថ្ងៃ លើវិស័យជលផល និងវិស័យព្រៃឈើ ការប្រើប្រាស់ថាមពល និងទឹកដោយសន្សំសំចៃ ការប្រើប្រាស់ថាមពលកកើតឡើងវិញ ប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន និងការអនុវត្តនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី ដើម្បីថែរក្សា ធនធានធម្មជាតិជូនអ្នកជំនាន់ក្រោយ ដោយដើរទន្ទឹមនឹងការអភិវឌ្ឍ សេដ្ឋកិច្ចជាតិ។

គោលការណ៍អភិវឌ្ឍន៍បៃតង គឺធ្វើឱ្យមានតុល្យភាពនៃការអភិវឌ្ឍ សេដ្ឋកិច្ច ជាមួយនឹងបរិស្ថាន សង្គម និងវប្បធម៌ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

**២.ចក្ខុវិស័យៈ**

គោលនយោបាយជាតិនេះ មានចក្ខុវិស័យធ្វើឱ្យមានតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចជាមួយ នឹងបរិស្ថានសង្គម វប្បធម៌ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព តាមរយៈការបញ្ជ្រាប ការបន្សុី ការបន្សាំ និងធ្វើឱ្យមានសុខដុមនីយកម្មរវាងគោលការណ៍អភិវឌ្ឍន៍បៃតង និងគោលនយោបាយជាតិ។

**៣.គោលបំណង និងគោលដៅៈ**

**៣.១-គោលបំណង**

គោលនយោបាយជាតិនេះ មានគោលបំណងលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរស់ប្រជាជនទាំងអស់ប្រកកដោយសុខដុមនីយកម្មជាមួយនឹងសុវត្ថិភាពអេកូឡូស៊ី តាមរយៈការអភិវឌ្ឍបៃតង សេដ្ឋកិច្ចខៀវ សេដ្ឋកិច្ចបៃតង ការការពារបរិស្ថាន ប្រព័ន្ធសុវត្ថិភាពសង្គម និងការរក្សាអត្តសញ្ញាណវប្បធម៌ជាតិ។

Draft

**៣.២-គោលដៅ**

- ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយតុល្យភាពជាមួយបរិស្ថាន សង្គម និងវប្បធម៌។
- បង្កើតបរិយាកាសអំណោយផលសម្រាប់អភិវឌ្ឍន៍បៃតងប្រកបដោយសមធម៌ តុល្យភាព ភាតរភាព និងគុណភាពក្នុងប្រព័ន្ធសេដ្ឋកិច្ច សង្គម និងអេកូឡូស៊ី ដែលរក្សាបាននូវតម្លៃវប្បធម៌ជាតិ។
- ធ្វើការគ្រប់គ្រងឱ្យមានប្រសិទ្ធិភាពលើសិទ្ធិទទួលបានការគ្រប់គ្រងធនធានទឹក និងអនាម័យ សិទ្ធិទទួលបានសន្តិសុខ ស្បៀង និងសុវត្ថិភាពចំណីអាហារ សិទ្ធិទទួលបានការអភិវឌ្ឍ ការអភិរក្ស ព្រៃឈើ និងធនធានទឹកចម្រុះ និងការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព សិទ្ធិទទួលបានថាមពលកកើតឡើងវិញ និងប្រសិទ្ធិភាពថាមពល សិទ្ធិទទួលបានព័ត៌មាន ចំណេះដឹង និងបំណិន សិទ្ធិទទួលបានមធ្យោបាយបម្រើឱ្យជីវភាពសង្គម និងបរិស្ថានកាន់តែល្អប្រសើរ និងសិទ្ធិទទួលបានហិរញ្ញវត្ថុក្នុងការបង្កើតអាជីវកម្មខ្នាតតូច មធ្យម និងការវិនិយោគ។
- លើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលលើការងារអភិវឌ្ឍន៍បៃតង។
- ពង្រឹងការផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង បទពិសោធន៍ល្អៗ បច្ចេកទេស បច្ចេកវិទ្យា និងការវិនិយោគទាក់ទងនឹងការងារបៃតង។
- ជំរុញកិច្ចសហប្រតិបត្តិការអភិវឌ្ឍបៃតងក្នុងក្របខ័ណ្ឌថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ តំបន់ ព្រមទាំងពិភពលោក។

## ៤. ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ:

ដើម្បីអនុវត្តន៍គោលនយោបាយជាតិនេះ ឱ្យសម្រេចបានជោគជ័យដូចបានរំពឹងទុក ប្រកបដោយប្រសិទ្ធិភាព និងតម្លាភាព ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងត្រូវមានប្រព័ន្ធតាមដានត្រួតពិនត្យ វាយតម្លៃសំណើកែលម្អការអនុវត្ត ដោយផ្តោតលើសូចនាករដូចខាងក្រោមៈ

- ក្របខណ្ឌច្បាប់ និងស្ថាប័នជាតិស្តីពីការអភិវឌ្ឍបៃតង ត្រូវបានបង្កើតឡើង និងកែសម្រួលហើយប្រព័ន្ធនៃការកំណត់ការគ្រប់គ្រង ការតាមដាន និងការវាយតម្លៃ ត្រូវបានកែលម្អ។
- ប្រភព និងមូលហេតុ ដែលធ្វើឱ្យពុំមាននិរន្តរភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ត្រូវបានកំនត់ និងវិភាគ
- ការកសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍បៃតង ត្រូវបានកែលម្អ និងពង្រឹងបន្ថែម។
- កម្រិតលើការអប់រំដល់ផ្នែកសាធារណៈ ឯកជន សង្គមស៊ីវិល និងសាធារណជន អំពីការអភិវឌ្ឍបៃតងត្រូវបានបង្កើតឡើង ហើយការចូលរួមរបស់សាធារណជននៅថ្នាក់មូលដ្ឋាននៅក្នុងសកម្មភាព និងកម្មវិធីផ្សព្វផ្សាយលើការងារអភិវឌ្ឍន៍បៃតងត្រូវបានលើកទឹកចិត្ត និងជំរុញឱ្យមានការចូលរួម។
- ការអភិវឌ្ឍបៃតងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានកែលម្អ។
- ផលប៉ះពាល់ដល់បរិស្ថានសង្គម និងវប្បធម៌ ដែលបណ្តាលមកពីសកម្មភាពការអភិវឌ្ឍសេដ្ឋកិច្ចត្រូវបានកាត់បន្ថយ។

## ៣.៣៥. យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា

### ចតុកោណទី១. ការលើកស្ទួយវិស័យកសិកម្ម

វិស័យកសិកម្មនៅតែមានតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច, ធានាសមធម៌, ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា តាមអតិក្រម និងក្នុងវិសាលភាព និងល្បឿនថ្មីដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាល នៃការអភិវឌ្ឍតាមវិបុលកម្ម (បើកទូលាយ) ពោលគឺ ពឹងផ្អែកសំខាន់លើធនធានមានស្រាប់ (ធនធានដី និងធនធានធម្មជាតិផ្សេងទៀត) និងពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្ម តាមបែបប្រពៃណីឈានទៅរកដំណាក់កាលថ្មី ដែលផ្តោតលើផលិតកម្មតាមបែបប្រពលវប្បកម្ម (ស៊ីជម្រៅ) ពោលគឺ ពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស, បច្ចេកវិទ្យាថ្មី, ការស្រាវជ្រាវ និងការអភិវឌ្ឍ, យន្តូបនីយកម្មព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកំពស់ផលិតភាព, ពិពិធភាវូបនីយកម្មមុខដំណាំ និងផលិតផលកសិកម្មផ្សេងទៀត រួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្មផង ដោយគិតគូរផងដែរ អំពីភាពចាំបាច់ក្នុងការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធិភាព និងការពារចីរភាពបរិស្ថាន និងធនធានធម្មជាតិ។ ទន្ទឹមនិងនេះ ការបន្តជំរុញការធ្វើពាណិជ្ជូបនីយកម្ម និងការអភិវឌ្ឍ វិស័យកសិកម្ម ឧស្សាហកម្ម នឹងជួយបង្កើនចំណូលជូនប្រជាកសិករ។

#### *មុំទី១. ការលើកកំពស់ផលិតភាព, ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម*

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤ គឺការលើកកម្ពស់ផលិតភាព និងការធ្វើពិពិធភាវូបនីយកម្មតាមរយៈការពង្រឹងសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ ដោយផ្តោតលើអន្តរាគមន៍ប្រទាក់ក្រឡាក្នុងវិស័យពាក់ព័ន្ធ ដូចជាការប្រើប្រាស់ធាតុចូលកសិកម្មតាមបច្ចេកទេស, ការស្រាវជ្រាវ និងការអភិវឌ្ឍប្រព័ន្ធសេវាបច្ចេកទេសកសិកម្ម, ការសាងសង់ និងថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ, ការផ្តល់ឥណទានជនបទ និងមីក្រូហិរញ្ញវត្ថុ, ការពង្រីកទីផ្សារកសិកម្ម, ការរៀបចំសហគមន៍កសិកម្ម និងការគ្រប់គ្រងដីធ្លីកសិកម្ម។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយ រាជរដ្ឋាភិបាលនីតិកាលទី៤ នឹងខិតខំរក្សាកំណើនក្នុងវិស័យកសិកម្មនេះ ឱ្យបានក្នុងរង្វង់៥%ក្នុងមួយឆ្នាំ ដោយបន្តលើកកម្ពស់ផលិតភាព, ធ្វើពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម។

#### *មុំទី២. ការលើកកំពស់ចិញ្ចឹមសត្វ និងវារីវប្បកម្ម*

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤ បានផ្តោតការយកចិត្តទុកដាក់ទៅលើការកែទម្រង់ជលផល ក្នុងគោលដៅបំពេញ

Draft

តម្រូវការអាហារូបត្ថម្ភ និងថែរក្សាធនធានមច្ឆជាតិឱ្យបានគង់វង្ស តាមរយៈការរៀបចំសហគមន៍នេសាទ, ការកែទម្រង់ការគ្រប់គ្រងឡូត៍នេសាទ, ការអភិរក្សព្រៃលិចទឹក, ការប្រយុទ្ធនិងការនេសាទខុសច្បាប់ និងការបំផុសវារីវប្បកម្ម។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤ មានគោលដៅជំរុញលើកកំពស់ចលនាសត្វ និងវារីវប្បកម្មឱ្យកាន់តែទូលំទូលាយថែមទៀត តាមរយៈការបង្កើតក្របខណ្ឌគោលដៅនយោបាយដោយផ្អែកលើគោលការណ៍ខ្សែចង្វាក់តម្លៃ ដើម្បីដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍវិស័យទាំងនេះ ដោយគិតគូរផងដែរដល់បញ្ហាសុវត្ថិភាព ចំណីអាហារ និងកិច្ចដំណើរការទីផ្សារ ពិសេសអនាម័យ និងភូតគាមអនាម័យ ទន្ទឹមនឹងការបន្តអនុវត្តវិធានការមុតស្រួចនានា សំដៅធានារក្សាចីរភាពនៃធនធានជលផល ទាំងក្នុងដែនទឹកសាប និងសមុទ្រ។

### *មុំទី៣. ការកែទម្រង់ដីធ្លី, ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម*

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺបន្តធ្វើកំណែទម្រង់ដីធ្លី ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រង, បែងចែក និងប្រើប្រាស់ដីធ្លី, ធានាសុវត្ថិភាពកម្មសិទ្ធដី, លុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីធ្លីដោយខុសច្បាប់ និងទប់ស្កាត់ការប្រមូលដីទុកដោយមិនបានប្រើប្រាស់ និងមិនផលិត ព្រមទាំងបន្តបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមដែលត្រូវបានកំណត់ជាគោលដៅទី៩ នៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា។

### *មុំទី៤. ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព*

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ បានផ្តោតលើការគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ និងជលផល ដើម្បីធានាចីរភាពនៃកំណើនសេដ្ឋកិច្ចជាតិ និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជននៅតាមទីជនបទ តាមរយៈការជំរុញអនុវត្តកម្មវិធីព្រៃសហគមន៍, ការត្រួតពិនិត្យឃ្លាមដានការធ្វើអាជីវកម្មព្រៃឈើ ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងការអនុវត្តវិធានការម៉ឺងម៉ាត់ចំពោះបទល្មើសព្រៃឈើ, ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងព្រៃបំរុង, ការអនុវត្តស៊ីជម្រៅនូវការកែរទម្រង់ឡូត៍នេសាទ និងជលផល។

ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងថែមទៀតនូវការគ្រប់គ្រងធនធានធម្មជាតិ សំដៅរក្សា "តុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្ស" ពិសេសលើកកំពស់វិភាគទាននៃធនធានធម្មជាតិ ចំពោះការអភិវឌ្ឍវិស័យកសិកម្មតាមរយៈ (១). ការធានាគម្របបៃតង, ការអភិរក្សព្រៃឈើ និងសត្វព្រៃ, (២). ការធានាចីរភាពនៃធនធានជលផល, និង(៣). ការរក្សាចីរភាពប្រព័ន្ធអេកូឡូស៊ីដើម្បីធានាគុណភាពដី និងចីរភាពនៃប្រភពទឹក ដោយផ្តោតការការពារជីវចម្រុះ, តំបន់ដីសើម និងតំបន់ឆ្នេរ។

ក្នុងគោលដៅនេះ រាជរដ្ឋាភិបាល នឹងប្រកាន់យកអភិក្រម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នា សំដៅលើកកម្ពស់ប្រសិទ្ធភាព និងសមធម៌ក្នុងការប្រើប្រាស់ធនធានធម្មជាតិ តាមរយៈ(១). ការកំណត់ច្បាស់លាស់នូវកម្មសិទ្ធលើធនធានធម្មជាតិ (២). ការពង្រឹងប្រព័ន្ធលើកទឹកចិត្តត្រឹមត្រូវក្នុងការងារអភិរក្សធនធានធម្មជាតិ និងការផ្តល់សិទ្ធអំណាចដល់អាជ្ញាធរថ្នាក់ក្រោមជាតិ, សហគមន៍ និងប្រជាជនម្នាក់ៗ ក្នុងការចូលរួមអភិរក្សធនធានធម្មជាតិ ដោយផ្តោតលើការបណ្តុះបណ្តាល, ការផ្តល់ព័ត៌មាន ព្រមទាំងការពង្រឹងមូលដ្ឋានសង្គម, គណនេយ្យភាព និងតម្លាភាពនៃស្ថាប័ន និង(៣). ការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយតួអង្គអភិរក្សពាក់ព័ន្ធ ក្នុងក្រមខណ្ឌកំណើនបៃតង និងការប្រែប្រួលអាកាសធាតុ។

## ចតុកោណទី២. ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ការអភិវឌ្ឍ និងទំនើបកម្មវិស័យហេដ្ឋារចនាសម្ព័ន្ធ គឺជាកត្តាដ៏សំខាន់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច, បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចព្រមទាំងពង្រីកភាពប្រកួតប្រជែង និងជម្រុញពិពិធកម្មសេដ្ឋកិច្ចកម្ពុជា ពិសេសសម្រាប់កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្នុងន័យនេះ ដើម្បីឆ្លើយតបទៅនិងដំណាក់កាលថ្មីនៃការអភិវឌ្ឍ សម្រាប់រយៈពេលវែងខាងមុខ រាជរដ្ឋាភិបាល នឹងរៀបចំផែនការមេ នៃការតភ្ជាប់មួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយទាំងផ្នែករឹង និងផ្នែកទន់ដែលគ្របដណ្តប់លើវិស័យគមនាគមន៍ដឹកជញ្ជូន. វិស័យថាមពលអគ្គិសនី ព្រមទាំងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍



Draft

ទន្ទឹមនឹងការបន្តជំរុញអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងវិស័យទឹកស្អាត។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលនឹងបង្កើនការយកចិត្តទុកដាក់លើការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីក្រុង។ កិច្ចការទាំងនេះ នឹងត្រូវបានធ្វើដោយធានាសង្គតិភាពជាមួយនឹងក្រមខណ្ឌ នៃការរៀបចំដែនដី និងនគរូបនីយកម្ម។

### *មុំទី១. វិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង*

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ជាអាទិ៍ ការបន្តសាងសង់ផ្លូវ, ការថែទាំផ្លូវ, ការពង្រឹងសមត្ថភាពកំពង់ផែ, ការស្តារ និងការអភិវឌ្ឍវិស័យផ្លូវដែក, ការពង្រីកសេវាអាកាសយានដ្ឋាន និងការពង្រីកសុវត្ថិភាពហោះហើរ និងសុវត្ថិភាពចរាចរណ៍។ រាជរដ្ឋាភិបាលបានសម្រេចវឌ្ឍនភាពល្អប្រសើរក្នុងការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដើម្បីសមាហរណកម្មផ្ទៃក្នុងប្រទេស និងការតភ្ជាប់ទៅនឹងតំបន់។

ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍក្នុងដំណាក់កាលថ្មី រាជរដ្ឋាភិបាលនីតិកាលទី៤ ដាក់ចេញនូវគោលដៅបន្តអភិវឌ្ឍន៍បណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់ប្រភេទ រួមជាមួយនិងហេដ្ឋារចនាសម្ព័ន្ធទីក្រុងឱ្យក្លាយទៅជាឡូជីស្ទីកមួយដ៏រស់រវើក, មានសុវត្ថិភាព និងមានប្រសិទ្ធភាព សំដៅរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងជួយលើកស្ទួយសុខុមាលភាពរបស់ប្រជាជន។

### *មុំទី២. ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ*

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការជំរុញកសាងថែទាំ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងការផ្គត់ផ្គង់ទឹកស្អាត។

រាជរដ្ឋាភិបាលនីតិកាលទី៤ នឹងបន្តលើកកម្ពស់គ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ, បង្កើនប្រសិទ្ធភាពនៃការថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ, ជំរុញសមាហរណ៍កម្មប្រព័ន្ធធារាសាស្ត្រជាមួយនឹងការអភិវឌ្ឍអគ្គិសនី និងប្រព័ន្ធដឹកជញ្ជូន ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍក្របខណ្ឌគតិយុត្ត, ស្ថាប័ន និងធនធានមនុស្ស។

### *មុំទី៣. ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី*

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់, ការចុះថ្លៃអគ្គិសនីឱ្យបានសមរម្យ និងការពង្រឹងយន្តការស្ថាប័ន និងសមត្ថភាពគ្រប់គ្រង។

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ ក្នុងវិស័យថាមពលអគ្គិសនី គឺការបន្តពង្រឹងសមត្ថភាព និងសុវត្ថិភាពក្នុងការផ្គត់ផ្គង់ ព្រមទាំងការពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ ដើម្បីបង្កើនភាពប្រកួតប្រជែងសេដ្ឋកិច្ច, ទ្រទ្រង់កំណើនសេដ្ឋកិច្ចរយៈពេលវែង, ពង្រឹងសមត្ថភាពធានាសន្តិសុខថាមពលអគ្គិសនី និងលើកកម្ពស់ជីវភាពរបស់ប្រជាជន។

### *មុំទី៤. ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍*

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺជំរុញការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ទំនើប និងប្រកបដោយគុណភាពតាមរយៈការពង្រឹងក្របខណ្ឌគតិយុត, ការកសាងសមត្ថភាពស្ថាប័ន, ការធ្វើទំនើបកម្មមូលដ្ឋានសម្ភារបច្ចេកទេស, ការលើកស្ទួយការប្រកួតប្រជែង, ការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងរដ្ឋាបាលអេឡិចត្រូនិច ព្រមទាំងការជំរុញសាងសង់ និងបង្កើនប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង សម្រាប់វិស័យបច្ចេកទេសព័ត៌មាន និងគមនាគមន៍។

ក្នុងគោលដៅត្រៀមរៀបចំមូលដ្ឋាន សម្រាប់ការឈានឡើងរបស់កម្ពុជា ទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍពិសេសការធានាការប្រកួតប្រជែងរបស់កម្ពុជានៅក្នុង "សេដ្ឋកិច្ចពុទ្ធិ" នាពេលអនាគត, រាជរដ្ឋាភិបាលនីតិកាលទី៤ នឹងបន្តអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ឱ្យមានលក្ខណៈទំនើបទាន់សម័យ មានគុណភាពខ្ពស់ ស្របតាមស្តង់ដារអន្តរជាតិ, មានថ្លៃប្រកួតប្រជែង និងមានសេវាគ្របដណ្តប់នៅទូទាំងប្រទេស ដែលប្រជាជនទូទៅអាចប្រើប្រាស់បាន និងទទួល

ផលប្រយោជន៍គ្រប់ៗគ្នាពីសេវានេះ។

**ចតុកោណទី៣. ការអភិវឌ្ឍវិស័យឯកជន និងការងារ**

រាជរដ្ឋាភិបាលបានកំណត់ថា" **វិស័យឯកជន គឺជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច**"។ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍក្នុងដំណាក់កាលថ្មី រាជរដ្ឋាភិបាលនឹងបន្តជំរុញអភិវឌ្ឍវិស័យវិស័យឯកជន តាមរយៈវិធានការ ជាកញ្ចប់ និងគ្រប់ជ្រុងជ្រោយសំដៅរៀបចំ និងកែលម្អគោលនយោបាយពាក់ព័ន្ធផ្សេងៗទៀត រួមទាំងការអភិវឌ្ឍហិរញ្ញវត្ថុ និងធនាគារ និងទីផ្សារការងារផង។ ក្នុងកិច្ចដំណើរនេះ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវ "**គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម**" ដែលមានតួនាទីស្នូលក្នុងការនាំសេដ្ឋកិច្ចកម្ពុជាឈានឡើងកាន់ខ្ពស់ថ្មីមួយ ក្នុងខ្សែចង្វាក់នៃតម្លៃបន្ថែមក្នុងតំបន់ និងសកលលោក។

*មុំទី១. ការពង្រឹងវិស័យឯកជន និងការជំរុញការវិនិយោគ និងធុរកិច្ច*

រាជរដ្ឋាភិបាលនីតិកាលទី៤ ដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រពីរគឺៈ (១). ការបន្តជំរុញអភិវឌ្ឍវិស័យឯកជនឱ្យកាន់តែមានភាពរស់រវើក និងមានជីវភាពខ្លាំងថែមទៀត ក្នុងតួនាទីជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និង(២). ការប្រែក្លាយកម្ពុជាឱ្យទៅជាគោលដៅវិនិយោគប្រកបដោយភាពទាក់ទាញ និងភាពប្រកួតប្រជែងនៅក្នុងតំបន់ ពិសេសក្នុងក្របខណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន។

*មុំទី២. ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម*

គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ពិសេសការពង្រឹងបរិស្ថានធុរកិច្ច តាមរយៈការកែលម្អក្របខណ្ឌគតិយុត, លើកស្ទួយនវានុវត្តន៍ និងបច្ចេកវិទ្យា, ការលើកកម្ពស់លទ្ធភាពទទួលហិរញ្ញប្បទាន និងការពង្រឹង និងពង្រីកសេវាកម្មគាំទ្រផ្សេងៗទៀត ព្រមទាំងធ្វើសមាហរណ៍កម្មសហគ្រាសធុនតូចនិងមធ្យមទៅក្នុងខ្សែសង្វាក់តម្លៃជាសកល។

ក្នុងនីតិកាលទី៤ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការបន្តធ្វើពិពិធកម្មមូលដ្ឋាន ឧស្សាហកម្ម តាមរយៈការជំរុញលើកទឹកចិត្តវិនិយោគក្នុងវិស័យឧស្សាហកម្មថ្មីៗទំនើប ដែលមានតម្លៃបន្ថែមខ្ពស់, មានភាពច្នៃប្រឌិតរស់រវើក និងមានសមត្ថភាពប្រកួតប្រជែង ពិសេសឧស្សាហកម្មផ្គុំដំឡើង, ឧស្សាហកម្មអេឡិចត្រូនិច, ឧស្សាហកម្មគ្រឿងបន្លាស់, ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្មកម្មន្តសាលផ្សេងៗទៀត, គួបផ្សំនឹងការបន្តជំរុញអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម រួមទាំងសិប្បកម្មផង ព្រមទាំងការរុញការអភិវឌ្ឍឧស្សាហកម្មឱ្យទៅដល់ទីជនបទសំដៅរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចក៏ដូចជា បង្កើតការងារ និងបង្កើតចំណូលជូនប្រជាជន។ បន្ថែមលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ផងដែរលើការអភិវឌ្ឍ និងការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវខ្ពស់ លើវិស័យឧស្សាហកម្មនីស្សារណកម្ម ដើម្បីប្រែក្លាយទៅជាប្រភពមួយទៀតនៃកំណើនសេដ្ឋកិច្ចកម្ពុជា។

*មុំទី៣. ការអភិវឌ្ឍទីផ្សារការងារ*

គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺជាបន្តអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ, ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យសមស្របតាមសេចក្តីត្រូវការទីផ្សារ, ការផ្សព្វផ្សាយព័ត៌មានអំពីសេចក្តីត្រូវការនៃទីផ្សារការងារ, ការកសាងប្រព័ន្ធស្ថិតិការងារ និងក្របខណ្ឌគុណវុឌ្ឍជាតិ, ការពង្រឹងយន្តការដោះស្រាយវិវាទការងារ និងបន្តអនុវត្តច្បាប់ស្តីពីការងារ។

រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងបន្តកែទម្រង់ឱ្យបានស៊ីជម្រៅថែមទៀត ទាំងលើគោលនយោបាយ, ក្របខណ្ឌគតិយុត្ត និងយន្តការស្ថាប័ន ដែលបានអនុវត្តន៍កន្លងមក សំដៅធ្វើឱ្យគ្រប់សមាសភាគនៃទីផ្សារការងារដំណើរការប្រកបដោយភាពស៊ីសង្វាក់គ្នា និងជួយគាំទ្រទៅវិញទៅមក ដើម្បីរួមចំណែកលើកកម្ពស់កំណើនសេដ្ឋកិច្ច, បង្កើតការងារ និងលើកស្ទួយជីវភាពប្រជាជន។

Draft

### *មុំទី៤. ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ*

គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុឱ្យមានភាពរឹងមាំ និងផ្អែកលើគោលការណ៍ទីផ្សារសំដៅពង្រឹងតួនាទីជាកម្លាំងចលករនៃវិស័យហិរញ្ញវត្ថុក្នុងការអភិវឌ្ឍ និងពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ពិសេសតាមរយៈការគៀងគរធនធានហិរញ្ញវត្ថុ ដើម្បីបម្រើឱ្យសេចក្តីត្រូវការហិរញ្ញប្បទានកើនឡើងជាប្រចាំ។

គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺជាបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយ ដែលមានវិសាលភាពកាន់តែទូលាយ, កាន់តែមានពិពិធភាព, កាន់តែស៊ីជម្រៅ ហើយរឹងមាំ និងមានប្រសិទ្ធភាព ដោយផ្អែកលើគោលការណ៍ទីផ្សារ ដើម្បីទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយផ្លែផ្កានូវ "**យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០**"។

## ចតុកោណទី៤. ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

### *មុំទី១. ការពង្រឹង និងការលើកកំពស់វិស័យអប់រំ, វិទ្យាសាស្ត្រ, បច្ចេកទេស ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស*

គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្តោតលើការផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និងយុវជនកម្ពុជាទាំងអស់ ក្នុងការទទួលការអប់រំមូលដ្ឋាន, ទាំងក្នុង និងក្រៅប្រព័ន្ធ, ព្រមទាំងបន្តយកចិត្តទុកដាក់លើការកែលម្អគុណភាពអប់រំដើម្បីឆ្លើយតបទៅ និងសេចក្តីត្រូវការនៃការអភិវឌ្ឍប្រទេស។

រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងបន្តជំរុញអនុវត្តន៍គោលការណ៍ "**ការអប់រំសម្រាប់ទាំងអស់គ្នា**" សំដៅធានាសមធម៌ក្នុងការទទួលបានសេវាអប់រំ, បន្តលើកកម្ពស់គុណធម៌ និងប្រសិទ្ធភាពសេវាអប់រំគ្រប់កម្រិតព្រមទាំងបន្តអភិវឌ្ឍន៍ស្ថាប័ន និងសមត្ថភាពមន្ត្រីអប់រំ។

### *មុំទី២. ការលើកកំពស់សុខភាព និងអាហារូបត្ថម្ភ*

គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺបន្តអនុវត្តន៍ "ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល" សំដៅលើកកំពស់សុខុមាលភាព និងអាហារូបត្ថម្ភរបស់ប្រជាជនទូទៅ, កាត់បន្ថយអត្រាស្លាប់របស់ម្តាយ ទារក និងកុមារ តាមរយៈការពង្រឹង ពង្រីកសេវាសុខាភិបាលប្រកបដោយគុណភាព, ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

រាជរដ្ឋាភិបាលនីតិកាលទី៥ បន្តជំរុញអនុវត្ត និងធ្វើបច្ចុប្បន្នកម្ម "**ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៨-២០១៥**" ដើម្បីលើកកំពស់ការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យសុខាភិបាលសំដៅលើកស្ទួយអនាម័យ, សុខភាព, សុខុមាលភាព និងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជាឱ្យកាន់តែល្អប្រសើរឡើង ពិសេសសម្រាប់ប្រជាជនក្រីក្រ, ងាយរងគ្រោះ, ស្ត្រី និងកុមារ។

### *មុំទី៣. ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម*

គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺពង្រឹងប្រព័ន្ធគាំពារសង្គម និងបង្កើតឱ្យមានប្រព័ន្ធគាំពារសង្គមជាផ្លូវការមួយ សំដៅគាំពារជនក្រីក្រ និងជនងាយរងគ្រោះ ដែលមិនអាចជួយខ្លួនឯងបានដើម្បីទប់ស្កាត់និងបញ្ហាសុខភាព, អប់រំ, អសន្តិសុខស្បៀង និងផលប៉ះពាល់នៃវិបត្តិនានា។

រដ្ឋាភិបាលនីតិកាលទី៥ នឹងបន្តពង្រឹងប្រព័ន្ធគាំពារសង្គមឱ្យកាន់តែមានភាពប្រទាក់ក្រឡាជាប្រព័ន្ធប្រមូលផ្តុំ, មានសង្គតិភាព និងមានប្រសិទ្ធភាពគ្របដណ្តប់ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន ដែលមានការបែងចែកតួនាទីច្បាស់លាស់ និងតាមកម្រិតនិមួយៗ ពោលគឺកម្រិតគោលនយោបាយ, កម្រិតបញ្ញត្តិករ និងប្រតិបត្តិករ។

### *មុំទី៤. ការជំរុញអនុវត្តគោលនយោបាយជាតិប្រជាជន និងសមាភាពយេនឌ័រ*

គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺពង្រឹងគុណភាពប្រជាជន, លើកស្ទួយស្ថានភាពស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយយុវជនឱ្យទៅជាកម្លាំងចលករដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍលើ

Draft

គ្រប់វិស័យ។

រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងផ្តោតការយកចិត្តទុកដាក់ទៅលើការបន្តពង្រឹងការគ្រប់គ្រងជីវភាពប្រជាសាស្ត្រ សំដៅធានាបង្កើនគុណភាព"**មូលធនមនុស្ស**" ដើម្បីទាញយកផលប្រយោជន៍ និងប្រើប្រាស់ ឱ្យអស់លទ្ធភាពនូវសក្តានុពលប្រជាសាស្ត្ររបស់កម្ពុជា សម្រាប់ធានាចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងវឌ្ឍនភាព និងវិបុលភាពរបស់ប្រជាជន។

Draft